# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដី នៅក្នុងឃុំ ចុងដូង
# ស្រុកបារាយណ៍ ខេត្តកំពង់ធំ
# ឆ្នាំ២០១៧ ដល់ ២០៣២




| | |
|---|---|
| រៀបចំដោយ | : ក្រុមហ៊ុនផ្តល់សេវាកម្ម SBK R&D |
| សម្របសម្រួលដោយ | : ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកបារាយណ៍ |
| គាំទ្របច្ចេកទេសដោយ | : អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO-MLMUPC) និងថ្នាក់ខេត្ត (PIO) |
| ឧបត្ថម្ភថវិកាដោយ | : រាជរដ្ឋាភិបាលកម្ពុជា (RGC), ADB_Loan, GAFSP_Grant និងSCF_ADB |

# មាតិកា

**អារម្ភកថា** ............ VIII
**សេចក្តីផ្តើម** ............ 1
**ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំចុងដូង** ............ 3
**១.១. ស្ថានភាពឃុំ** ............ 3
១.១.១. ទីតាំងរដ្ឋបាលឃុំ ............ 3
១.១.២. ប្រជាសាស្ត្រ ............ 5
ក. ចំនួនប្រជាជន ............ 5
ខ. អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន ............ 6
គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ ............ 7
ឃ. របររកទទួលទាន ............ 7
ង. ចំណូលស្រុក និងចំណាកស្រុក ............ 9
១.១.៣. ស្ថានភាពសេដ្ឋកិច្ច ............ 10
ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ ............ 10
ខ. កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ ............ 11
គ. ស្ថានភាពបំណុលសរុប និងអត្រាការប្រាក់ ............ 12
ឃ. ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬ ក្រោមរូបភាពផ្សេងៗ ............ 13
ង. ចំណូលពីប្រភពផ្សេងៗ ............ 13
១.១.៤. ស្ថានភាពសិក្សាធិការ ............ 13
ក. ស្ថានភាពអប់រំ ............ 13
ខ. ស្ថានភាពអក្ខរកម្ម ............ 14
គ.ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត ............ 15
១.១.៥.ស្ថានភាពសុខាភិបាល ............ 16
១.១.៦. ស្ថានភាពយេនឌ័រ ............ 18
**១.២. ស្ថានភាពភូមិសាស្ត្រ** ............ 20

១.២.១. ទីតាំងភូមិសាស្ត្រ ....................................................................................................20

១.២.២. អាកាសធាតុ (ពិពណ៌នាតាមរដូវកាល) ..................................................................28

១.២.៣. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ..................................................29

១.២.៤. បរិក្ខាសាធារណៈ....................................................................................................30

ក. ស្ថានភាពប្រើប្រាស់អគ្គិសនី ....................................................................................30

ខ. ប្រព័ន្ធទឹកស្អាត.......................................................................................................31

**១.៣. ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន**.......................................................................32

១.៣.១. ស្ថានភាពការកាន់កាប់ និងគ្រប់គ្រង ....................................................................32

ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ.......................................................................35

ក.១.ដីលំដីលំនៅឋានភូមិ ...............................................................................................35

ខ. ដីកសិកម្ម.................................................................................................................36

ខ.១.ដីស្រែវស្សា...........................................................................................................36

ខ.២.ដីស្រែប្រាំង ...........................................................................................................37

ខ.៣.ដីស្រែប្រាំងនិងស្រែវស្សា.........................................................................................38

ខ.៤.ដីចម្ការ ..................................................................................................................40

ឃ. ដីព្រៃឈើ/តម្របព្រៃ ...............................................................................................41

ឃ.១.ព្រៃគុម្ពោត...........................................................................................................41

ឃ.៣.ព្រៃលិចទឹក..........................................................................................................42

គ.ផ្ទៃទឹក និងខ្សែទឹក...................................................................................................42

គ.១.បឹង .......................................................................................................................42

គ.២.ស្ទឹង .....................................................................................................................43

គ.៣.ស្រះ.......................................................................................................................43

១.៣.២. ផលិតកម្ម កសិកម្ម ...............................................................................................45

ក. ផលិតកម្មដំណាំស្បៀង ............................................................................................45

ខ. ផលិតកម្មដំណាំរួមផ្សំ ... 46

គ. ផលិតកម្មឧស្សាហកម្ម ... 46

១.៣.៣. ធនធានធម្មជាតិ ... 47

ក. ធនធានព្រៃឈើ ... 47

ខ. ធនធានជលផល ... 47

១.៣.៤. ធនធានរ៉ែ ... 48

**១.៤.ទីផ្សារ និងខ្សែសង្វាក់ផលិតផល** ... 48

១.៤.១.ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ ... 48

១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល ... 48

១.៤.៣.ឧបសគ្គ និងឱកាស ... 51

**ជំពូក ២៖ ការវិភាគ តម្រូវការ សក្ដានុពល និងឧបសគ្គសម្រាប់អនាគត** ... 52

**២.១. តម្រូវការសម្រាប់អនាគត** ... 52

២.១.១. ផែនការអភិវឌ្ឍន៍ឃុំ ... 52

ក. ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ (២០១៨-២០២២) ... 52

ខ. គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតដែលបានអនុម័តរួច ... 55

២.១.២. ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២ ... 56

២.១.៣. តម្រូវការដីធ្លីជាមូលដ្ឋាន ... 57

ក. ដីលំនៅឋាន ... 57

ខ. ដីកសិកម្ម ... 58

គ. ដីព្រៃឈើ ... 59

ឃ. ធនធានទឹក ... 59

ង. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត ... 60

ង.១. វិស័យអប់រំ ... 60

ង.២. វិស័យសុខាភិបាល ... 62

ង.៣. អគ្គិសនី ... 62

ង.៤. ទីលានចាក់សំរាម ....................................................................................................................62
ង.៥. ដីកប់ខ្មោច..............................................................................................................................63
ង.៦. ស្រះ និងអណ្តូងទឹក....................................................................................................................63
**២.២. តំបន់រសើប** .............................................................................................................................63
**២.៣. ការប្រឈម**.................................................................................................................................64
២.៣.១.ការប្រឈមដោយធម្មជាតិ.............................................................................................................64
ក. កំណើនប្រជាជន ........................................................................................................................64
ខ. គ្រោះធម្មជាតិ ការរេចរឹលនៃធម្មជាតិ ...........................................................................................65
២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍន៍ដែលពុំមាននិរន្តរភាព .......................................................................65
**២.៤. ឱកាស**.......................................................................................................................................66
២.៤.១.ដោយអំណោយផលពីធម្មជាតិ .....................................................................................................66
២.៤.២.ដោយបច្ចេកវិទ្យាថ្មីៗ.....................................................................................................................66
២.៤.៣.ដោយគម្រោងវិនិយោគ....................................................................................................................66
**២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ** .........................................................................................67
**ជំពូក ៣៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគតឆ្នាំ២០១៧-២០៣២** ............................ 71
**៣.១. តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង** ......................................................................... 71
៣.១.១.តម្រូវការដីទៅតាមប្រភេទ ........................................................................................................ 71
៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល..................................................................................................... 71
**៣.២. ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់** .....................................................................................72
៣.២.១. ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ ...........................................................................................72
៣.២.២. ផែនទីប្រើប្រាស់ដីអនាគត ..........................................................................................................75
៣.២.៣. សេចក្តីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត ..................................................................77
ក. ដីលំនៅឋាន ភូមិ៖..........................................................................................................................77
គ. ដីស្រែប្រាំង.....................................................................................................................................78
ឃ. ដីស្រែប្រាំងនិងវស្សា ......................................................................................................................78

ង. ដីចម្ការ ........ 79
ច. ព្រៃគុម្ពោត ........ 79
ឆ. ព្រៃជាមួយចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប ........ 80
ជ. ព្រៃលិចទឹក ........ 80
ឈ. បឹង ........ 80
ញ. ស្ទឹង ........ 81
ដ. ស្រះ ........ 81
**៣.៣.ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី** ........ 81
**៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព** ........ 82
៣.៤.១. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព ........ 82
ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម ........ 82
ខ. ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត ........ 83
៣.៤.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព ........ 84
**៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)** ........ 85

## បញ្ជីតារាង

តារាង 1 ៖ ស្ថានភាពទូទៅនៃឃុំ ........ 3
តារាង 2 ៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ ........ 5
តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ ........ 6
តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម ........ 7
តារាង 5៖ តារាងមុខរបរ ........ 7
តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ ........ 9
តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧ ........ 9
តារាង 8៖ ស្ថិតិប្រជាជនចំណាកស្រុក ........ 10
តារាង 9៖ តារាងកម្រិតជីវភាពរបស់ប្រជាជន ........ 11
តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧ ........ 14
តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ ........ 15
តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត ........ 16
តារាង 13៖ សុខភាពមាតា និងទារក ........ 16
តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព ........ 18

តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំចុងដូង ..... 19
តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹង ឃុំចុងដូង ស្រុកបារាយណ៍ ..... 22
តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ ..... 27
តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ ..... 29
តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន ..... 29
តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី ..... 31
តារាង 21៖ ស្ថិតិអ្នកប្រើប្រាស់ការប្រើប្រាស់ទឹក ..... 31
តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីនីមួយៗឃុំចុងដូង ..... 34
តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ..... 45
តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ..... 46
តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ..... 46
តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ..... 47
តារាង 27៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ..... 47
តារាង 28៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ ..... 48
តារាង 29៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ទីផ្សារនិងខ្សែសង្វាក់ផលិតផល ..... 51
តារាង 30៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត ..... 52
តារាង 31៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ) ..... 56
តារាង 32៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ) ..... 57
តារាង 33៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២ ..... 58
តារាង 34៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២ ..... 59
តារាង 35៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២ ..... 61
តារាង 36៖ បញ្ហាប្រឈម (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ) ..... 67
តារាង 37៖ ការប្រើប្រាស់ដីនាពេលអនាគត ឃុំចុងដូង ..... 73
តារាង 38៖ តារាងផែនការផ្នែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត ..... 74
តារាង 39៖ តារាងផែនការផ្នែកសេវាកម្មនាពេលអនាគត ..... 74

## បញ្ជីដ្យាក្រាម

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ២០១៧ ..... 5
ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព ..... 18
ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ ..... 29
ដ្យាក្រាម 4៖ គំនូសតាងនៃការលំហូរផលិតផលកសិកម្ម នៅក្នុងភូមិ និង ការប្រើប្រាស់ ..... 50

## បញ្ជីផែនទី

ផែនទី 1៖ ផែនទីទីតាំងឃុំចុងដូង ស្រុកបារាយណ៍ ..... 4
ផែនទី 2៖ ផែនទីព្រំប្រទល់រដ្ឋបាលឃុំចុងដូង ..... 4
ផែនទី 3៖ ផែនទីរយៈកម្ពស់ឃុំចុងដូង ..... 21

ផែនទី 4៖ ពំនុះកាត់ទទឹងឃុំចុងដូង ....... 22
ផែនទី 5 ៖ ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំចុងដូង ....... 28
ផែនទី 6 ៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំចុងដូង ....... 30
ផែនទី 7 ៖ ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំចុងដូង ....... 32
ផែនទី 8៖ ផែនទីប្រើប្រាស់ដីលម្អិត ឃុំចុងដូង ....... 33
ផែនទី 9៖ ផែនទីគម្រោងអាទិភាពឃុំចុងដូង ....... 55
ផែនទី 10៖ ផែនទីតំបន់រសើប ឃុំចុងដូង ....... 64
ផែនទី 11៖ ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ....... 70
ផែនទី 12៖ ផែនទីប្រើប្រាស់ដីពេលអនាគត ឃុំចុងដូង ....... 76

## បញ្ជីរូបភាព

រូបភាព 1៖ សាលារៀន ....... 14
រូបភាព 2៖ មណ្ឌលសុខភាពនៅក្នុងឃុំចុងដូង ....... 17
រូបភាព 3៖ ប្រព័ន្ធធារាសាស្ត្រ ....... 27
រូបភាព 4៖ ប្រព័ន្ធគមនាគមន៍ ....... 30
រូបភាព 5៖ លំនៅឋានភូមិ ....... 36
រូបភាព 6៖ ដីស្រែវស្សា ....... 37
រូបភាព 7៖ ដីស្រែប្រាំង ....... 38
រូបភាព 8៖ ដីស្រែប្រាំង និង ស្រែវស្សា ....... 39
រូបភាព 9៖ ចម្ការស្វាយចន្ទី ....... 40
រូបភាព 10៖ ព្រៃគុម្ពោត ....... 41
រូបភាព 11៖ ព្រៃលិចទឹក ....... 42
រូបភាព 12៖ បឹង ....... 43
រូបភាព 13៖ ស្ទឹង ....... 43
រូបភាព 14៖ ស្រះ ....... 44
រូបភាព 15៖ ផលិតផលកសិកម្ម ....... 49

# អារម្ភកថា

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គឺជាឧបករណ៍មួយដ៏សំខាន់ នៅក្នុងការជួយដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ផ្ទាល់ ក៏ដូចជាដល់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកទៅដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបទៅដោយចីរភាព និងសមធម៌ ហើយជាពិសេសការគ្រប់គ្រង និងប្រើប្រាស់ដី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ ដូច្នេះក្រោយពេលមានផែនការប្រើប្រាស់ដីនេះ អាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរដែនដី នឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយ នៅក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់នេះ ទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនៅថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ស្រុក និងធ្វើការអនុម័តនៅថ្នាក់រាជធានី/ខេត្ត ទៅតាមនីតិវិធី ដូចដែលធ្លាប់អនុវត្តនៅក្នុងការកសាង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចកន្លងមកដោយមានគ្រប់ភាគីពាក់ព័ន្ធទាំងអស់ចូលរួមធ្វើការសម្រេច។ ក្នុងទឹកចិត្តសោមនស្សរីករាយជាអនេក ខ្ញុំមានកិត្តិយសសូមបង្ហាញនូវរបាយការណ៍បច្ចេកទេសស្តីពីផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង មានចក្ខុវិស័យរហូតដល់ឆ្នាំ២០៣២ ដែលក្រុមការងារបានខិតខំប្រឹងប្រែងធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំឡើងអស់រយៈពេលជាងពីរឆ្នាំកន្លងមកនេះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងកម្មវិធីកសិកម្ម និងសន្តិសុខស្បៀងពិភពលោក (GAFSP) ដែលបានគាំទ្រឧបត្ថម្ភថវិកា ក្រុមហ៊ុនផ្តល់សេវាកម្មមកជួយសិក្សារៀបចំផែនការនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានទទួលគ្រប់គ្រងគម្រោង និងគាំទ្របច្ចេកទេស រដ្ឋបាលខេត្តកំពង់ធំ និងរដ្ឋបាលស្រុកបារាយណ៍ ដែលបានជួយសម្របសម្រួលដល់កិច្ចដំណើរការរបស់គម្រោង និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមនៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូងនេះ។ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូងនេះ នឹងបានចូលរួមចំណែកដល់ការអភិវឌ្ឍន៍ឃុំប្រកបដោយចីរភាព ថែមទាំងត្រូវបានប្រើប្រាស់ដោយមានការចូលរួមនិងមានការគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋបាលនៅថ្នាក់ក្រោមជាតិនិងពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់៕

ថ្ងៃ...សុក្រ ១៣ រោច......ខែ.កត្តិក.......ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ចុងដូង ថ្ងៃទី..១៣...ខែ.....វិច្ឆិកា......ឆ្នាំ២០២០

ប្រធានក្រុមប្រឹក្សាឃុំ និងជាមេឃុំចុងដូង

កែវ_អ៊ុក

# សេចក្តីផ្តើម

ស្ថិតនៅក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាល ដែលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាល បានបន្តធ្វើការជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ នៅក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបទៅដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជា នៅក្រោមការដឹកនាំប្រកបទៅដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវគោលនយោបាយជាតិ ស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាសំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន ឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ ។

ឃុំចុងដូង ជាឃុំមួយក្នុងចំណោមឃុំទាំង ១០ ស្ថិតក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ មានតំបន់លំនៅឋានមួយផ្នែក និងមួយផ្នែកទៀតជាតំបន់កសិកម្ម មានផ្ទៃដីសរុបចំនួន ១២ ៧១២,៣២ ហិកតា ដែលមានព្រំប្រទល់ខាងជើងជាប់នឹង ឃុំត្នោតជុំ ស្រុកបារាយណ៍ ខាងត្បូងជាប់នឹង ឃុំបឹង ឃុំបារាយណ៍ ស្រុកបារាយណ៍ ខាងកើតជាប់នឹងឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខាងលិចជាប់នឹងឃុំញ្ញើ ស្រុកសន្ទុក ។ មានគ្រួសារសរុប ៣ ០៣៨ គ្រួសារ មានប្រជាជនសរុប ១៣ ៧៤៨ នាក់ នៅក្នុងនោះស្ត្រី ៦ ៩៦១ នាក់ ហើយប្រជាពលរដ្ឋ ៧៥ % ជាកសិករ។ ឃុំចុងដូង មានផ្ទៃដីស្រែសរុបទំហំ ៨ ៨៥៥,៣៤ ហិកតា គឺជាផ្ទៃដី ដែលមានទំហំធំទូលាយមានវិសាលភាព ស្រូបអស់ ៦៤ % នៃផ្ទៃដីសរុបរបស់ឃុំ ដែលជាបង្អែកដ៏មានសក្តានុពលតែមួយគត់ សម្រាប់ការអភិវឌ្ឍន៍នៅក្នុងឃុំចុងដូង ប្រកបដោយចីរភាព ។

ក្នុងគោលដៅធានាការគ្រប់គ្រង និងអភិវឌ្ឍឃុំចុងដូង ប្រកបដោយចីរភាពនេះ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ និងស្រុកបារាយណ៍ ព្រមទាំងក្រុមប្រឹក្សាឃុំចុងដូង ក្រោមការទទួលសិទ្ធិផ្តល់សេវាកម្មរៀបចំផែនការប្រើប្រាស់ដី នៅក្នុងឃុំចុងដូង ដោយក្រុមហ៊ុន SBK Co,LTd និងមានការគ្រប់គ្រងគាំទ្របច្ចេកទេស ដោយអង្គភាពអនុវត្តគម្រោងនៅថ្នាក់ខេត្ត (PIO) និងអង្គភាពអនុវត្តគម្រោងនៅថ្នាក់ជាតិ (NIO) នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងមានការគាំទ្រ និងឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង ដែលមាន ចក្ខុវិស័យឆ្នាំ ២០៣២ សម្រាប់តម្រង់ទិសដល់ការអភិវឌ្ឍន៍ឃុំ ពាក់ព័ន្ធការប្រើប្រាស់ដីក្នុងឃុំចុងដូង ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ ដើម្បីជាមូលដ្ឋានជួយដល់ក្រុមប្រឹក្សាឃុំផ្ទាល់ ក៏ដូចជា អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយចីរភាព និងសមធម៌ ដែលនៅក្នុងនោះមានការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍន៍ឃុំ ធ្វើឱ្យជីវភាពប្រជាពលរដ្ឋមានភាពប្រសើរឡើងរួចផុតពីភាពក្រីក្រ ជាពិសេសប្រើប្រាស់ដីកសិកម្ម នៅក្នុងឃុំចុងដូង ឱ្យអស់សក្តានុពលដែលមាន នៅក្នុងការផលិតស្រូវ ដើម្បីបង្កើនការនាំចេញអង្ករឱ្យបានច្រើននៅពេលខាងមុខ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល ដែលនៅសល់ពីការហូបចុកតាមរយៈការប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូងនេះ ដែលជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ឃុំ តាមអាណត្តិនីមួយៗរបស់ខ្លួន ។

ផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង ត្រូវបានរៀបចំឡើង មានការសិក្សាស្រាវជ្រាវច្បាស់លាស់ទៅលើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន ព្រមទាំងគោលនយោបាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួន ដែលពាក់ព័ន្ធទៅនឹងការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតការសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន ។ ចំពោះនីតិវិធីនៃការរៀបចំផែនការប្រើប្រាស់ដីនេះវិញ ត្រូវបានរៀបចំឡើងដោយផ្អែកទៅលើអនុក្រឹត្យ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដី នៅក្នុងឃុំ/សង្កាត់ ព្រមទាំងប្រកាសរួមស្តីពីនីតិវិធីលម្អិត សម្រាប់ការរៀបចំ និងអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ និងឯកសារណែនាំអនុវត្តស្តីពី ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ មានដំណើរការរៀបចំផែនការ ដូចមានសង្ខេបក្នុងដ្យាក្រាមខាងក្រោម ៖

ដ្យាក្រាម៖ ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់




សម្គាល់៖ ប្រអប់បង្ហាញទំហំការងារដែលត្រូវអនុវត្តតាមឯកសារណែនាំ

# ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំចុងដូង

## ១.១. ស្ថានភាពឃុំ

កាលដើមឡើយ មានអ្នកជំនួញម្នាក់មកពីប្រទេសចិន ឈ្មោះថាដូង បានមករកស៊ីនៅក្នុងឃុំនេះ ហើយបានកសាងអណ្តូងទឹកមួយចំនួន និងវត្តមួយដោយដាក់ឈ្មោះរបស់គាត់ ហៅថាវត្តចិនដូង ប៉ុន្តែក្រោយមកពាក្យចិនដូងនេះ ត្រូវបានប្រែក្លាយទៅជាចុងដូងវិញ តាមរយៈការហៅតៗគ្នារបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ។ ប្រជាជនបានដាក់ឈ្មោះភូមិនៅកន្លែងនោះថា **"ភូមិចុងដូង"** ។ រហូតមកដល់ឆ្នាំ២០០១តំបន់នេះ ត្រូវបានរដ្ឋាភិបាលប្រកាសដាក់ឈ្មោះថា **"ឃុំចុងដូង"** ជាផ្លូវការរហូតមកដល់បច្ចុប្បន្ននេះតាមប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ៤៩៣ប្រ.ក/៣០-មេសា-២០០១ ។

### ១.១.១. ទីតាំងរដ្ឋបាលឃុំ

ឃុំចុងដូង គឺជាឃុំមួយនៅក្នុងចំណោមឃុំទាំង ១០ ស្ថិតនៅក្រោមការគ្រប់គ្រង របស់រដ្ឋបាលស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ឃុំនេះមានភូមិចំនួន ០៨ គឺភូមិទួលដំណាក់ ភូមិសំរោង ភូមិខ្សាច់ល្អិត ភូមិគួរ ភូមិទួលសាលា ភូមិកំប៉ើយ ភូមិពពេជ និងភូមិចុងដូង ដែលមានផ្ទៃដីទំហំសរុបចំនួន ១២ ៧១២,៣២ ហិកតា (ប្រភពទិន្នន័យ៖ ក្រុមការងារ GIS ឆ្នាំ ២០១៨) និងមានព្រំប្រទល់ជាប់នឹង៖

- ខាងជើង ជាប់នឹង ឃុំត្នោតជុំ ស្រុកបារាយណ៍
- ខាងត្បូង ជាប់នឹង ឃុំបឹង ឃុំបារាយណ៍ ស្រុកបារាយណ៍
- ខាងកើត ជាប់នឹង ឃុំបល្ល័ង្គ ស្រុកបារាយណ៍
- ខាងលិច ជាប់នឹង ឃុំញ៉ៅ ស្រុកសន្ទុក

តារាង 1 ៖ ស្ថានភាពទូទៅនៃឃុំ

| **ខេត្ត** | **កំពង់ធំ** | **លេខកូដខេត្តៈ ០៦** |
|---|---|---|
| ស្រុក | បារាយណ៍ | លេខកូដស្រុកៈ ០៦០១ |
| ឃុំ | ចុងដូង | លេខកូដឃុំ : ០៦០១០៨ |
| ចំនួន៨ភូមិ | ១. ទួលដំណាក់ | លេខកូដភូមិៈ ០៦០១០៨០១ |
| | ២. សំរោង | លេខកូដភូមិៈ ០៦០១០៨០២ |
| | ៣. ខ្សាច់ល្អិត | លេខកូដភូមិៈ ០៦០១០៨០៣ |
| | ៤. គួរ | លេខកូដភូមិៈ ០៦០១០៨០៤ |
| | ៥. ទួលសាលា | លេខកូដភូមិៈ ០៦០១០៨០៥ |
| | ៦. កំប៉ើយ | លេខកូដភូមិៈ ០៦០១០៨០៦ |
| | ៧. ពពេជ | លេខកូដភូមិៈ ០៦០១០៨០៧ |
| | ៨. ចុងដូង | លេខកូដភូមិៈ ០៦០១០៨០៨ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

ផែនទី 1៖ ផែនទីទីតាំងឃុំចុងដូង ស្រុកបារាយណ៍



ផែនទី 2៖ ផែនទីព្រំប្រទល់រដ្ឋបាលឃុំចុងដូង



## ១.១.២. ប្រជាសាស្ត្រ

### ក. ចំនួនប្រជាជន

នៅក្នុងឃុំចុងដូង ចែកចេញជា ០៨ ភូមិ ដែលមាន ៣ ០៩០ គ្រួសារ ប្រជាជនសរុប ១៣ ៧៤៨ នាក់ ក្នុងនោះស្ត្រី ៦ ៩៦១ នាក់ ហើយប្រជាជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងមានចំនួន ៨ ៥៤២ នាក់ ក្នុងនោះស្រីចំនួន ៤ ២៨២ នាក់។ នៅក្នុងឃុំចុងដូង ភូមិដែលមានប្រជាជនច្រើនជាងគេ គឺភូមិទួលដំណាក់ ដែលមាន ៧០២ គ្រួសារ ស្មើនឹង ២២,៧២ ភាគរយ ប្រជានជនសរុបចំនួន ៣ ១០៨ នាក់ ក្នុងនោះស្រីចំនួន ១ ៦០៤ នាក់ ហើយប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅមានចំនួន ១ ៩៥០ នាក់ ក្នុងនោះស្រីមានចំនួន ៩៨៤ នាក់ ចំណែកឯភូមិ ដែលមានប្រជាជនតិចជាងគេ គឺភូមិកំប៉ើយ ដែលមានចំនួន ១៧៦ គ្រួសារ ស្មើងនឹង ៥,៧០ ភាគរយ មានប្រជាជនសរុបចំនួន ៧១៦ នាក់ ស្រីចំនួន ៣៣៥ នាក់ និងប្រជាជនដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅមានចំនួន ៣៣៥ នាក់ នៅក្នុងនោះស្រីមានចំនួន ២១៦ នាក់ ។

តារាង 2 ៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ

| ឈ្មោះភូមិ | គ្រួសារ | គិតជា% | មនុស្ស | | | ១៨ឆ្នាំឡើង | | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ទួលដំណាក់ | ៧០២ | ២២,៧២ | ៣ ១០៨ | ១ ៥០៤ | ១ ៦០៤ | ១ ៩៥០ | ៩៦៦ | ៩៨៤ |
| សំរោង | ៣១០ | ១០,០៣ | ១ ៤៧៦ | ៨១៦ | ៦៦០ | ៦៧៣ | ៣៨៤ | ២៨៩ |
| ខ្សាច់ល្អិត | ៤៥២ | ១៤,៦៣ | ២ ២៣៨ | ១ ០៣៤ | ១ ២០៤ | ១ ៥២០ | ៦៨៩ | ៨៣១ |
| គូរ | ៣៧២ | ១២,០៤ | ១ ៧៨០ | ៨៥៥ | ៩២៥ | ១ ១៧០ | ៥៦៩ | ៦០១ |
| ទួលសាលា | ២២៤ | ៧,២៥ | ៩៥០ | ៤៩២ | ៤៥៨ | ៥៩៦ | ៣១៧ | ២៧៩ |
| កំប៉ើយ | ១៧៦ | ៥,៧០ | ៧១៦ | ៣៨១ | ៣៣៥ | ៣៣៥ | ២៤៣ | ២១៦ |
| ពពេជ | ៤៣៥ | ១៤,០៨ | ១ ៧៦៤ | ៨៥៨ | ៩០៦ | ១ ១៦៥ | ៥៨៦ | ៥៧៩ |
| ចុងដូង | ៤១៩ | ១៣,៥៦ | ១ ៧១៦ | ៨៤៧ | ៨៦៩ | ១ ០០៩ | ៥០៦ | ៥០៣ |
| **សរុប** | **៣ ០៩០** | **១០០** | **១៣ ៧៤៨** | **៦ ៧៨៧** | **៦ ៩៦១** | **៨ ៥៤២** | **៤ ២៦០** | **៤ ២៨២** |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ២០១៧




*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

បើយោងទៅតាមតារាងស្ថិតិប្រជាជនតាមក្រុមអាយុនៅឆ្នាំ ២០១៧ នៅក្នុងឃុំចុងដូង បានបង្ហាញឱ្យឃើញថាប្រជាជនពេញកម្លាំងពលកម្ម ដែលមានអាយុចាប់ពី ២៥ ឆ្នាំ ដល់ ៦០ ឆ្នាំ មានចំនួន ៥ ៣៩៥ នាក់ ស្មើប្រហាក់ប្រហែល ៣៩ភាគរយ នៃប្រជាជនសរុប ក្រៅពីនេះមានអាយុពីកើតដល់ ២៤ ឆ្នាំ មានចំនួន ៦ ៦៣២ នាក់ស្មើប្រហាក់ប្រហែល ៤៨ភាគរយ នៃប្រជាជនសរុប និងប្រជាជនមានអាយុចាប់ពី ៦១ ឆ្នាំឡើង ដែលជាអ្នកបានចូលនិវត្តន៍បាត់បង់សមត្ថភាពការងារមានចំនួន ១ ៧២១ នាក់ ស្មើប្រហាក់ប្រហែល ១៣ភាគរយ នៃប្រជាជនសរុប ។ ដូច្នេះសន្និដ្ឋានបានថា នៅក្នុងឃុំចុងដូង មានមនុស្សពេញកម្លាំងពលកម្មមួយនាក់ ដែលរកចំណូលបានគិតជាមធ្យមត្រូវចិញ្ចឹមមនុស្សជិតពីរនាក់បន្ថែម ។

តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ

| តាមក្រុមអាយុ | ២០១៧ | | | ផ្សេងៗ |
|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | |
| អាយុពី0-២ឆ្នាំ | ៧៨៥ | ៣៩៣ | ៣៩២ | កុមារ |
| អាយុពី៣-៤ | ៦២១ | ៣០៧ | ៣១៤ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៥ឆ្នាំ | ៤១៦ | ២០៥ | ២១១ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៦ឆ្នាំ | ៤៦៤ | ២៣៦ | ២២៨ | អាយុចូលរៀនសាលាបឋម |
| អាយុពី៧-១១ឆ្នាំ | ១ ២៣១ | ៥៧៨ | ៦៥៣ | អាយុចូលរៀនសាលាបឋម |
| អាយុពី១២-១៤ឆ្នាំ | ៨១៩ | ៣៩៧ | ៤២២ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី១៥-១៧ឆ្នាំ | ៨៧0 | ៤១១ | ៤៥៩ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី១៨-២៤ឆ្នាំ | ១ ៤២៦ | ៧២៨ | ៦៩៨ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី២៥-៣៥ឆ្នាំ | ២ 0២៦ | ១ 0៥២ | ៩៧៤ | អាយុពេញពលកម្ម |
| អាយុពី៣៦-៤៥ឆ្នាំ | ១ ៦៩៨ | ៨១៤ | ៨៨៤ | អាយុពេញពលកម្ម |
| អាយុពី៤៦-៦0ឆ្នាំ | ១ ៦៧១ | ៨0៦ | ៨៦៥ | អាយុពេញពលកម្ម |
| អាយុពី៦១ឆ្នាំឡើង | ១ ៧២១ | ៨៦0 | ៨៦១ | អាយុចូលនិវត្តន៍ |
| **សរុប** | **១៣ ៧៤៨** | **៦ ៧៨៧** | **៦ ៩៦១** | |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

### ខ. អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន

ដោយយោងតាម CDB ឆ្នាំ២០១៧ បានឱ្យដឹងថា អត្រាកំណើនប្រជាជនជាមធ្យម នៅក្នុងអំឡុងពេលចន្លោះពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០១៧ មានចំនួន ១,៦៩ ភាគរយ នៅក្នុងនោះសង្កេតឃើញថាមានការធ្លាក់ចុះខ្លាំងនៅឆ្នាំ ២០១៦ គឺមានអត្រាកំណើនប្រជាជនចំនួន -0,៨៥ ភាគរយ មូលហេតុនៃការធ្លាក់ចុះនេះដោយសារមានការផ្លាស់ប្តូរលំនៅឋានចេញ ចំណាកស្រុក ការពន្យាកំណើត មរណៈភាពកុមារ និងដោយកត្តាគ្រោះថ្នាក់ចរាចរណ៍ ជម្ងឺ។ល។ ប៉ុន្តែអត្រាកំណើនប្រជាជននៅឆ្នាំ ២០១៧ មានការកើនឡើងខ្លាំងជាងគេ គឺមានអត្រាកំណើនចំនួន ៣,៨៤ភាគរយ ដែលការកើនឡើងនេះដោយសារមានការផ្លាស់ប្តូរទីលំនៅចូល តាមរយៈអាពាហ៍ពិពាហ៍ និងការកើតថ្មី ។ តែបើពិនិត្យទៅលើជំរឿនប្រជាជនទូទៅនៅឆ្នាំ២០១៩ បានឱ្យដឹងថា អត្រាកំណើនជាមធ្យមនៅក្នុងអំឡុង១0ឆ្នាំ (២00៨-២0១៨) នៅក្នុងខេត្តកំពង់ធំមានចំនួន 0,៦ភាគរយ ទាបជាងអត្រាកំណើនខាងលើដែរ។ ដូច្នេះយើង បានកំណត់យកអត្រា

កំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំក្នុងឃុំចុងដូង ១,៦៩ភាគរយ ជាបានការ ដើម្បីប្រើប្រាស់ក្នុងការព្យាករណ៍កំណើនប្រជាជន ក្នុងឃុំ ។

នៅក្នុងឃុំចុងដូង ក្នុងឆ្នាំ២០១៧ មានដង់ស៊ីតេប្រជាជនរស់នៅ ១២៧ នាក់/គម² ដោយការរស់នៅរបស់ប្រជាពលរដ្ឋភាគច្រើនតាំងលំនៅឋានជាលក្ខណៈរាយប៉ាយតាមភូមិ នៅតាមដងផ្លូវសំខាន់ៗនៅក្នុងឃុំ។

តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម

| ចំនួន | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | កំណើនមធ្យម |
|---|---|---|---|---|---|---|---|
| **ប្រជាជនសរុប** | ១២ ៦៥៥ | ១២ ៧០២ | ១៣ ១៤២ | ១៣ ៣៥២ | ១៣ ២៣៩ | ១៣ ៧៤៨ | |
| **កំណើនមធ្យម**(%) | | ០,៣៧ | ៣,៤៦ | ១,៦០ | -០,៨៥ | ៣,៨៤ | ១,៦៩ |

**☞ចំណាំ**

- អត្រាកំណើនសម្រាប់ចន្លោះឆ្នាំនីមួយៗ៖ (ឆ្នាំចុងក្រោយ-ឆ្នាំដំបូង) x ១០០/ឆ្នាំដំបូង
- អត្រាកំណើនមធ្យមប្រចាំឆ្នាំ៖ (បូកសរុបអត្រាកំណើនតាមឆ្នាំនីមួយ/ចំនួនឆ្នាំ)

### គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់

នៅក្នុងឃុំចុងដូង មានជនជាតិខ្មែរ និងខ្មែរកាត់ចិន ដែលភាគច្រើនកាន់សាសនាព្រះពុទ្ធ និងគោរពប្រពៃណី និងទំនៀមទម្លាប់បែបខ្មែរដូចជា ពិធីរៀបមង្គលការ ប្រារព្ធពីធីបុណ្យទាននៅតាមវត្តអារាម និងតាមផ្ទះនិមន្តព្រះសង្ឃសូត្រមន្តតាមផ្ទះ និងពិធីបូជាសព និងមានចំនួនតិចតួច ដែលមានទំនៀមទម្លាប់បែបចិនដូចជាពិធីសែនព្រេនដូនតា និងពិធីបញ្ចុះសព ។ និយាយរួមប្រជាជននៅក្នុងឃុំចុងដូង តែងតែប្រារព្ធពិធីបុណ្យទានតាមប្រពៃណីទំនៀមទំលាប់ពីបុរាណរៀងមក តាមជំនឿបែបខ្មែរ និងបែបចិនតិចតួច ។

### ឃ. របររកទទួលទាន

បើយោងទៅតាមប្រភពទិន្នន័យមន្ទីរផែនការនៅឆ្នាំ ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំចុងដូង ប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរកសិកម្ម ជាចម្បងរហូតដល់ ៤ ២០១ នាក់ ស្មើនឹង ៦០,២ភាគរយ មុខរបរសិប្បកម្ម ជាចម្បង ចំនួន ៦៣៨ នាក់ ស្មើនឹង ៩,១ភាគរយ និងមុខរបរសេវាកម្ម ចំនួន ២ ១៣៤ នាក់ ស្មើនឹង ៣០,៦ភាគរយ មុខរបរទាំងអស់នោះមានដូចជា៖ ធ្វើស្រែចម្ការ ចិញ្ចឹមសត្វ កម្មករសំណង់ ស៊ីឈ្នួលដកស្ទូងតិចតួច លក់ដូរ ជាងជួសជុលកង់ ម៉ូតូ ជួសជុលរថយន្ត ជាងកាត់ដេរ ជាងកាត់សក់ ជាមន្ត្រីរាជការ អាជីវករលក់ដូរ ធ្វើការជាមួយវិស័យឯកជន និងអង្គការនានា ហើយភាគច្រើនធ្វើការមានជំនាញច្បាស់លាស់ ។

តារាង 5៖ តារាងមុខរបរ

| បរិយាយ | ២០១៧ |
|---|---|
| សរុបអ្នកមានមុខរបរចម្បង | ៦ ៩៧៣ នាក់ |
| %សរុបអ្នកមានមុខរបរចម្បង | ១០២,២ % |
| %ស្រីមានមុខរបរចម្បង(គឺតក្នុងស្រី១៨-៦០ឆ្នាំ) | ៧០,៨ % |
| %ប្រុសមានមុខរបរចម្បង(គឺតក្នុងប្រុស១៨-៦០ឆ្នាំ) | ៩២,៥ % |
| សរុបអ្នកមានមុខរបរចម្បងក្នុងផ្នែកកសិកម្ម | ៤ ២០១ នាក់ |

| បរិយាយ | | ២០១៧ |
|---|---|---|
| %អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម(គឺតក្នុងមុខរបរចម្បង) | | ៦០,២ % |
| %ស្រីមានមុខរបរចម្បងផ្នែកកសិកម្ម(គឺតក្នុងមុខរបរចម្បង) | | ២៨,៥ % |
| ក្នុងនោះ: | %អ្នកមានមុខរបរធ្វើស្រែ | ៥៣,៣ % |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលវែង | ៥,២ % |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលខ្លី | 0,0 |
| | %អ្នកមានមុខរបរដាំដំណាំបន្លែ | 0,0 |
| | %អ្នកមានមុខរបរនេសាទ | 0.0 |
| | %អ្នកមានមុខរបរចិញ្ចឹមសត្វ | 0,២ % |
| | %អ្នកមានមុខរបរពីអនុផលព្រៃឈើ | ១,៤ % |
| សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសិប្បកម្ម | | ៦៣៨ នាក់ |
| %អ្នកបម្រើការងារក្នុងផ្នែកសិប្បកម្ម | | ៩,១ % |
| %ស្រីបម្រើការងារក្នុងផ្នែកសិប្បកម្ម | | ៣,៤ % |
| ក្នុងនោះ: | %អ្នកបម្រើការងារសិប្បកម្មត្បាញរវៃ | 0,0 |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីផ្ដៅ វល្លិ ល្ពាក់,.. | ៣,៥ % |
| | %អ្នកបម្រើការងារសិប្បកម្មផលិតគ្រឿងសង្ហារឹម | ៤,៦ % |
| | %អ្នកបម្រើការងារសិប្បកម្មចម្លាក់ធ្វើពីឈើ ថ្ម ស្ពាន់.. | 0,0 |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីដែក អាលុយមីញ៉ូម | 0,0 |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីជ័រ ប្លាស្ទីក ... | 0,0 |
| | %អ្នកបម្រើការងារសិប្បកម្មកែច្នៃ ឬ វិចខ្ចប់គ្រាប់ធញ្ញជាតិ | 0,0 |
| | %អ្នកបម្រើការងារសិប្បកម្មផលិតផ្សេងៗ | 0,0 |
| សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម | | ២ ១៣៤ នាក់ |
| %អ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម | | ៣០,៦ % |
| %ស្រីបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម | | ១៤,៨ % |
| ក្នុងនោះ: | %អ្នកបម្រើការងារលក់ដូរ និងជំនួញ | ៥,0 % |
| | %អ្នកបម្រើការងារជាជាងជួសជុល | 0,៤ % |
| | %អ្នកបម្រើការងារក្នុងផ្នែកដឹកជញ្ជូន | ១,៥ % |
| | %អ្នកបម្រើការងារស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មករសំណង់ | ៤,២ % |
| | %អ្នកបម្រើការងារក្នុងវិស័យឯកជន(កម្មកររោងចក្រ បុគ្គលិក អង្គការ) | ១៨,៦ % |
| | %អ្នកបម្រើការងារជាមន្ត្រីរាជការ | 0,៨ % |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

ដោយយោងទៅតាមទិន្នន័យមន្ទីរផែនការឆ្នាំ ២០១៧ បានបង្ហាញឱ្យឃើញថា ប្រជាជនក្នុងឃុំចុងដូង ក្រៅពីមុខរបរចម្បងហើយ ពួកគាត់បានបង្កើតមុខរបរបន្ទាប់បន្សំបន្ថែមទៀត ដើមទ្រទ្រង់ជីវភាពនៅក្នុងគ្រួសារ ឱ្យកាន់តែប្រសើរឡើង ហើយក្នុងនោះប្រជាជន ដែលមានមុខរបរបន្ទាប់បន្សំផ្នែកសិកម្ម ២ ៧៧៣នាក់ ស្មើនឹង

៧៩,១ភាគរយ ក្នុងនោះស្រីចំនួន ១ ១៧៦នាក់ ស្មើនឹង ៣៣,៥ភាគរយ សិប្បកម្ម មាន ៤៤៦នាក់ ស្មើនឹង ១២,៧ ភាគរយ នៅក្នុងនោះស្រីមាន ២១៦ នាក់ ស្មើនឹង ៦,២ ភាគរយ និងសេវាកម្មចំនួន ២៦៤ នាក់ ស្មើនឹង ៨,២ ភាគរយ ក្នុងនោះមានស្រីចំនួន ១២០នាក់ ស្មើនឹង ៣,៤ភាគរយ ។

ដូច្នេះតាមព័ត៌មានខាងលើបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋនៅក្នុងឃុំចុងដូង ក្រៅពីប្រកបរបរធ្វើស្រែជាចម្បង មានប្រជាពលរដ្ឋប្រមាណជិតពាក់កណ្តាល បានខិតខំប្រកមុខរបរបន្ទាប់បន្សំថែមទៀត ដូចជា លក់ដូរ និងជំនួញ ផ្នែកដឹកជញ្ជូន និងកម្មករសំណង់ ។ល។ ចំណែកអ្នក ដែលមានរបរផ្នែកសេវាកម្ម ជាចម្បង ស្ទើរតែទាំងអស់ បានខិតខំប្រកបរបរកសិកម្ម ដែលជាមុខរបរបន្ទាប់បន្សំបន្ថែមទៀតផងដែរ ដូចមានរៀបរាប់ក្នុងតារាងខាងក្រោមនេះ៖

តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ

| បរិយាយ | ២០១៧ | ២០១៧ចំនួន(នាក់) |
|---|---|---|
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ៧៩,១ % | ២៧៧៣ នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ៣៣,៥ % | ១១៧៦ នាក់ |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | ១២,៧ % | ៤៤៦ នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | ៦,២ % | ២១៦ នាក់ |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ៨,២ % | ២៦៤ នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ៣,៤ % | ១២០ នាក់ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

### ង. ចំណូលស្រុក និងចំណាកស្រុក

កត្តាដែលធ្វើឱ្យមានការផ្លាស់ប្តូរលំនៅឋាន គឺដោយសារនៅភូមិចាស់ដែលគាត់បានរស់នៅពិបាកក្នុងការរកស៊ី និងគ្មានការងារធ្វើនៅក្នុងភូមិ ព្រមទាំងមូលហេតុមួយចំនួនទៀត ដូចជា៖ ស្ថានភាពដី នៅក្នុងតំបន់មូលដ្ឋានមួយចំនួនមានការប្រែប្រួលដោយដីខូចងាប់សារជាតុបម្រុង ហើយឡើងខ្សោះ ឬហឹរជាដើម ខ្វះប្រភពទឹក ធ្វើឱ្យទទួលបានទិន្នផលទាប តម្លៃផលិតផលកសិកម្មមិនទៀងទាត់ និងគ្មានទីផ្សារផលិតផល ចំណែកសមាជិកគ្រួសារកើនឡើង និងមួយចំនួនជាប់បំណុលធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម។ល។ ការផ្លាស់ប្តូរលំនៅឋាន ប្រជាជនមួយចំនួនទៅរស់នៅទីប្រជុំជន ឃុំ/សង្កាត់ ស្រុក/ក្រុង រាជធានី/ខេត្ត និងទៅធ្វើការងារនៅប្រទេសផ្សេងៗ។ មូលហេតុចម្បងនៃការធ្វើចំណាកស្រុកគ្រប់ប្រភេទ គឺក្នុងគោលបំណងលើកស្ទួយជីវភាពគ្រួសារ។ យោងតាមទិន្នន័យពីក្រុមប្រឹក្សាឃុំបង្ហាញឱ្យឃើញថា នៅក្នុងឃុំនេះ មានគ្រួសារផ្លាស់លំនៅដ្ឋានចូលចំនួន ០៣ គ្រួសារ មានមនុស្សសរុបចំនួន ១៦នាក់ ក្នុងនោះស្រី ០៩នាក់ ចំណែកគ្រួសារផ្លាស់លំនៅដ្ឋានចេញមានចំនួន ០៧ គ្រួសារ មានមនុស្សសរុប ៣២នាក់ ក្នុងនោះស្រី ១៧នាក់។

តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧

| ល.រ | បរិយាយ | ចំនួនគ្រួសារ | ចំនួនប្រជាជនសរុប | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | ចំនួនគ្រួសារផ្លាស់លំនៅដ្ឋានចូល | ០៣ | ១៦ | ៩ |
| ២ | ចំនួនគ្រួសារផ្លាស់លំនៅដ្ឋានចេញ | ០៧ | ៣២ | ១៧ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

ដោយយោងទៅតាមទិន្នន័យមន្ទីរផែនការខេត្ត ឆ្នាំ២០១៧ បានបង្ហាញថា ប្រជាពលរដ្ឋធ្វើការចំណាកស្រុកមានចំនួនសរុប ៩៣៩ នាក់ មានស្ត្រីចំនួន ៤៨៨ នាក់ នៅក្នុងនោះប្រជាជនដែលធ្វើការចំណាកស្រុកក្នុងប្រទេសមានចំនួន ៧៩៣ នាក់ មានស្ត្រីចំនួន ៤២៧ នាក់ គឺជាចំណាកស្រុកមិនអចិន្ត្រៃយ៍នោះទេ ពួកគាត់ទៅធ្វើការនៅ ស្រុក ខេត្តផ្សេង ឬរាជធានីភ្នំពេញតែមួយរយៈប៉ុណ្ណោះ ហើយពួកគាត់នឹងត្រលប់មកស្រុកជារឿយៗ ចំណែក ចំណាកស្រុកទៅក្រៅប្រទេសមានចំនួន ១៤៦នាក់ ស្រីចំនួន ៦១នាក់ ពួកគាត់ទៅប្រទេសថៃ ម៉ាឡេស៊ី ជប៉ុន និងប្រទេសកូរ៉េជាដើម ដោយពួកគាត់ទៅធ្វើការនៅទីនោះ តែមួយរយៈប៉ុណ្ណោះ និងត្រលប់មកកាន់ស្រុកកំណើតវិញបន្ទាប់ពីចប់កុងត្រាការងារ។

ប្រជាជនធ្វើចំណាកស្រុកចេញទៅរកស៊ីនៅស្រុក និងខេត្តផ្សេងៗ ឬទៅប្រទេសជិតខាង ដោយសារកត្តាមួយចំនួនដូចខាងក្រោមៈ

- ដីបង្កបង្កើនផលសម្រាប់វិស័យកសិកម្មតិចតួច ធ្វើស្រែបានផលតិច
- ការធ្វើស្រែចម្ការបានតែមួយរដូវ និងគ្មានទីផ្សារគ្រប់គ្រាន់សម្រាប់លក់ផលិតផល
- មិនមានការងារគ្រប់គ្រាន់នៅក្នុងស្រុក
- ជំពាក់បំណុលធនាគារ ឬឯកជនមិនមានលទ្ធភាពសង
- គ្មានមុខរបរច្បាស់លាស់ និងមានប្រាក់ចំណូលប្រចាំថ្ងៃទាប។
- កំណើនសមាជិកគ្រួសារមានការកើនឡើង។
- ដោយធ្វើស្រែប្រើឧបករណ៍ពាក់កណ្តាលស្វ័យប្រវត្តិធ្វើឱ្យកម្លាំងពលកម្មថយចុះ។
- គ្រួសារមានដីតិចតួច មិនគ្រប់គ្រាន់ក្នុងការចិញ្ចឹមគ្រួសារ បន្ទាប់មកលក់ចេញទៅស្រុកផ្សេង។

តារាង ៨៖ ស្ថិតិប្រជាជនចំណាកស្រុក

| បរិយាយ | ២០១៦ | | | ២០១៧ | | |
|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេស | ៧៩៥ | ៣៧៣ | ៤២២ | ៧៩៣ | ៣៦៦ | ៤២៧ |
| ចំនួនអ្នកធ្វើចំណាកស្រុកក្រៅប្រទេស | ១៩៦ | ១១៩ | ៧៧ | ១៤៦ | ៨៥ | ៦១ |
| **សរុប** | **៩៩១** | **៤៩២** | **៤៩៩** | **៩៣៩** | **៤៥១** | **៤៨៨** |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

### ១.១.៣. ស្ថានភាពសេដ្ឋកិច្ច

#### ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ

បើយោងតាមរបាយការណ៍ ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំចុងដូង នៅត្រង់ចំណុចនៃការវិភាគចំណាត់ថ្នាក់ទ្រព្យធនបានឱ្យដឹងថា គ្រួសារ ដែលមានជីវភាពគ្រាន់បើ និងគ្រួសារមានជីវភាពមធ្យម មានប្រភពចំណូលទី១ គឺអាជីវកម្មកែច្នៃគ្រឿងសង្ហារឹម ប្រភពចំណូលទី២ គឺជំនួញគ្រឿងសង្ហារឹម និងប្រភពចំណូលទី៣ គឺលក់ស្រូវ។ គ្រួសារមានជីវភាពក្រ មានប្រភពចំណូលទី១ គឺលក់កម្លាំងពលកម្ម ប្រភពចំណូលទី២ គឺនេសាទត្រី និងប្រភពចំណូលទី៣ គឺកម្មករសំណង់ និងគ្រួសារក្រណាស់ មានប្រភពចំណូលទី១ គឺលក់កម្លាំងពលកម្ម និងប្រភពចំណូលទី២ គឺនេសាទត្រី។

## ខ. កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ

បើយោងទៅតាមតារាងចំណាត់ថ្នាក់ទ្រព្យធន នៅក្នុងឆ្នាំ២០១៧ ដែលទទួលបានពីរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកៀ្រត្រ-បរិស្ថានខាងលើ បានបង្ហាញឱ្យឃើញថា ក្នុងឆ្នាំ២០១៧ ប្រជាពលរដ្ឋក្នុងឃុំចុងដូងមានកម្រិតជីវភាពរស់នៅ ដោយចែកចេញជាបួនកម្រិត គឺ១)គ្រួសារបង្គួរ/គ្រាន់បើ មានចំនួន ៥ភាគរយ ដែលជាគ្រួសារ មានកម្រិតជីវភាពធូរធាជាងគេនៅក្នុងឃុំ មានដីកាន់កាប់ចំនួន ០៦ ហិកតា ២)គ្រួសារមធ្យមមានចំនួន ៨៦ ភាគរយ ជាចំនួនច្រើនជាងគេ (លើសពាក់កណ្តាល) មានដីកាន់កាប់ពី ០៥ ហិកតា ៣) គ្រួសារក្រមានចំនួន ០៦ ភាគរយ មានដីកាន់កាប់ពី ០១ ហិកតា និង ៤)គ្រួសារក្រណាស់ ជាគ្រួសារក្រីក្របំផុត និងមានចំនួនតិចជាងគេត្រឹមតែ ០៣ ភាគរយ មានដីកាន់កាប់ ០១ ហិកតា ចុះក្រោមរហូតដល់អ្នកគ្មានដី ។

បើយោងទៅតាមការសាកសួរជាមួយនឹងក្រុមប្រឹក្សាឃុំចុងដូង បានបង្ហាញឱ្យឃើញថា ចំណូលប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជាមធ្យម ១០ ០០០-១៥ ០០០ រៀល/គ្រួសារ ដូច្នេះចំណូលប្រចាំឆ្នាំចាប់ពី ៣ ៦៥០ ០០០- ៥ ៤៧៥ ០០០ រៀល/គ្រួសារ ចំណែកការចំណាយប្រចាំឆ្នាំវិញដូចជា ស្បៀងអាហារ សម្លៀកបំពាក់ ឧបករណ៍ប្រើប្រាស់ សម្ភារៈសិក្សា និងថ្នាំសង្កូវ ព្រមទាំងការចំណាយផ្សេងៗចាប់ពី ២ ៩២០ ០០០- ៤ ៣៨០ ០០០ រៀល/គ្រួសារ ។

តារាង ១៖ តារាងកម្រិតជីវភាពរបស់ប្រជាជន

| ចំណាត់ថ្នាក់ធនធាន | បង្គួរ/គ្រាន់បើ | មធ្យម | ក្រ | ក្រណាស់/គ្មានដី | សរុប |
|---|---|---|---|---|---|
| **ប្រៀបធៀបជា(%)តំបន់ I** | | | | | |
| -ភូមិទួលដំណាក់ ៦៦៨គ្រួសារ | ៦% | ៩០% | ៤% | ១% | ១០០% |
| -ភូមិសំរោង ២៨០គ្រួសារ | ៤% | ៩១% | ១% | ៤% | ១០០% |
| -ភូមិខ្សាច់ល្អិត ៤៨០គ្រួសារ | ៤% | ៨៣% | ១០% | ៣% | ១០០% |
| -ភូមិគួរ ៣៧៣គ្រួសារ | ៥% | ៧៩% | ១៣% | ៣% | ១០០% |
| -ភូមិទួលសាលា២២៤គ្រួសារ | ៥% | ៨៩% | ៥% | ១% | ១០០% |
| -ភូមិកំប៉ើយ ១៧២គ្រួសារ | ៨% | ៨១% | ៧% | ៤% | ១០០% |
| -ភូមិពេជ ៣៩៣គ្រួសារ | ៣% | ៨៨% | ៦% | ៣% | ១០០% |
| -ភូមិចុងដូង ៣៣១គ្រួសារ | ១០% | ៨៣% | ២% | ៥% | ១០០% |
| **តំបន់ II** (០គ្រួសារ) | | | | | |
| **តំបន់ III** (០គ្រួសារ) | | | | | |
| **ទូទាំងឃុំ (២៩,២១គ្រួសារ)** | **៥%** | **៨៦%** | **៦%** | **៣%** | **១០០%** |
| ទំហំគ្រួសារ | ៤ | ៤ | ៦ | ៧ | |
| កំលាំងពលកម្ម | ៤ | ៣ | ៣ | ២ | |
| ទំហំដីកាន់កាប់សរុប(ហត) | ២ | ១ | 0,0៥ | 0,0២0 | |
| ចំនួន និងប្រភេទក្បាលដី | ៦ | ៥ | ១ | ១ | |
| ដីលំនៅដ្ឋាន(ហត) | 0,១0 | 0,0៦ | 0,0៥ | 0,២0 | |
| ដីលំនៅដ្ឋាន(ហត) | 0,១0 | 0 | 0 | 0 | |
| ដីស្រែ(ហត) | 0,៥ | 0,២៥ | 0 | 0 | |
| ដីផ្សេងៗទី1(ហត) | 0,៤ | 0,២៥ | 0 | 0 | |

| | | | | | |
|---|---|---|---|---|---|
| ដីផ្សេងៗទី2(ហត) | 0,៥ | 0,២៥ | 0 | 0 | |
| ដីផ្សេងៗទី3(ហត) | 0,៤ | 0,0៩ | 0 | 0 | |
| ដំណាំទី1៖ ស្រូវ (ហត) | 0,៥ | 0,២៥ | 0 | 0 | |
| ដំណាំទី2៖ ឪឡឹក (ហត) ដាំលើដីស្រែ | 0,៥ | 0,២៥ | 0 | 0 | |
| ដំណាំទី3៖ដំឡូងមី(ហត) | 0,៤ | 0,0៩ | 0 | 0 | |
| ការចិញ្ចឹមត្រី | គ្មាន | គ្មាន | គ្មាន | គ្មាន | |
| ចំនួនគោ | ៣ | ២ | ១ | 0 | |
| ចំនួនក្របី | គ្មាន | គ្មាន | គ្មាន | គ្មាន | |
| ចំនួនជ្រូក | គ្មាន | គ្មាន | គ្មាន | គ្មាន | |
| ការប្រើប្រាស់ឧបករណ៍នេសាទ | គ្មាន | -សំណាញ់<br>-ម៉ង<br>-ចងសន្ទូច | -សំណាញ់<br>-ម៉ង<br>-ចងសន្ទូច | -សំណាញ់<br>-ម៉ង<br>-ចងសន្ទូច | |
| ប្រភពចំណូលទី1៖ | អាជីវកម្មកែច្នៃគ្រឿងសង្ហារឹម | អាជីវកម្មកែច្នៃគ្រឿងសង្ហារឹម | លក់កម្លាំងពលកម្ម | លក់កម្លាំងពលកម្ម | |
| ប្រភពចំណូលទី2៖ | ជំនួញគ្រឿងសង្ហារឹម | ជំនួញគ្រឿងសង្ហារឹម | នេសាទត្រី | នេសាទត្រី | |
| ប្រភពចំណូលទី3៖ | លក់ស្រូវ | លក់ស្រូវ | កម្មករសំណង់ | គ្មាន | |
| ការងារក្រៅពីកសិកម្ម (ប្រភេទពលកម្ម) | សិប្បកម្មកែច្នៃ | កម្មករសំណង់ | កម្មករសំណង់ | កម្មករសំណង់ | |
| ការប្រើប្រាស់ឥណទាន | ខ្ចីប្រាក់ពីធនាគារ | ខ្ចីប្រាក់ឯកជន | ខ្ចីប្រាក់ពីធនាគារ | គ្មាន | |

ប្រភព៖ *របាយការណ៍វិភាគប្រព័ន្ធគ្រួសារ-បរិស្ថានឃុំចុងដូងឆ្នាំ២០១៧*

### គ. ស្ថានភាពចំណូលសរុប និងអត្រាការប្រាក់

ប្រជាពលរដ្ឋនៅក្នុងឃុំចុងដូង មានចំនួន ១ ៥១0 គ្រួសារ ស្មើនឹងប្រមាណ ៥0 ភាគរយ ដែលជាប់បំណុលនៅមីក្រូហិរញ្ញវត្ថុ និងធនាគារ ដូចមានរាយខាងក្រោម៖

- អ្នកមានជីវភាពបង្គួរ៖ មានលទ្ធភាពអាចខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរ ដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពមធ្យម៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរ ដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពខ្សត់ខ្សោយក្រ៖ ពុំមានលទ្ធភាពខ្ចីប្រាក់ពីធនាគារ ឬមីក្រូហិរញ្ញវត្ថុឯកជនទេ ដោយសារគ្មានទ្រព្យបញ្ចាំ តែត្រូវខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យម។
- ចំណែកអ្នកក្របំផុត៖ ប្រកបរបរដោយលក់កម្លាំងពលកម្ម និងធ្វើចំណាកស្រុក។

នៅក្នុងឃុំចុងដូង មិនមានទីតាំងមីក្រូហិរញ្ញវត្ថុ និងធនាគារនោះទេ ប៉ុន្តែមានស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារជាច្រើន ដែលបានផ្តល់សេវា និងបញ្ចេញប្រាក់កម្ចីជូនប្រជាពលរដ្ឋនៅក្នុងឃុំ នៅក្នុងនោះមានដូចជា៖ ធនាគារអេស៊ីលីដា ធនាគារស្ថាបនា មីក្រូហិរញ្ញវត្ថុ អម្រឹត មីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ មីក្រូហិរញ្ញវត្ថុ ប្រាសាក់ មីក្រូហិរញ្ញវត្ថុ អេ អឹម ខេ មីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់ មីក្រូហិរញ្ញវត្ថុ ក្រេឌីត មីក្រូហិរញ្ញវត្ថុ សហគ្រិន មីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី មីក្រូហិរញ្ញវត្ថុ គ្រួសារ មីក្រូហិរញ្ញវត្ថុ ប្រៃសណីយ៍ និងសហគមន៍ចងការប្រាក់(៦ភូមិ) ដែលមានអត្រាការប្រាក់ គឺអាស្រ័យទៅលើចំនួនទឹកប្រាក់ដែលខ្ចី បើចំនួនទឹកប្រាក់ខ្ចីកាន់តែច្រើន អត្រាការប្រាក់កាន់តែតិច ០,៩៩ភាគរយ ហើយបើចំនួនទឹកប្រាក់កាន់តែតិច អត្រាការប្រាក់កាន់តែច្រើន ១,៨ ភាគរយ។ ចំណែកអ្នកខ្សត់ខ្សោយដែលខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យមមានអត្រាការប្រាក់ខ្ពស់គឺចាប់ពី ១,៥ភាគរយ ទៅ ១០ភាគរយ ។

### ឃ. ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬ ក្រោមរូបភាពផ្សេងៗ

ជាទូទៅប្រជាពលរដ្ឋនៅក្នុងឃុំចុងដូង បានប្រើប្រាស់មីក្រូឥណទាន ជាសាច់ប្រាក់សុទ្ធ គឺដើម្បីយកទៅពង្រីកមុខរបរ ចងការបន្ត ទិញសម្ភារៈកសិកម្ម ទិញជី និងប្រើប្រាស់ទៅតាមតម្រូវការចាំបាច់ផ្សេងៗទៀត ក៏នៅមានក្រោមរូបភាព ដែលប្រជាពលរដ្ឋមួយចំនួនទៅទទួលយកជីដាក់ស្រូវមុន និងសន្យាសងប្រាក់នៅពេលប្រមូលផលស្រូវផងដែរ។

### ង. ចំណូលពីប្រភពផ្សេងៗ

ប្រជាពលរដ្ឋនៅក្នុងឃុំចុងដូង ពួកគាត់អាចទទួលបាននូវប្រភពចំណូលពីប្រភពផ្សេងៗដូចជា៖

- ចំណាកស្រុកក្រៅប្រទេស(ពលករផ្នែក កសិកម្ម ឧស្សាហកម្ម) ដូចជាប្រទេសថៃ កូរ៉េជាដើម
- និងចំណូលមួយចំនួនតូចទៀត គឺបានមកពីគ្រួសារ ឬបងប្អូនរស់នៅជាអចិន្ត្រៃយ៍នៅបរទេស ដែលពួកគាត់បានផ្ញើមកដើម្បីផ្គត់ផ្គង់គ្រួសារនៅស្រុកខ្មែរ។

## ១.១.៤. ស្ថានភាពសិក្សាធិការ

### ក. ស្ថានភាពអប់រំ

យោងតាមផែនការអភិវឌ្ឍន៍ឃុំចុងដូង៥ឆ្នាំ (២០១៧-២០២២) បានឱ្យដឹងថា ជារៀងរាល់ឆ្នាំកុមារាកុមារីគ្រប់អាយុចូលរៀន បានចុះឈ្មោះចូលរៀនគ្រប់គ្នា ទោះបីជាកុមារស្ថិតនៅក្នុងស្ថានភាពគ្រួសារក្រីក្រ គ្រួសារដែលជាស្ត្រីមេម៉ាយ ឬក្មេងកំព្រា កុមារពិការក៏ដោយក្តី។ មកដល់ពេលបច្ចុប្បន្ន វិស័យអប់រំនៅក្នុងឃុំចុងដូង មានការរីកចម្រើនជាងមុនដូចជា៖ អគារសិក្សាត្រូវបានសាងសង់ថ្មីៗ និងមានការកែលម្អបន្ទប់រៀនថែមទៀត នៅតាមសាលារៀនគ្រប់កម្រិត ដែលផ្តល់លទ្ធភាពឱ្យសិស្សបានរៀនសូត្រគ្រប់ពេល ពុំមានការខ្វះខាតឡើយ ។ ចំណុចអវិជ្ជមានក៏មាននៅក្នុងឃុំផងដែរដូចជា៖ ខ្វះគ្រូបង្រៀន មិនទាន់មានសាលាមត្តេយ្យសហគមន៍គ្រប់គ្រាន់នៅតាមភូមិនៅឡើយ មានអ្នកមិនចេះអក្សរ(អនក្ខរជន) ជាពិសេសមនុស្សវ័យចំណាស់ពួកគាត់ពុំសូវមានស្មារតីសិក្សារៀនសូត្រ ទោះបីមានការយកចិត្តទុកដាក់ជម្រុញលើកទឹកចិត្តពីអាជ្ញាធរមូលដ្ឋានយ៉ាងណាក៏ដោយ ។

រូបភាព 1៖ សាលារៀន

|  |  |
|---|---|
| សាលាបឋមសិក្សាក្នុងឃុំចុងដូង | សាលាអនុវិទ្យាល័យក្នុងឃុំចុងដូង |

នៅក្នុងឃុំចុងដូង មានកម្រិតសិក្សាចាប់ពីមត្តេយ្យសិក្សារហូតដល់អនុវិទ្យាល័យ ចំណែកវិទ្យាល័យវិញមិនទាន់មាននោះទេ មាននៅតែខាងក្រៅឃុំ ។ សាលាមត្តេយ្យសិក្សា មានចំនួន ០២ កន្លែង ០២បន្ទប់ ០២ ថ្នាក់ គ្រូបង្រៀនមានចំនួន ០២ នាក់ ជាស្ត្រី ហើយសិស្សកំពុងរៀន មានចំនួន ៤៥ នាក់ ក្នុងនោះមានស្រី ២៩នាក់។ សាលាបឋមសិក្សា មានចំនួន ០៧ កន្លែង ៥៧ន្ទប់ ៤៥ថ្នាក់ គ្រូបង្រៀនចំនួន ៤០ នាក់ ក្នុងនោះជាស្ត្រី ១៩ នាក់ ហើយសិស្សដែលកំពុងរៀនមានចំនួន ១ ៦២៦ នាក់ មានស្រីចំនួន ៧៨៩ នាក់ ចំណែកឯសាលាអនុវិទ្យាល័យវិញ មានចំនួន ០១ កន្លែង ១១ បន្ទប់ ០៩ ថ្នាក់ គ្រូបង្រៀនមានចំនួន ២១ នាក់ ក្នុងនោះស្ត្រី ១០ នាក់ និងសិស្សដែលកំពុងរៀន មានចំនួន ៥៤៥ នាក់ នៅក្នុងនោះស្រីចំនួន ២៨៤ នាក់ ។

តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧

| ស្ថានភាពសាលា | ចំនួនសាលារៀន | | | ចំនួនសិស្ស | | គ្រូបង្រៀន | |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | សរុប | ស្រី | សរុប | ស្រី |
| ១.សាលាមត្តេយ្យ | ០២ | ០២ | ០២ | ៤៥ | ២៩ | ២ | ០២ |
| ២.សាលាបឋមសិក្សា | ០៧ | ៥៧ | ៤៥ | ១៦២៦ | ៧៨៩ | ៤០ | ១៩ |
| ៣.អនុវិទ្យាល័យ | ០១ | ១១ | ០៩ | ៥៤៥ | ២៨៤ | ២១ | ១០ |
| ៤.វិទ្យាល័យ | 0 | 0 | 0 | 0 | 0 | 0 | 0 |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

### ខ. ស្ថានភាពអក្ខរកម្ម

នៅក្នុងឃុំចុងដូង មានមនុស្សអាយុពី ១៥-៤៥ឆ្នាំ មានចំនួន ៦០២០នាក់ នៅក្នុងនោះ អ្នកមិនចេះអក្សរស្មើនឹង ៧,៧ ភាគរយ បើគិតទៅតាមក្រុមអាយុវិញយើងឃើញថា អ្នកមិនចេះអក្សរមានអាយុពី ១៥-២៥ ឆ្នាំ ចំនួន ៨៧ នាក់ ស្មើនឹង ៣,៨ ភាគរយ អាយុពី ២៥-៤៥ ឆ្នាំ មានចំនួន ៣៧៥ នាក់ ស្មើនឹង ១០,១ ភាគរយ។

ប្រជាពលរដ្ឋភាគច្រើនដែលមិនចេះអក្សរ គឺដោយសារមិនបានចូលរៀន មូលហេតុដោយសារសាលារៀននៅឆ្ងាយពីភូមិ ឃុំ ប្រជាពលរដ្ឋនៅតែមានកង្វះខាតមធ្យោបាយធ្វើដំណើរទៅសាលារៀន ខ្វះថវិកាសម្រាប់ទិញសម្ភារៈសិក្សាសម្លៀកបំពាក់ និងផ្នត់គំនិតរបស់ឪពុកម្តាយចាស់គំរឹល ឬមិនជឿនលឿន។ ទោះបីយ៉ាងនោះក្តី នៅ

ក្នុងឃុំនៅមានថ្នាក់អក្ខរកម្មជាប្រចាំ តែពួកគាត់ពុំទាន់មានពេលចូលសិក្សា ព្រោះជាប់រវល់ប្រកបរបរចិញ្ចឹមជីវិត ជាហេតុនាំមកនូវការភ្លេចអក្សរ នៅក្នុងចំណោមអ្នកដែលបានចូលមកសិក្សាក្នុងថ្នាក់អក្ខរកម្មកន្លងមក ។

**- អនុវិស័យអប់រំក្រៅប្រព័ន្ធ**

ក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយ បានពង្រឹងតាមរយៈការពិនិត្យឡើងវិញ នូវគោលនយោបាយអប់រំក្រៅប្រព័ន្ធ ការបង្កើតអនុក្រុមការងារអប់រំក្រៅប្រព័ន្ធ និងមានភារកិច្ចច្បាស់លាស់ ការវាយតម្លៃសមត្ថភាពអប់រំក្រៅប្រព័ន្ធ និងការកសាងផែនទី ក៏ដូចជាការពិនិត្យឡើងវិញនូវកម្មវិធីចូលរៀនឡើងវិញ ព្រមទាំងការរៀបចំសេចក្តីណែនាំស្តីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ និងកម្មវិធីសមមូល។ ដើម្បីធ្វើការជម្រុញឱ្យផែនការយុទ្ធសាស្រ្តអនុវិស័យអប់រំក្រៅប្រព័ន្ធបានទទួលជោគជ័យ ត្រូវបន្តអនុវត្តសកម្មភាពដូចខាងក្រោម៖

១. បន្តពង្រឹងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងមណ្ឌលអានដែលមានស្រាប់

២. បន្តពង្រឹងការអនុវត្តកម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សា

៣. អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ

៤. បន្តអនុវត្តការងារអក្ខរកម្មតាមការជាក់ស្តែង

៥. បន្តអនុវត្តកម្មវិធីចូលរៀនឡើងវិញ។

តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ

| បរិយាយ | ២០១៦ | ២០១៧ |
|---|---|---|
| ចំនួនអ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ១២៧ | ៨៧ |
| %អ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ៥,៥ | ៣,៨ |
| ចំនួនអ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ៣៦៤ | ៣៧៥ |
| %អ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ១០,២ | ១០,១ |
| សរុបមនុស្សអាយុ១៥-៤៥ឆ្នាំ | ៥៨៩៧ | ៦០២០ |
| %អ្នកមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ | ៨,៣ | ៧,៧ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

## គ.ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

បើយោងទៅតាមប្រភពទិន្នន័យពីមន្ទីរផែនការខេត្តឆ្នាំ ២០១៧ បានបង្ហាញឱ្យឃើញថា លទ្ធភាពក្នុងការបន្តការសិក្សារបស់សិស្សនៅក្នុងឃុំចុងដូង ទៅថ្នាក់ខ្ពស់ទៀតមានដូចខាងក្រោម៖

- អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ២៧៥ នាក់ ស្រីមានចំនួន ១៤២ នាក់
- អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ៣១៣ នាក់ ស្រីមានចំនួន ១៦៥ នាក់
- អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ២៩៤ នាក់ ស្រីមានចំនួន ១៣៣ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ២៦០ នាក់ ស្រីមានចំនួន ១១៣ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ២៩៤ នាក់ ស្រីមានចំនួន ១៧៩ នាក់។
- អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ១៦១ នាក់ ស្រីចំនួន ៨២ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសរុបចំនួន ១៥៣ នាក់ ស្រីចំនួន ៩៦ នាក់
- អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសរុបចំនួន ៩៩ នាក់ ស្រីចំនួន ៦០ នាក់

តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

| ការអប់រំតាមក្រុមអាយុ | សរុប | ស្រី |
|---|---|---|
| អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យ | ២៧៥ | ១៤២ |
| អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យ | ៣១៣ | ១៦៥ |
| អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យ | ២៩៤ | ១៣៣ |
| អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យ | ២៦០ | ១១៣ |
| អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យ | ២៩៤ | ១៧៩ |
| អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យ | ១៦១ | ៨២ |
| អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៥៣ | ៩៦ |
| អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ៩៩ | ៦០ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

### ១.១.៩.ស្ថានភាពសុខាភិបាល

មណ្ឌលសុខភាព គឺជាកន្លែងផ្តល់សេវាអប់រំសុខភាព ថែទាំ និងព្យាបាលអ្នកជម្ងឺផ្សេងៗ ដែលជាកន្លែងសាធារណៈរបស់រដ្ឋ។ ឃុំចុងដូង មានមណ្ឌលសុខភាព ចំនួន ០១ កន្លែង ដែលស្ថិតនៅភូមិទួលដំណាក់ និងមានចម្ងាយប្រហែល ២០០ ម៉ែត្រ ពីសាលាឃុំចុងដូង ដែលមានគ្រូពេទ្យចំនួន ០៥ នាក់ ក្នុងនោះឆ្មបចំនួន០៣ នាក់។ ប្រភេទជម្ងឺ ដែលកាចសាហាវ ឬជម្ងឺឆ្លងដែលកើតញឹកញាប់ គឺជម្ងឺរលាកផ្លូវដង្ហើម ទឹកនោមផ្អែម លើសឈាម ឡើងជាតិអាស៊ីត ។ ស្ថានភាពមាតា និងទារកនៅក្នុងឃុំចុងដូង មានស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង ០១ឆ្នាំកន្លងទៅចំនួន ១០ នាក់ ស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង១ឆ្នាំកន្លងទៅ មានចំនួន១៦៤ នាក់ ទារកដែលបានកើតរស់ដោយឆ្មបពេទ្យមានចំនួន ១៦៤ នាក់ មរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែ ដោយឆ្មបបុរាណមិនមាននោះទេ មរណភាពមាតាបន្ទាប់ពីសម្រាលកូននៅក្នុងចន្លោះ ០-១ ខែ ដោយឆ្មបពេទ្យមិនមានទេ មរណភាពទារកក្នុងចន្លោះអាយុ ០-១ ខែ ដោយឆ្មបបុរាណមិនមានទេ មរណភាពទារកក្នុងចន្លោះអាយុ ០-១ ខែ ដោយឆ្មបពេទ្យមិនមានទេ ទារកដែលបានចុះសំបុត្រកំណើតមានចំនួន១៥០នាក់ កុមារដែលមានអាយុចន្លោះពី ៩-១២ ខែ មានចំនួន ១៥០ នាក់ កុមារដែលមានអាយុចន្លោះពី ៩-១២ ខែ បានចាក់ថ្នាំបង្ការគ្រប់ចំនួន ១៤៧ នាក់ ហើយសម្រាប់ការចាក់ថ្នាំបង្ការជម្ងឺផ្សេងៗនេះ ធ្វើនៅមណ្ឌលសុខភាព និងតាមភូមិជូនប្រជាពលរដ្ឋ ដែលមានជម្ងឺមួយចំនួនដូចជា៖ ជម្ងឺកញ្ជ្រិល ស្វិតដៃជើង ក្អកមាន់ របេងតេតាណូស រលាកថ្លើមប្រភេទបេ ផ្តាសាយបក្សី គ្រុនចាញ់ រាករូស និងគ្រុនឈាម។ ករណីជម្ងឺធ្ងន់ធ្ងរការបញ្ជូនអ្នកជម្ងឺដោយមធ្យោបាយខ្លួនឯងផ្ទាល់ មកមណ្ឌលសុខភាព ព្រោះមណ្ឌល សុខភាពស្ថិតនៅជិតពួកគាត់ ឯការបញ្ជូនទៅមន្ទីរពេទ្យបង្អែកដោយមធ្យោបាយផ្ទាល់ខ្លួន និង រថយន្តសង្គ្រោះរបស់ពេទ្យបង្អែក ទាំងការចំណាយផ្សេងៗជាបន្ទុករបស់អ្នកជម្ងឺក្នុងករណីអ្នកជម្ងឺមិនមានប័ណ្ណក្រីក្រ។

តារាង 13៖ សុខភាពមាតា និងទារក

| ល.រ | សុខភាពមាតានិងទារក | ឆ្នាំ២០១៧ |
|---|---|---|
| ១ | ចំនួនបុគ្គលិកពេទ្យនៅមណ្ឌលសុខភាព | ៥ នាក់ |
| ២ | ចំនួនពេទ្យឆ្មបនៅមណ្ឌលសុខភាព | ៣ នាក់ |

| | | |
|---|---|---|
| ៣ | ចំនួនឆ្មបបុរាណនៅមណ្ឌលសុខភាព | 0 |
| ៤ | ចំនួនបន្ទប់នៅមណ្ឌលសុខភាព | ៧ បន្ទប់ |
| ៥ | ចំនួនគ្រែនៅមណ្ឌលសុខភាព | ៥ គ្រែ |
| ៦ | ចំនួនឆ្មបដែលបានបណ្តុះបណ្តាលមានក្នុងភូមិ | ២ នាក់ |
| ៧ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅ | ១០ នាក់ |
| ៨ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង ១ឆ្នាំកន្លងទៅ | ១៦៤ នាក់ |
| ៩ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបបុរាណ | ១០ នាក់ |
| ១០ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបពេទ្យ | ១៦៤ នាក់ |
| ១១ | ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ 0-១ខែដោយឆ្មបបុរាណ | 0 |
| ១២ | ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ 0-១ខែដោយឆ្មបពេទ្យ | 0 |
| ១៣ | ចំនួនមរណភាពទារកក្នុងចន្លោះអាយុ 0-១ខែដោយឆ្មបបុរាណ | 0 |
| ១៤ | ចំនួនមរណភាពទារកក្នុងចន្លោះអាយុ 0-១ខែដោយឆ្មបពេទ្យ | 0 |
| ១៥ | ចំនួនទារកដែលបានចុះសំបុត្រកំណើត | ១៥0 នាក់ |
| ១៦ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែ | ១៥0 នាក់ |
| ១៧ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | ១៤៧ នាក់ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

រូបភាព 2៖ មណ្ឌលសុខភាពនៅក្នុងឃុំចុងដូង



យោងតាមទិន្នន័យពីមន្ទីរផែនការខេត្ត នៅក្នុងឆ្នាំ ២០១៧ បានឱ្យដឹងថា ចម្ងាយពីភូមិនីមួយៗទៅកាន់មណ្ឌលសុខភាព មិនឆ្ងាយណាស់ណានោះទេ គឺឆ្ងាយបំផុតត្រឹមពី 0-៧គីឡូម៉ែត្រ ប៉ុណ្ណោះ ដូចមានក្នុងតារាង

សង្ខេបខាងក្រោម ។ ចំណែកស្ថានភាពផ្លូវទៅកាន់មណ្ឌលសុខភាពវិញ ក៏មិនពិបាកក្នុងការធ្វើដំណើរដែរ ដែលអំណោយផលដល់ការបញ្ជូនអ្នកជម្ងឺទៅកាន់មណ្ឌលសុខភាពបានទាន់ពេលវេលា ។

តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព

| ល.រ | ឈ្មោះភូមិ | ចម្ងាយជាមធ្យម ពីភូមិទៅមណ្ឌលសុខភាព | ផ្សេងៗ |
|---|---|---|---|
| ១ | ទួលដំណាក់ | 0 គីឡូម៉ែត្រ | |
| ២ | សំរោង | ៧ គីឡូម៉ែត្រ | |
| ៣ | ខ្សាច់ល្អិត | ៣ គីឡូម៉ែត្រ | |
| ៤ | គួរ | ៥,៥ គីឡូម៉ែត្រ | |
| ៥ | ទួលសាលា | ៣ គីឡូម៉ែត្រ | |
| ៦ | កំប៉ើយ | ៤,៣ គីឡូម៉ែត្រ | |
| ៧ | ពពេជ | ៣ គីឡូម៉ែត្រ | |
| ៨ | ចុងដូង | ២ គីឡូម៉ែត្រ | |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព




*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

### ១.១.៦. ស្ថានភាពយេនឌ័រ

តាមផែនការអភិវឌ្ឍន៍ឃុំចុងដូងរយៈពេល ៥ឆ្នាំ (២០១៨-២០២២) បានឱ្យដឹងថា សមភាពការងាររបស់ស្ត្រី និងបុរសក្នុងឃុំចុងដូងនាពេលបច្ចុប្បន្នគ្មានការរើសអើង ឬគាបសង្កត់ទៅលើស្ត្រីនោះទេ ។ ផ្ទុយទៅវិញ ការងារយេនឌ័រកំពុងតែមានការគាំទ្រយ៉ាងពេញទំហឹង ជាក់ស្តែងក្នុងការងារមានថ្នាក់ដឹកនាំជាស្ត្រី នៅថ្នាក់ភូមិ និងនៅថ្នាក់ឃុំកំពុងតែត្រូវបានលើកកម្ពស់ និងលើកទឹកចិត្តស្ត្រីឱ្យមានការចូលរួមយ៉ាងសកម្មក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំ ក៏ដូចជាផែនការវិនិយោគផងដែរ ។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមនៅតែកើតមានឡើងលើសមត្ថភាពស្ត្រី ដោយសារស្ត្រីមួយចំនួនមានកម្រិតជីវភាពក្រីក្រ ខ្លះត្រូវបោះបង់ការសិក្សាដើម្បីរកចំណូលមកទ្រទ្រង់ជីវភាពនៅក្នុងគ្រួសារនិងអ្នកខ្លះចំណាកស្រុកទៅភ្នំពេញដើម្បីធ្វើកម្មកររោងចក្រ។ ដើម្បីដោះស្រាយបញ្ហានេះក្រុមប្រឹក្សាឃុំ បានសហការជាមួយមន្ទីរការិយាល័យជំនាញៗ និងដៃគូអភិវឌ្ឍនានាជុំវិញ និងលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលបច្ចេកទេសនានានិងជំនាញវិជ្ជាជីវៈបង្កើនមុខរបរថ្មីៗដើម្បីបង្កើននូវប្រាក់ចំណូល

និងកាត់បន្ថយនូវការចំណាកស្រុក ។ ប៉ុន្តែបើយោងតាមរយៈរបាយការណ៍ នៃការវិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថានឃុំចុងដូង ឆ្នាំ២០១៧ បានឱ្យដឹងអំពីតួនាទីយេនឌ័រក្នុងការចូលរួមសកម្មភាពការងារផលិតកម្មកសិកម្ម និងការងារទូទៅក្នុងជីវភាពគ្រួសាររបស់កសិករក្នុងឃុំចុងដូង មានលម្អិតក្នុងតារាងខាងក្រោម ។

តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំចុងដូង

| សកម្មភាព | បុរស | ស្ត្រី | យោបល់បន្ថែម |
|---|---|---|---|
| **ស្រូវវស្សា និង ស្រូវប្រាំង** | | | |
| -ការរៀបចំដីលើកទី១ | ៨0% | ២0% | បុរសធ្វើស្រែចម្ការច្រើនជាងស្ត្រី |
| -ការរៀបចំដីលើកទី២ | ៨0% | ២0% | ស្ត្រីរវល់ការងារផ្ទះច្រើនជាងបុរស |
| -ការត្រាំពូជ | ៥0% | ៥0% | បុរសអ្នកលីគ្រាប់ពូជ ស្ត្រីជាអ្នករៀបចំត្រាំ |
| -ព្រួស | ៨0% | ២0% | ស្ត្រីអាចជួយព្រួសបានមួយចំនួន |
| -ការដាក់ជីបំប៉ន | ៨0% | ២0% | ស្ត្រីជួយជញ្ជូនជីបានខ្លះ |
| -គ្រប់គ្រងទឹកស្រែ | ៥0% | ៥0% | បុរស និងស្ត្រីធ្វើការរួមគ្នា |
| -ការបាញ់ថ្នាំសំលាប់ស្មៅ | ៧0% | ៣0% | ស្ត្រីជួយទិញថ្នាំ |
| -ការច្រូតកាត់ | ៥0% | ៥0% | ស្ត្រីជួយរៀបចំបាយទឹក(ប្រើប្រាស់ម៉ាស៊ីនច្រូត ស្មើ១00%) |
| -ការដឹកជញ្ជូន | ៧0% | ៣0% | ស្ត្រីអាចជួយរៀបចំកណ្តាប់ |
| -ហាលសម្ងួត | ៥0% | ៥0% | ធ្វើការរួមគ្នា |
| -ទុកដាក់ស្រូវ | ៦0% | ៤0% | ស្ត្រីរៀបចំសម្អាតជង្រុក បុរសលើកដាក់ស្រូវ |
| -លក់ស្រូវ | ៥0% | ៥0% | ពិភាក្សារួមគ្នា ស្ត្រីជាអ្នកទុកដាក់លុយ |
| **សកម្មភាពមុខរបរចិញ្ចឹមជីវិតសំខាន់ផ្សេងទៀត** | | | |
| -សួនបន្លែ | ៤0% | ៦0% | បុរសជាអ្នករៀបចំសួនបន្លែ ស្ត្រីជួយថែទាំ |
| -ចិញ្ចឹមជ្រូក | ៣0% | ៧0% | បុរសជួយធ្វើទ្រុង និងលាងសម្អាតម្តងម្កាល |
| -ចិញ្ចឹមគោ ក្របី | ៧0% | ៣0% | បុរសធ្វើការងារច្រើនជាងស្ត្រី |
| -ចិញ្ចឹមមាន់ ទា | ៥0% | ៥0% | បុរស និងស្ត្រីធ្វើការរួមគ្នា |
| -រកត្រី | ៨0% | ២0% | ស្ត្រីជួយកាន់ឧបករណ៍ ឬចែវទូក |
| -ជំនួញទូទៅ | ២0% | ៨0% | បុរសជួយការងារបន្ទាប់បន្សំ |
| -ការថែទាំប្រព័ន្ធធារាសាស្ត្រ | ៩0% | ១0% | ស្ត្រីចូលរួមផ្តល់យោបល់ |
| **ដំណាំឪឡឹក** | | | |
| -ការរៀបចំដី | ៨0% | ១0% | ភាគច្រើនបុរសជាអ្នករៀបចំ ស្ត្រីដាំបាយឱ្យ |
| -ភ្ជួរ | ៨0% | ១0% | ភាគច្រើនបុរសជាអ្នករៀបចំ ស្ត្រីដាំបាយឱ្យ |
| -រាស់ | ៨0% | ២0% | ភាគច្រើនបុរសជាអ្នករៀបចំ |
| -ឆ្មូតរង | ៨0% | ២0% | ស្ត្រីចូលរួមជួយខ្លះដែរ |
| -ដាក់ជី | ៧0% | ៣0% | ស្ត្រីជួយរៀបចំជី បុរសជាអ្នកបាចជី |
| -ផ្តុំរង | ៨0% | ២0% | បុរសជាអ្នកធ្វើ ស្ត្រីជួយរៀបចំបាយទឹក |

| | | | |
|---|---|---|---|
| -ដាំគ្រាប់ | ៥០% | ៥០% | បុរស និងស្ត្រីធ្វើការរួមគ្នា |
| -ពូនរង | ៥០% | ៥០% | បុរស និងស្ត្រីធ្វើការរួមគ្នា |
| -បូមទឹក | ៨០% | ២០% | ស្ត្រីជួយរៀបចំ ទុយយោទឹក និងប្រេង |
| -ថែទាំ | ៥០% | ៥០% | បុរស និងស្ត្រីធ្វើការរួមគ្នា |
| -លក់ម៉ៅ | ៥០% | ៥០% | បុរស និងស្ត្រីពិភាក្សាគ្នា |

ប្រភព៖ *របាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំចុងដូងឆ្នាំ ២០១៨*

បើយោងទៅតាមរបាយការណ៍ ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំចុងដូង ឆ្នាំ២០១៧ បានរកឃើញពីការវិភាគតួនាទីយេនឌ័រក្នុងឃុំចុងដូងដូចខាងក្រោម៖

១. ផលិតផលកសិកម្មភាគច្រើន ស្ត្រីជាអ្នកផលិត

២. បុរសទៅរកចំណូលនៅឆ្ងាយៗផ្ទះ

៣. ស្ត្រីមើលថែការងារនៅផ្ទះជាប្រចាំ

៤. សកម្មភាពការងារមានការចូលរួមធ្វើទាំងអស់គ្នា

៥. ការងារធ្ងន់ៗជាបន្ទុករបស់បុរស

តាមប្រភពព័ត៌មានដែលទទួលបាន ដូចមានរៀបរាប់ខាងលើពាក់ព័ន្ធ ការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីនៅក្នុងឃុំចុងដូង យើងសង្កេតឃើញថា បុរស និងស្ត្រីមិនមានការរើសអើងគ្នាធ្ងន់ធ្ងរនោះទេ គឺមានភាពលំអៀងតិចតួចប៉ុណ្ណោះ ដូចជាការងារធ្វើស្រែគេសង្កេតឃើញថា បុរសមានការចូលរួមច្រើនជាងស្ត្រី ជាពិសេសការងាររៀបចំដីស្រែ ឃើញថាការងារនេះបុរសទទួលរ៉ាប់រងស្ទើរតែទាំងស្រុង ដែលស្ត្រីមានកម្លាំងទន់ខ្សោយជាងជាអ្នកចម្អិនអាហារនៅផ្ទះ ចំណែកការងារដឹកជញ្ជូនគ្រាប់ស្រូវ បាញ់ថ្នាំ សម្លាប់សត្វល្អិត និងដាក់ជីច្រូតកាត់ និងការងារទុកដាក់ស្រូវជាដើម គឺបុរសបានចូលរួមច្រើនជាងស្ត្រី ប៉ុន្តែការងារក្នុងផ្ទះ និងនៅជិតផ្ទះឃើញស្ត្រីបានចូលរួមច្រើនជាងបុរសវិញ តែនៅក្នុងនោះក៏បានរកឃើញថា ការសម្រេចចិត្តក្នុងគ្រួសារបុរសនៅមានសិទ្ធិច្រើនជាងស្ត្រី និងមានស្ត្រីមួយចំនួននៅទទួលរងអំពើហិង្សាក្នុងគ្រួសារនៅឡើយ ។ ប៉ុន្តែទោះបីមានបញ្ហាប្រឈមខ្លះក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីក៏ដោយ ក៏យើងឃើញកិច្ចការនេះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលទៅថ្ងៃអនាគតនឹងឈានទៅកាន់តែប្រសើរឡើង ។

## ១.២. ស្ថានភាពភូមិសាស្ត្រ

### ១.២.១. ទីតាំងភូមិសាស្ត្រ

ឃុំចុងដូង ជាឃុំមួយស្ថិតនៅក្នុងដែនរដ្ឋបាលស្រុកបារាយណ៍ ខេត្តកំពង់ធំ មានទីតាំងផ្អែកលើនិយាមកាផែនទី (អាប់ស៊ីស) ៥១១ ៥៨៨,១៨ និង(អ័រដោនេ) ១ ៣៧៦ ២១០,៤៨ ។ សណ្ឋានដីនៅក្នុងឃុំចុងដូង បើផ្អែកតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ បានឱ្យដឹងថា ជាដីមិនរាបស្មើមានទាបមានខ្ពស់ ដោយបានចែកចេញជា ០៣ តំបន់ គឺ

**តំបន់ I**៖ នៅភាគខាងកើតឃុំ ជាតំបន់ដីមានស្ថាពភាពរមៀលក្រួច និងដីជម្រាលពីកើតទៅលិច ដែលមានប្រភេទដីល្បាយខ្សាច់ ដីកណ្តេង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ ត្រូវបានប្រើប្រាស់សម្រាប់លំនៅឋាន ដំណាំស្រូវវស្សា និងស្រូវប្រាំង ដំណាំតាមរដូវ និងដំណាំឈើហូបផ្លែ ។

**តំបន់ II**៖ នៅផ្ទៃកកណ្តាលឃុំ ជាតំបន់មានស្ថាពភាពរមៀលក្រូច ទាបជាងតំបន់ទី I បន្តិច ជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីផេះព័ណ៌ខ្មៅ ដីកណ្តោង ក្រុមគោកគ្រប់ ក្រុមប្រទះឡាង និងក្រុមដីក្រគរ ត្រូវបានប្រើប្រាស់សម្រាប់ដំណាំស្រូវប្រាំង និងស្រូវប្រដេញទឹកស្រោចស្រពដោយប្រព័ន្ធប្រឡាយ និងបឹង ។

**តំបន់ III**៖ នៅភាគខាងលិច ជាតំបន់ទំនាបលិចទឹក ៤ខែ ទាបជាងតំបន់ទី II ជម្រាលពីកើតទៅលិច ជាប្រភេទដីល្បប់ និងក្រុមដីក្រគរ ត្រូវបានប្រើប្រាស់សម្រាប់ដំណាំស្រូវប្រាំង ស្រូវប្រដេញទឹក និងតំបន់អភិរក្សសត្វខ្សឹប ។

ផែនទី 3៖ ផែនទីរយៈកម្ពស់ឃុំចុងដូង



ផែនទី 4៖ ពំនុះកាត់ទទឹងឃុំចុងដូង




តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹង ឃុំចុងដូង ស្រុកបារាយណ៍

| តំបន់ / បរិយាយ | តំបន់កៀ្សត្រ-បរិស្ថាន I | តំបន់កៀ្សត្រ-បរិស្ថាន II | តំបន់កៀ្សត្រ-បរិស្ថាន III |
|---|---|---|---|
| រូបថតតំណាងតំបន់ កៀ្សត្រ-បរិស្ថាន |  |  |  |
| ឈ្មោះតំបន់ | តំបន់លំនៅឋានដំណាំស្រូវវស្សា និងស្រូវប្រាំង ដំណាំតាមរដូវ និងដំណាំឈើហូបផ្លែ (ចាប់ពីថ្នល់ជាតិរហូតដល់ប្រឡាយកងមាស) ផ្ទៃដីសរុប ៥,៨៦០ហ.ត | តំបន់ដំណាំស្រូវប្រាំង និងស្រូវប្រដេញទឹក ស្រោចស្រពដោយប្រព័ន្ធប្រឡាយ និងបឹង(ចាប់ ប្រឡាយកងមាសរហូត ដល់មាត់បឹងរៀល)(ធ្វើស្រែបាន២ដង)ផ្ទៃដីសរុប ៣,៥០៨ហ.ត | តំបន់ដំណាំស្រូវប្រាំង និងស្រូវប្រដេញទឹក និងតំបន់អភិរក្សសត្វឱ្យប(ចាប់ពីមាត់បឹងរៀលរហូតដល់ ជីណ្តក ស្រុកកំពង់លែង)(ធ្វើស្រែបាន១ដង) ផ្ទៃដីសរុប ៣,៣៤៦ហ.ត |
| រៀបរាប់ដោយសង្ខេប | -មានលំនៅឋាន<br>-ដំណាំស្រូវវស្សា<br>-ដំណាំស្រូវប្រាំង<br>-ដំណាំបន្លែចម្រុះ<br>-ដំណាំឈើហូបផ្លែ | -ស្រូវប្រាំង និងស្រូវប្រដេញទឹក<br>-ដំណាំឪឡឹក<br>-ឃ្វាល ទា,គោក្របី<br>-នេសាទត្រី<br>-ធ្វើស្រែភាគច្រើនមានភ្លឺ | -ស្រូវប្រាំងនិងស្រូវប្រដេញទឹក<br>-ដំណាំឈូក<br>-នេសាទត្រី<br>-ឃ្វាល ទា,គោក្របី<br>-ធ្វើស្រែភាគច្រើនមានភ្លឺ |

| | | | |
|---|---|---|---|
| | -ដំណាំឪឡឹក<br>-ដំណាំដំឡូងផ្វា<br>-ដំណាំដំឡូងមី<br>-សាលារៀន<br>-មណ្ឌលសុខភាព<br>-សាលាឃុំ<br>-ប៉ុស្តិ៍នគរបាលរដ្ឋបាល<br>-សួនបណ្តុះកូនឈើ<br>-វត្តអារាម<br>-ចិញ្ចឹមសត្វ(សេះ,ពពែ,ជ្រូក, មាន់,ទា,គោក្របី)<br>-ធ្វើស្រែភាគច្រើនគ្មានភ្លឺ<br>-ដីមិនសូវមានជីជាតិ | -ដីមានជីជាតិមធ្យម | -ដីមានជីជាតិមធ្យម |
| ឋានលេខា | -ដីមានស្ថាពភាពរមៀលក្រួច<br>-ដីជម្រាលពីកើតទៅលិច | -ដីមានស្ថាពភាពរមៀលក្រួច ទាបជាងតំបន់ទី\| បន្តិច<br>-ដីជម្រាលពីកើតទៅលិច | -ដីទំនាបលិចទឹក ៤ខែ ទាបជាងតំបន់ទី\|\|<br>-ដីជម្រាលពីកើតទៅលិច |
| ប្រភេទដី | -ដីល្បាយខ្សាច់<br>-ដីកណ្តេង<br>-ដីគ្រួសខ្មៅ<br>-ដីខ្សាច់<br>-ក្រុមដីកំពង់សៀម<br>-ក្រុមប្រទះឡាង<br>-ក្រុមដីព្រៃខ្មែរ | -ដីល្បាយខ្សាច់<br>-ដីផេះព័ណ៌ខ្មៅ<br>-ដីកណ្តេង<br>-ក្រុមគោកត្រប់<br>-ក្រុមប្រទះឡាង<br>-ក្រុមដីក្រគរ | -ដីល្បប់<br>-ក្រុមដីក្រគរ |
| ជលសាស្ត្រ | -ប្រឡាយកំប៉ើយ ប្រភពទឹកមកពីទំនប់១មករា ១០គម (ជម្រៅទឹក ១-១.៥ម)<br>-ប្រឡាយត្នោតជុំ(CAVAC) ប្រភពទឹកមកពីទំនប់1មករា 10Km(ជម្រៅទឹក ១-១,៥ម)<br>-ប្រឡាយណោងសានស្វាយរៀង 2km(ជម្រៅទឹក ១-១,៥ម)<br>-ប្រឡាយតូច (ជម្រៅ0,៥-១ម)<br>-ប្រឡាយកងមាស(ជម្រៅ១-២ម)<br>-ប្រឡាយត្រពាំងឈើទាល ១៦00ម(ជម្រៅទឹក 0,៣-0,៥ម) | -ប្រឡាយកងមាស(ជម្រៅទឹក១-២ម)<br>-ប្រឡាយកំប៉ើយ ប្រភពទឹកមកពីទំនប់1មករា ១០គម<br>-អូរឆ្តោរ=៥ហ.ត(ប្រើពេញ១ឆ្នាំ)<br>-អូរក្រចាប់=៣ហ.ត(ប្រើពេញ១ឆ្នាំ)<br>-អូរច្រលង=១០ហ.ត(ប្រើពេញ១ឆ្នាំ)<br>-អូរត្រកួន=១0ហ.ត(ប្រើពេញ១ឆ្នាំ)<br>-អូរអាកង់=៥ហ.ត(ប្រើពេញ១ឆ្នាំ)<br>-បឹងរៀល១២0ហ.ត(ប្រើពេញ១ឆ្នាំ)<br>-បឹងបបែល១0ហ.ត(ប្រើពេញ១ឆ្នាំ)<br>-បឹងល្ងួងយ៉ាន់២0ហ.ត(ពេញ១ឆ្នាំ) | -ត្រពាំងបឹងផ្តោល=១០ហ.ត<br>-បឹងត្រាវ= ១0ហ.ត<br>-បឹងអាផ្តោល=៣ហ.ត<br>-បឹងអាស្រូល=៣ហ.ត<br>-បឹងផ្តោល=១១ហ.ត<br>-បឹងត្រស់ ៣ហ.ត<br>-បឹងប្រចៅ ៥ហ.ត<br>-បឹងត្រើយម៉ាកង=៨0ហ.ត<br>-បឹងរៀល=១០ហ.ត(ប្រើពេញ១ឆ្នាំ)<br>-បឹងអាកង់=១ហ.ត<br>-អូរស្រះរៀន=១0ហ.ត<br>-អូរកំពីងពួយ=២ហ.ត<br>-ព្រែកកាត់=១0ហ.ត<br>-ព្រែកសាច់អាខ្មៅ=៥ហ.ត |
| ធនធានទឹក | -ប្រឡាយមេស្ទឹង ជីនិត<br>-ប្រឡាយកំប៉ើយ<br>-ប្រឡាយត្នោតជុំ(CAVAC) | -ប្រឡាយកងមាស<br>-ប្រឡាយកំប៉ើយ<br>-បឹងរៀល | -បឹងត្រាវ<br>-បឹងផ្តោល<br>-បឹងត្រើយម៉ាកង |

| | | | |
|---|---|---|---|
| | -ប្រឡាយណោងសានស្វាយរៀង<br>-ប្រឡាយតូច<br>-ប្រឡាយកងមាស<br>-ប្រឡាយត្រពាំងឈើទាល | -បឹងលួងយ៉ាន់<br>-បឹងបបែល | -បឹងរៀល |
| គំរបដី/ការប្រើប្រាស់ដី | -សាងសង់លំនៅឋាន<br>-សាលារៀន<br>-សាលាឃុំ<br>-វត្ត<br>-ប៉ុស្ដិ៍នគបាល<br>-មណ្ឌលសុខភាព<br>-ផលិតប្រាំង និងស្រូវវស្សា<br>-ដាំដំណាំឈើហូបផ្លែ<br>-ដាំដំណាំបន្លែចម្រុះ<br>-ដំណាំដំឡូងផ្វា<br>-ដំណាំដំឡូងមី<br>-ចិញ្ចឹមសត្វ(សេះ,ពពែ,ជ្រូក, មាន់,ទា,គោក្របី)<br>-សាងសង់ប្រព័ន្ធប្រឡាយទឹក | -ស្រូវប្រាំង និងស្រូវប្រដេញទឹក<br>-ដំណាំឪឡឹក<br>-ឃ្វាល ទា,គោក្របី<br>-នេសាទត្រី | -ស្រូវប្រាំង និងស្រូវប្រដេញទឹក<br>-ដំណាំឈូក<br>-នេសាទត្រី<br>-ឃ្វាល ទា,គោក្របី |
| ដំណាំសំខាន់ៗ | -ដំណាំស្រូវវស្សា<br>-ដំណាំស្រូវប្រាំង<br>-ដំណាំដំឡូងមី<br>-ដំណាំឪឡឹក<br>-ដំឡូងផ្វា<br>-ដំណាំឈើហូបផ្លែ<br>-ដំណាំបន្លែចម្រុះ | -ដំណាំស្រូវប្រដេញទឹក<br>-ដំណាំស្រូវប្រាំង<br>-ដំណាំឪឡឹក | -ដំណាំស្រូវប្រដេញទឹក<br>-ដំណាំស្រូវប្រាំង<br>-ដំណាំឪឡឹក<br>-ដំណាំឈូក |
| ពូជស្រូវ | -ពូជស្រូវសែនក្រអូប<br>-ពូជស្រូវ៥០៤<br>-ពូជស្រូវផ្ការំដួល<br>-ពូជស្រូវរាំងជ័យ<br>-ពូជស្រូវខា៨<br>-ពូជស្រូវ៤៩<br>-ពូជស្រូវខា៣<br>-ពូជស្រូវអង្គការក្រហម<br>-ពូជស្រូវដំណើបនាងនួក<br>-ពូជស្រូវដំណើបស្មាច់<br>-ពូជស្រូវនងម៉ន<br>-ពូជស្រូវលាក់ស្លឹក<br>-ពូជស្រូវផ្កាម្លិះ<br>-ពូជស្រូវផ្ការមៀត | -ពូជស្រូវសែនក្រអូប<br>-ពូជស្រូវ៥០៤<br>-ពូជស្រូវ៤៩ | -ពូជស្រូវសែនក្រអូប<br>-ពូជស្រូវ៥០៤<br>-ពូជស្រូវ៤៩ |

| | | | |
|---|---|---|---|
| ការប្រើប្រាស់ដី | +ពូជស្រូវវស្សា<br>-ជីដេអាប៉េ ១បាវ<br>-ជីអ៊ុយរ៉េ ១បាវ<br>-ជីកាលី ១បាវ<br>+ពូជស្រូវប្រាំង<br>-ជីដេអាប៉េ ២បាវ<br>-ជីអ៊ុយរ៉េ ២បាវ<br>-ជី20-20-15TE ១បាវ | ពូជស្រូវប្រាំង<br>-ជីដេអាប៉េ ២បាវ<br>-ជីអ៊ុយរ៉េ ២បាវ<br>-ជី20-20-15TE 1បាវ | ពូជស្រូវប្រាំង<br>-ជីដេអាប៉េ ១បាវ<br>-ជីអ៊ុយរ៉េ ១បាវ<br>-ជី20-20-15TE ១បាវ |
| ការចិញ្ចឹមសត្វ | -ចិញ្ចឹមសត្វ (សេះ,ពពែ,ជ្រូក, មាន់,ទា,គោក្របី) | -កន្លែងឃ្វាល (ជ្រូក,មាន់,ទា,គោក្របី) | -កន្លែងឃ្វាល (ជ្រូក,មាន់,ទា,គោក្របី) |
| ដីរបស់រដ្ឋ/ដីសហគមន៍ | -ត្រពាំង=0,៤ហ.ត | -ត្រពាំង ភូមិបឹង=0,៤ហ.ត<br>-ត្រពាំងស្រះ=0,0៥ហ.ត<br>-ត្រពាំងអារស់=0,0៧ហ.ត<br>-ត្រពាំងក្របៅ=0,0៤៥ហ.ត<br>-ត្រពាំងឫស្សី =0,0៤ហ.ត<br>-ត្រពាំងត្រនក=0,0៦ហ.ត<br>-ត្រពាំងអាលាត=0,0៩ហ.ត<br>-ត្រពាំងអណ្តូង=0,0៤ហ.ត<br>-ត្រពាំងគ្រួស=0,៥ហ.ត<br>-ត្រពាំងវែង=0,0៣ហ.ត<br>-ត្រពាំងកណ្តាល=0,២៥ហ.ត<br>-ត្រពាំងពោង=0,២៥ហ.ត<br>-ត្រពាំងសាមខា=0,៥ហ.ត<br>-ត្រពាំងពងក្រពើ=១ហ.ត<br>-ត្រពាំងឈូក៣ហ.ត(ពេញ1ឆ្នាំ)<br>-ត្រពាំងតាឆេង=0,៥ហ.ត<br>-ត្រពាំងបញ្ចុង=២,៥ហ.ត<br>-ត្រពាំងក្បាលក្របី=១ហ.ត (ប្រើពេញ1ឆ្នាំ)<br>-ត្រពាំងបាតត្រឡោក=៥ហ.ត<br>-ត្រពាំងកក់=១ហ.ត<br>-ត្រពាំងសារ៉ាយ=១ហ.ត<br>-ត្រពាំងគល់=១ហ.ត<br>-ត្រពាំងតាប៉ោ=0,៧ហ.ត<br>-ត្រពាំងត្រាវជាន់ផុងលើ=២ហ.ត<br>-ត្រពាំងត្រាវជាន់ផុងក្រោម២ហ.ត<br>-ត្រពាំងអាឡៃង=0,៥ហ.ត<br>-អូរស្តោរ=៥ហ.ត(ប្រើពេញ១ឆ្នាំ)<br>-អូរក្រចាប់៣ហ.ត(ពេញ១ឆ្នាំ) | -បឹងត្រាវ= ១0ហ.ត<br>-បឹងអាផ្ចោល=៣ហ.ត<br>-បឹងអាស្រូល=៣ហ.ត<br>-បឹងត្រស់ ៣ហ.ត<br>-បឹងប្រចៅ ៥ហ.ត<br>-បឹងត្រើយម៉ាកង=៨0ហ.ត<br>-បឹងរៀល=១0ហ.ត(ពេញ1ឆ្នាំ)<br>-បឹងផ្ចោល=១១ហ.ត<br>-បឹងអាកង់=១ហ.ត<br>-ត្រពាំងកំផ្លាញ=0,២៥ហ.ត<br>-ត្រពាំងអកនៀល=0,២៥ហ.ត<br>-ត្រពាំងដងវែក=២ហ.ត<br>-ត្រពាំងបឹងផ្ចោល=១0ហ.ត<br>-អូរស្រះរៀន=១0ហ.ត<br>-អូរកំពីងពួយ=២ហ.ត<br>-ព្រៃកកាត់=១0ហ.ត<br>-ព្រៃកសាច់អាខ្មៅ=៥ហ.ត |

| | | | |
|---|---|---|---|
| | | -អូរច្រលង១០ហ.ត(ពេញ១ឆ្នាំ)<br>-អូរត្រកួន១០ហ.ត(ប្លេញ១ឆ្នាំ)<br>-អូរអាកង់៥ហ.ត(ប្រើពេញ១ឆ្នាំ)<br>-បឹងរៀល១២០ហ.ត(ពេញ១ឆ្នាំ)<br>-បឹងបបែល១០ហ.ត(ពេញ១ឆ្នាំ)<br>-បឹងលួងយ៉ាន់=២០ហ.ត(ប្រើពេញ១ឆ្នាំ) | |
| បញ្ហាផ្សេងៗ | -ដីស្រែមិនរាបស្មើ<br>-ជម្ងឺ និងកត្តាចង្រៃលើស្រូវ<br>-គ្មានប្រឡាយជើងក្អែប<br>-ធាតុចូលកសិកម្មឡើងថ្លៃ<br>-ខ្វះបច្ចេកទេសជួសជុលថែទាំគ្រឿងយន្តកសិកម្ម<br>-ផ្លូវពិបាកដឹកជញ្ជូនកសិកផលចេញពីស្រែ<br>-ខ្វះបច្ចេកទេសផលិតពូជស្រូវ<br>-ខ្វះបច្ចេកទេសមុន និងក្រោយប្រមូលផលស្រូវ<br>-ខ្វះបច្ចេកទេសប្រើប្រាស់ដីនិងថ្នាំ កសិកម្ម<br>-គ្មានឡសម្ងួត និងលានហាល<br>-ខ្វះបច្ចេកទេសដាំដុះស្រូវ<br>-តម្លៃស្រូវទាប | -ដីស្រែមិនរាបស្មើ<br>-ជម្ងឺនិងកត្តាចង្រៃលើដំណាំស្រូវ<br>-ធាតុចូលកសិកម្មឡើងថ្លៃ<br>-ខ្វះបច្ចេកទេសជួសជុលថែទាំគ្រឿងយន្តកសិកម្ម<br>-ផ្លូវពិបាកដឹកជញ្ជូនកសិកផលចេញពីស្រែ<br>-ខ្វះបច្ចេកទេសផលិតពូជស្រូវ<br>-ខ្វះបច្ចេកទេសមុន និងក្រោយប្រមូលផលស្រូវ<br>-ខ្វះបច្ចេកទេសប្រើប្រាស់ដីនិងថ្នាំ កសិកម្ម<br>-ខ្វះបច្ចេកទេសដាំដុះស្រូវ<br>-តម្លៃស្រូវទាប | -ដីស្រែមិនរាបស្មើ<br>-ជម្ងឺ និងកត្តាចង្រៃលើស្រូវ<br>-ធាតុចូលកសិកម្មឡើងថ្លៃ<br>-ខ្វះបច្ចេកទេសជួសជុលថែទាំគ្រឿងយន្តកសិកម្ម<br>-ផ្លូវពិបាកដឹកជញ្ជូនកសិកផលចេញពីស្រែ<br>-ខ្វះបច្ចេកទេសផលិតពូជស្រូវ<br>-ខ្វះបច្ចេកទេសមុន និងក្រោយប្រមូលផលស្រូវ<br>-ខ្វះបច្ចេកទេសប្រើប្រាស់ដី និងថ្នាំ កសិកម្ម<br>-ខ្វះបច្ចេកទេសដាំដុះស្រូវ<br>-តម្លៃស្រូវទាប |
| កាឡានុវត្តភាព/ឱកាស | -អាចធ្វើស្រែបាន២-៣ដង/ឆ្នាំ (តែកសិករភាគច្រើនមិនធ្វើដោយសារមានផ្ទៃដីតូចៗ)<br>-ពង្រីកការដាំដុះដំណាំឱឡឹក និងដំឡូងផ្វាបន្ទាប់ពីប្រមូលផលស្រូវហើយ<br>-ពង្រីកការដាំដុះដំណាំស្រូវសម្រាប់ ផ្គត់ផ្គង់ទីផ្សារ<br>-បង្កើតក្រុមផលិតពូជស្រូវ<br>-ពង្រឹងនិងគាំទ្រសហគមន៍កសិកម្ម<br>-បង្កើតតំបន់ទេចរណ៍ធម្មជាតិ និងតំបន់អភិរក្សមេពូជត្រីបឹងរៀល<br>-ពង្រឹង និងគាំទ្រសហគមន៍កែច្នៃគ្រឿងសង្ហារឹម | -អាចធ្វើស្រែបាន២ដង/ឆ្នាំ<br>-ពង្រីកការដាំដុះដំណាំឱឡឹក បន្ទាប់ពីប្រមូលផលស្រូវហើយ<br>-ពង្រីកការដាំដុះស្រូវសម្រាប់ផ្គត់ផ្គង់ទីផ្សារ<br>-បង្កើតក្រុមផលិតពូជស្រូវ<br>-បង្កើតតំបន់ទេចរណ៍ធម្មជាតិ និងតំបន់អភិរក្សមេពូជត្រីបឹងរៀល | -ពង្រីកការដាំដុះដំណាំឱឡឹក បន្ទាប់ពីប្រមូលផលស្រូវហើយ<br>-ពង្រីកការដាំដុះដំណាំស្រូវសម្រាប់ ផ្គត់ផ្គង់ទីផ្សារ<br>-បង្កើតតំបន់ទេចរណ៍ធម្មជាតិ និងតំបន់អភិរក្សមេពូជត្រីបឹងត្រើយម៉ាកង |

បើយោងទៅតាម របាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំចុងដូង បានបង្ហាញ ឱ្យឃើញថា នៅក្នុងឃុំ មានប្រភពទឹកសំខាន់ៗដូចជា៖ បឹងរៀល បឹងល្ហុងយ៉ាន់ បឹងបបែល បឹងត្រាវ បឹងផ្តោល បឹងត្រើយម៉ាកង និងបឹងរៀល ព្រមទាំងប្រឡាយសំខាន់ៗ ដូចជា៖ ប្រឡាយមេស្ទឹងជីនិត ប្រឡាយកំប៉ិយ ប្រឡាយត្នោតជុំ(CAVAC) ប្រឡាយណោងសានស្វាយរៀង ប្រឡាយកងមាស ប្រឡាយត្រពាំងឈើទាល ។ នៅក្នុងឃុំចុងដូងមានប្រឡាយចំនួន ៣០ខ្សែ ប្រវែង ៤៦ ២១១,១៤ម៉ែត្រ នៅក្នុងនោះប្រឡាយមេ មាន ២ ខ្សែ ប្រវែង ៣ ៧៥៣,៧៩ ម៉ែត្រ ប្រឡាយរងមាន ១ ខ្សែ ប្រវែង ៤ ០២៤,៥៣ ម៉ែត្រ និងប្រឡាយតូចៗមាន ២៧ខ្សែ ប្រវែង ៣៨ ៤៣២,៨៣ ម៉ែត្រ។ ចំណែកទឹកក្រោមដីនៅក្នុងឃុំចុងដូង មានការប្រើប្រាស់ តាមរយៈអណ្តូងស្នប់សម្រាប់ស្រោចស្រព និងសម្រាប់ការប្រើប្រាស់ទូទៅក្នុងជីវភាពប្រចាំថ្ងៃ របស់ប្រជាពលរដ្ឋប៉ុណ្ណោះ។ ប្រភពទឹកដែលនាំទឹកមកប្រើប្រាស់នៅក្នុងឃុំ មានតែរដូវវស្សាពីបឹងរៀល បឹងល្ហុងយ៉ាន់ បឹងបបែល បឹងត្រាវ បឹងផ្តោល បឹងត្រើយម៉ាកង និងបឹងរៀល តាមរយៈប្រឡាយមេ និងប្រឡាយរង ដែលឃុំបានជីក និងស្តារសម្រាប់នាំយកទឹកមកស្រោចស្រពនៅក្នុងភូមិសាស្ត្រស្រែវស្សា និងស្រែប្រាំង ។

តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ

| ប្រភេទ | ចំនួនខ្សែ | ប្រវែង(ម៉ែត្រ) |
|---|---|---|
| ប្រឡាយមេ | ២ | ៣ ៧៥៣,៧៩ |
| ប្រឡាយរង | ១ | ៤ ០២៤,៥៣ |
| ប្រឡាយតូច | ២៧ | ៣៨ ៤៣២,៨៣ |
| **ចំនួនសរុប** | **៣០** | **៤៦ ២១១,១៤** |

រូបភាព 3៖ ប្រព័ន្ធធារាសាស្ត្រ



ប្រឡាយរង

ផែនទី 5 ៖ ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំចុងដូង




## ១.២.២. អាកាសធាតុ (ពិពណ៌នាតាមរដូវកាល)

នៅក្នុងឃុំចុងដូងក៏ដូចជានៅទូទាំងខេត្ត គឺទទួលរបបខ្យល់មកពីតំបន់ត្រូពិច ដែលមានអាកាសធាតុក្តៅ ហើយសើម។ របបខ្យល់មូសុង គឺបានពាំនាំមកនូវចំនួនទឹកភ្លៀងយ៉ាងច្រើនមកជាមួយ ដែលអំណោយផលទៅដល់ការធ្វើកសិកម្មនានា និងដាំដំណាំផ្សេងៗទៀត។

បើយោងទៅតាមប្រភពទិន្នន័យពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំ ប្រចាំស្រុកបារាយណ៍ក្នុងឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងស្រុកបារាយណ៍ទាំងមូល មានភ្លៀងធ្លាក់សរុបចំនួន ៩១ ដង និងមានបរិមាណទឹកភ្លៀងប្រចាំឆ្នាំចំនួន ១ ៤១៩,៩ ម.ម ។

**អំពីអាកាសធាតុ៖**

- រដូវរងារ៖ ខែ វិច្ឆិកា ដល់ ខែ មីនា (២០ ទៅ ២៨ អង្សា)
- រដូវក្តៅ៖ ខែ មីនា ដល់ ខែ ឧសភា (៣០ ទៅ ៣៥ អង្សា)
- រដូវភ្លៀង៖ ខែ ឧសភា ដល់ ខែ តុលា (២៣ ទៅ ៣០ អង្សា ជាមួយនឹងការឡើងសំណើមទៅដល់ ៩០ ភាគរយ)នៅរដូវនេះជារៀងរាល់ឆ្នាំ គឺមានភ្លៀងធ្លាក់ខ្លាំង នៅពេលរសៀល និងល្ងាច។

សំណើម៖ ឃុំចុងដូងមានសំណើមជាមធ្យម ៤៨ភាគរយ និងមានល្បឿនខ្យល់៣គីឡូម៉ែត្រ/១ម៉ោង។

តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ

| ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិមាណទឹកភ្លៀង | ២ | ១៥,៨ | ៣៧,៦ | ៩៨,៣ | ២០៣ | ១១១,៥ | ២០៨ | ២៥០ | ១៦៤,៥ | ១៤៤,៩ | ១១៧,៨ | ៦៦,៥ |
| ចំនួនថ្ងៃមានភ្លៀងធ្លាក់ | ១ | ១ | ២ | ៨ | ១១ | ៦ | ១០ | ១៥ | ១០ | ៩ | ១០ | ៦ |

ប្រភព៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ




ប្រភព៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

### ១.២.៣. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍រួមមាន ផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស ។ បច្ចុប្បន្នឃុំចុងដូងមានតែប្រព័ន្ធគមនាគមន៍ផ្លូវគោកប៉ុណ្ណោះ ហើយបានដើរតួយ៉ាងសំខាន់ នៅក្នុងការសម្រួលទៅដល់ ការដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ដែលនៅក្នុងនោះមានផ្លូវសំខាន់ជាច្រកចេញ-ចូល របស់ឃុំចំនួន១ខ្សែ គឺផ្លូវជាតិលេខ៦ ប្រវែង៤ ៦៧៧,២៩ម៉ែត្រ ឆ្លងកាត់ភូមិចំនួន៤ ដូចជាភូមិទួលដំណាក់ ភូមិពពេជ ភូមិទួលសាលា និងភូមិចុងដូង និងមានផ្លូវក្នុងឃុំផ្សេងៗទៀតគ្រប់គ្រាន់ អាចតភ្ជាប់ទំនាក់ទំនងពីភូមិមួយទៅភូមិមួយ រួមទាំងអាចទំនាក់ទំនងទៅក្រៅឃុំបានយ៉ាងងាយស្រួល។ ឃុំចុងដូង មានផ្លូវសរុបចំនួន ១៣៨ ខ្សែ ប្រវែង ១៤៧ ២៥២,៥១ ម៉ែត្រ ក្នុងនោះផ្លូវកៅស៊ូមានចំនួន ១ ខ្សែ ប្រវែង ៤ ៦៧៧,២៩ ម៉ែត្រ ផ្លូវគ្រួសក្រហមចំនួន ៥២ ខ្សែ ប្រវែង ៤២ ៦០៣,៤៨ ម៉ែត្រ និងផ្លូវលំដីសឬផ្លូវរទេះចំនួន ៨៥ ខ្សែ ប្រវែង ៩៩ ៩៧១,៧៤ ម៉ែត្រ ។

តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន

| ប្រភេទផ្លូវ | ចំនួនខ្សែផ្លូវ | ប្រវែងផ្លូវ(ម៉ែត្រ) |
|---|---|---|
| ផ្លូវជាតិលេខ៦ | ១ | ៤ ៦៧៧,២៩ |
| ផ្លូវគ្រួសក្រហម | ៥២ | ៤២ ៦០៣,៤៨ |
| ផ្លូវលំដីសឬផ្លូវរទេះ | ៨៥ | ៩៩ ៩៧១,៧៤ |
| **ចំនួនសរុប** | **១៣៨** | **១៤៧ ២៥២,៥១** |

រូបភាព 4៖ ប្រព័ន្ធគមនាគមន៍



ផ្លូវកៅស៊ូ



ផ្លូវគ្រួសក្រហម



ផ្លូវលំដីស

ផែនទី 6 ៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំចុងដូង




## ១.២.៤. បរិក្ខាសាធារណ:

### ក. ស្ថានភាពប្រើប្រាស់អគ្គិសនី

បេសកកម្មរបស់មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ គឺដឹកនាំជំរុញការគ្រប់គ្រង និងសមាហរណកម្មលើវិស័យរ៉ែ និងថាមពលរួមទាំងប្រេងកាត ឧស្ម័ន និងអគ្គិសនី នៅក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចសង្គម នៅមូលដ្ឋាន និងនៅក្នុងខេត្តកំពង់ធំ ក្នុងនាមជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល ។

នៅក្នុងឃុំចុងដូង ប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីមានចំនួន ២ ៨៩៨ខ្នងផ្ទះ ស្មើនឹង ៩៩,១ភាគរយ អាគុយមានចំនួន ២១ ខ្នងផ្ទះ ស្មើនឹង ០,៧ ភាគរយ ចំណែកប្រភពថាមពលក្រៅពីនោះមិនមានប្រើប្រាស់នោះទេ ។

តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី

| បរិយាយ | ២០១៦ភាគរយ | ២០១៧ | |
|---|---|---|---|
| | | ភាគរយ | ចំនួនផ្ទះ |
| ផ្ទះបំភ្លឺដោយបណ្ដាញអគ្គិសនី | ៨៥,១ | ៩៩,១ | ២៨៩៨ |
| ផ្ទះបំភ្លឺដោយអាគុយ | ៦,៣ | ០,៧ | ២១ |
| ផ្ទះបំភ្លឺដោយបន្ទះសូឡា | ០,០ | ០,០ | ០ |
| ផ្ទះបំភ្លឺដោយឡជីវឧស្ម័ន | ០,០ | ០,០ | ០ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

## ខ. ប្រព័ន្ធទឹកស្អាត

អាជ្ញាធរខេត្តកំពង់ធំ បានអំពាវនាវឱ្យប្រជាពលរដ្ឋ ដែលធ្លាប់ប្រើប្រាស់ទឹក ស្ទឹង ត្រពាំង ឬអណ្ដូងដៃងាកមកប្រើប្រាស់ទឹកស្អាតវិញ ដើម្បីជួយលើកកម្ពស់សុខភាព និងលើកស្ទួយអនាម័យនៅជនបទ ។ ក្នុងឃុំចុងដូង ប្រជាពលរដ្ឋប្រើប្រាស់ទឹកស្អាតមានចំនួន ៩២៦គ្រួសារ ស្មើនឹង ៣០ភាគរយ ក្នុងនោះ អណ្ដូងស្នប់ ឬ អណ្ដូងចម្រុះ មានចំនួន ៤៩១គ្រួសារ និងអណ្ដូងជីកមានការការពារ ៤៩១គ្រួសារ ចំណែកអណ្ដូងជីកមិនមានការការពារ មានប្រជាពលរដ្ឋប្រើប្រាស់ចំនួន ២ ១៦៤នាក់ ស្មើនឹង ៧០ភាគរយ ហើយប្រភពទឹកក្រៅពីនេះមិនមានប្រជាជនប្រើប្រាស់នោះទេ ។ តាមរយៈទិន្នន័យខាងក្រោម បានបង្ហាញថា ប្រជាពលរដ្ឋនៅមានចំនួនច្រើនណាស់ ដែលប្រើប្រាស់ទឹកមិនទាន់ស្អាត ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់ពួកគាត់ ។

តារាង 21៖ ស្ថិតិអ្នកប្រើប្រាស់ការប្រើប្រាស់ទឹក

| បរិយាយ | | ២០១៦ | ២០១៧ |
|---|---|---|---|
| សរុបគ្រួសារមានទឹកស្អាតប្រើប្រាស់ | | **២ ៣៤៨** | **៩២៦** |
| ក្នុងនោះ | ទឹកដែលឆ្លងកាត់ប្រព័ន្ធធ្វើទឹកឱ្យស្អាត | ១៦ | ៤៩ |
| | ទឹកអណ្ដូងស្នប់ឬអណ្ដូងចម្រុះ | ១៥៦៣ | ៤៩១ |
| | ទឹកអណ្ដូងជីកមានការការពារ | ៧៦៩ | ៣៨៦ |
| | ទឹកភ្លៀងដែលមានការការពារ | ០ | ០ |
| %គ្រួសារមានទឹកស្អាតប្រើប្រាស់ | | **៨០,៤** | **៣០,០** |
| ទឹកអណ្ដូងជីកមិនមានការការពារ | | ១២៥ | ២ ១៦៤ |
| %គ្រួសារប្រើប្រាស់ទឹកអណ្ដូងជីកមិនមានការការពារ | | ៤,៣ | ៧០,០ |
| ទឹកស្រះ | | ០ | ០ |
| %គ្រួសាប្រើប្រាស់ទឹកស្រះ | | ០,០ | ០,០ |
| ទឹកពីប្រភពផ្សេងៗ( ទន្លេ ស្ទឹង អូរ ជ្រោះ ) | | ៤៤៧ | ០ |
| %គ្រួសារប្រើប្រាស់ទឹកពីប្រភពផ្សេងៗ( ទន្លេ ស្ទឹង អូរ ជ្រោះ ) | | ១៥,៣ | ០,០ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចុងដូង ខែឧសភា ឆ្នាំ២០១៨*

# ១.៣. ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

## ១.៣.១. ស្ថានភាពការកាន់កាប់ និងគ្រប់គ្រង

ផែនទី 7 ៖ ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំចុងដូង



ផែនទី ៤៖ ផែនទីប្រើប្រាស់ដីលម្អិត ឃុំចុងដូង



តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីនីមួយៗឃុំចុងដូង

| ប្រភេទដីប្រើប្រាស់ (ឈ្មោះហៅតាមបច្ចេកទេស) | បរិយាយ (ឈ្មោះហៅតាមអ្នកស្រុក) | ផ្ទៃដីទំហំ (ហិកតា) | ភាគរយ (%) |
|---|---|---|---|
| **ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ** | | **៤១៨,៦៦** | ៣,២៧ |
| **ក.១.ដីលំនៅឋានភូមិ** | | **៤១៨,៦៦** | ៣,២៧ |
| -ដីលំនៅឋានភូមិក្រៅតំបន់ការពារ | ដីភូមិ | ១៥៧,៣២ | ១,២៣ |
| -ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ដីភូមិ | ២២២,៣០ | ១,៧៤ |
| -ដីលំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ដីភូមិ | ៣៩,០៥ | ០,៣១ |
| **ខ.ដីកសិកម្ម** | | **៨ ८៩៦,៨៩** | **៦៩,៥៥** |
| **ខ.១.ដីស្រែវស្សា** | | **៤ ៥៦០,៦៤** | **៣៥,៦៥** |
| -ដីស្រែវស្សាក្រៅតំបន់ការពារ | ដីស្រែ | ៨៩៤,៥០ | ៦,៩៩ |
| -ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ដីស្រែ | ២ ២៦១,៩៨ | ១៧,៦៨ |
| -ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ដីស្រែ | ១ ៤០៤,២០ | ១០,៩៨ |
| **ខ.២.ដីស្រែប្រាំង** | | **៣១៣,២០** | ២,៤៥ |
| -ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ដីស្រែ | ២១៨,៨៥ | ១,៧១ |
| -ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ដីស្រែ | ៩៤,២១ | ០,៧៤ |
| **ខ.៣.ដីស្រែប្រាំងនិង ស្រែវស្សា** | | **៣ ៩៨១,៥០** | **៣១,១៣** |
| -ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ដីស្រែ | ៣ ៩៧៩,៥០ | ៤០,១៧ |
| -ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ដីស្រែ | ២,០១ | ០,០២ |
| **ខ.៤.ដីចម្ការ** | | ៤១,៥៦ | ០,៣២ |
| -ចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ចម្ការ | **២២,៤៣** | **០,១៨** |
| -ចម្ការក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ចម្ការ | **១៩,១៣** | **០,១៥** |
| **ឃ.ដីព្រៃឈើ/គម្របព្រៃ** | | **២ ៨៤៤,៤៣** | **២២,២៤** |
| **ឃ.១.ព្រៃគុម្ពោត** | | **១២៧,៧១** | **១,០០** |
| -ព្រៃគុម្ពោត ក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ព្រៃគុម្ពោត | ៨៨,៨៤ | ០,៦៩ |
| -ព្រៃគុម្ពោតក្នុងគម្របព្រៃឈើឆ្នាំ២០០២ ត្រួតតំបន់២ជុំវិញបឹងទន្លេសាប | ព្រៃគុម្ពោត | ៣៨,៨៧ | ០,៣០ |
| **ឃ.២.ព្រៃជាមួយចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប** | **ចម្ការ** | **២៨,៥៦** | ០,២២ |
| **ឃ.៣.ព្រៃលិចទឹក** | | **២ ៦៨៨,១៦** | ២១,០១ |

| | | | |
|---|---|---|---|
| **ង.ផ្ទៃទឹក និងខ្សែទឹក** | | **៥៩០,១៩** | ៤,៦១ |
| **ង.១.បឹង** | បឹង | **៤២៩,៨៧** | ៣,៣៦ |
| **ង.២.ស្ទឹង** | ស្ទឹង | **១៤៧,៧០** | ១,១៥ |
| **ង.៣.ស្រះ** | | **១២,៦១** | **០,១០** |
| -ស្រះ | ស្រះ | ១,៦៥ | ០,០១ |
| -ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ស្រះ | ២,៣០ | ០,០២ |
| -ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ស្រះ | ៨,៦៦ | ០,០៧ |
| **ផ្ទៃដីឃុំសរុប** | | **១២ ៧៩១,៧៤** | **១០០** |

### ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ

#### ក.១.ដីលំដីលំនៅឋានភូមិ

ដីលំនៅឋាន ភូមិ គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែនៅជុំវិញ។ នៅពេលបច្ចុប្បន្ននេះដីលំនៅឋាន ភូមិនៅក្នុងឃុំចុងដូងមានទំហំផ្ទៃដីសរុបចំនួន ៤១៨,៦៦ហិកតា ដែលស្ថិតនៅជាប់អមសងខាងផ្លូវជាតិលេខ៦ និងមួយចំនួនទៀតស្ថិតនៅខាងលិចផ្លូវជាតិលេខ៦ ចូលទៅក្នុងព្រមទាំងមានចំនួនតិចតួចស្ថិតនៅភាគខាងកើតនៃឃុំ ដែលនៅក្នុងបច្ចុប្បន្ននេះ បាននិងកំពុងប្រើប្រាស់ជាដីលំនៅឋាន ភូមិ ហើយស្ថិតនៅតាម ០៣តំបន់ផ្សេងគ្នា គឺក្រៅតំបន់ការពារ តំបន់១ជុំវិញបឹងទន្លេសាប និងតំបន់២ជុំវិញបឹងទន្លេសាបដូចមានរៀបរាប់ខាងក្រោមៈ

**-ដីលំនៅឋាន ភូមិក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប**

ដីលំនៅឋាន ភូមិក្រៅតំបន់ការពារជុំវិញបឹងទន្លេសាបមានពីរកន្លែងផ្សេងគ្នា មានទំហំផ្ទៃដីសរុបចំនួន ១៥៧,៣២ហិកតា ក្នុងនោះទីតាំងទី១ ស្ថិតនៅភាគខាងកើតនៃឃុំ មានចំនួន១ភូមិ គឺភូមិកំប៉ើយ និងទីតាំងទីពីរ ស្ថិតនៅតាមបណ្ដោយជាប់ផ្លូវជាតិលេខ៦ ដែលមានចំនួន ០៤ ភូមិ មានដូចជាភូមិទួលដំណាក់ ភូមិពពេជ ចុងដូង និងភូមិទួលសាលា(មួយផ្នែកស្ថិតនៅខាងកើតជាប់ផ្លូវជាតិលេខ៦ គឺស្ថិតនៅក្រៅតំបន់ការពារ និងមួយផ្នែកទៀតស្ថិតនៅខាងលិចជាប់ផ្លូវជាតិលេខ៦ គឺស្ថិតនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប)។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចុងដូង នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋាន ភូមិទាំងអស់ ជាតំបន់ដីដែលមានស្ថាពភាពរមៀលក្រួច និងដីជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីកណ្ដោង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ ជាដីដែលកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) តែមិនទាន់ត្រូវបានចុះបញ្ជីជាលក្ខណៈប្រព័ន្ធទេ។

**-ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានពីរទីតាំង ទំហំផ្ទៃដីចំនួន ២២២,៣០ហិកតា ក្នុងនោះទីតាំងទី១ស្ថិតនៅខាងលិចផ្លូវជាតិលេខ៦ចូលទៅក្នុង ដែលមានចំនួន ០១ភូមិ គឺភូមិខ្សាច់ល្អិត និងទីតាំងទីពីរស្ថិតនៅខាងលិចផ្លូវជាតិលេខ៦ ដែលមានចំនួន ០១ភូមិ គឺភូមិគួរ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចុងដូង នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋាន ភូមិទាំងអស់ ជាតំបន់ដីដែលមានស្ថាពភាពរមៀលក្រួច និងដីជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីកណ្ដោង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ ជាដីដែលកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) តែមិនទាន់ត្រូវបានចុះបញ្ជីជាលក្ខណៈប្រព័ន្ធទេ។

**-ដីលំនៅឋាន ភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីលំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានមួយទីតាំង និងមានទំហំផ្ទៃដីចំនួន ៣៩,០៥ ហិកតា ដែលស្ថិតនៅភាគខាងលិចនៃឃុំ ដែលបន្តពីដីតំបន់១ជុំវិញបឹងទន្លេសាប មានតែភូមិចំនួនមួយ គឺភូមិសំរោង ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចុងដូង នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋាន ភូមិទាំងអស់ ជាតំបន់ដីដែលមានស្ថាពភាពរមៀលក្រូច និងដីជម្រាលពីកើតទៅលិច មានប្រភេទជាដីល្បាយខ្សាច់ ដីកណ្តោង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធចាត់ចែងនោះឡើយ ។ ដីលំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាបពេលបច្ចុប្បន្ននេះត្រូវបានប្រជាពលរដ្ឋប្រើប្រាស់សម្រាប់តាំងលំនៅឋានរស់នៅ ។

រូបភាព 5៖ លំនៅឋានភូមិ

|  |  |  |
|---|---|---|
| លំនៅឋានភូមិក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប | លំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប | លំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប |

## ខ. ដីកសិកម្ម

### ខ.១.ដីស្រែវស្សា

បច្ចុប្បន្ននេះដីស្រែវស្សា នៅក្នុងឃុំចុងដូងមានទំហំផ្ទៃដីសរុបចំនួន ៤ ៥៦០,៦៤ហិកតា ភាគច្រើនស្ថិតនៅភាគខាងលិចជាប់ផ្លូវជាតិលេខ៦ និងមានចំនួនតិចតួចស្ថិតនៅភាគខាងកើតជាប់ផ្លូវជាតិលេខ៦ ដែលនៅក្នុងបច្ចុប្បន្ននេះបាននឹងកំពុងប្រើប្រាស់ជាដីស្រែវស្សា ហើយស្ថិតនៅតាម ០៣តំបន់ផ្សេងគ្នា គឺក្រៅតំបន់ការពារ តំបន់១ និងតំបន់២ជុំវិញបឹងទន្លេសាប ដូចមានរៀបរាប់ខាងក្រោម៖

**-ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីសរុបចំនួន ១៥៧,៣២ហិកតា ស្ថិតនៅខាងកើតជាប់នឹងផ្លូវជាតិលេខ៦ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចុងដូងនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែវស្សាទាំងអស់ គឺជាតំបន់ដីដែលមានស្ថាពភាពរមៀលក្រូច និងដីជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីកណ្តោង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ ជាដីកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) តែមិនទាន់ត្រូវបានចុះបញ្ជីជាលក្ខណៈប្រព័ន្ធទេ ។ ដីស្រែវស្សាទាំងនេះ មានមួយផ្នែកនៅក្បែរៗជាប់នឹងដីលំនៅឋានភូមិ ក្រោយពីច្រូតកាត់ស្រូវរួចប្រជាពលរដ្ឋ នៅក្នុងឃុំតែងនាំគ្នាដាំដំណាំរួមផ្សំថែមទៀតរួមមានដូចជា ពោត សណ្តែក ឳឡឹក និងបន្លែគ្រប់មុខជាដើម។ល។ ហើយដីទាំងនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងទំនប់១មករា។

**-ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីសរុបចំនួន ២ ២៦១,៩៨ហិកតា ដែលស្ថិតនៅភាគខាងលិចផ្លូវជាតិលេខ៦ ។ បើផ្អែកតាមផ្សាក្រាមពំនុះកាត់ទទឹងឃុំចុងដូងនៃរបាយការណ៍វិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន ដីស្រែវស្សាទាំងអស់ ជាតំបន់ដីដែលមានស្ថាពភាពរមៀលក្រួច និងដីជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីកណ្តោង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ ជាដីកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) តែមិនទាន់ត្រូវបានចុះបញ្ជីជាលក្ខណៈប្រព័ន្ធទេ ។ ដីស្រែវស្សាទាំងនេះ មានមួយផ្នែកនៅក្បែរៗជាប់នឹងដីលំនៅឋានភូមិ ក្រោយពីច្រូតកាត់ស្រូវរួចប្រជាពលរដ្ឋ នៅក្នុងឃុំតែងនាំគ្នាដាំដំណាំរួមផ្សំថែមទៀតរួមមានដូចជា ពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខជាដើម។ល។ ហើយដីទាំងនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងទំនប់១មករា។

**-ដីស្រែវស្សាក្នុងតំបន់២ ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីសរុបចំនួន ១ ៤០៤,២០ហិកតា ស្ថិតនៅភាគខាងលិចផ្លូវជាតិលេខ៦ បន្តពីដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ។ បើផ្អែកតាមផ្សាក្រាមពំនុះកាត់ទទឹងឃុំចុងដូង នៃរបាយការណ៍វិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន ដីស្រែវស្សានៅក្នុងតំបន់២ជុំវិញបឹងទន្លេសាប ដីស្រែវស្សាទាំងអស់ ជាតំបន់ដី ដែលមានស្ថាពភាពរមៀលក្រួច និងដីជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីកណ្តោង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមតែអាស្រ័យផលប៉ុណ្ណោះដោយមិនមានសិទ្ធិក្នុងការចាត់ចែងនោះឡើយ ។ ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងទំនប់១មករា។

រូបភាព 6៖ ដីស្រែវស្សា



ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប



ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប



ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប

## ខ.២.ដីស្រែប្រាំង

បច្ចុប្បន្ននេះ ដីស្រែប្រាំងក្នុងឃុំចុងដូង មានទំហំផ្ទៃដីសរុបចំនួន ៣១៣,២០ហិកតា ស្ថិតនៅភាគខាងលិចនៃឃុំ ហើយនៅបន្តពីដីស្រែប្រាំងនិងវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប រហូតដល់ដីព្រៃលិចទឹក ដែលនៅក្នុងបច្ចុប្បន្ននេះបាននិងកំពុងប្រើប្រាស់ជាដីស្រែប្រាំង ហើយស្ថិតនៅតាម ០២ ផ្សេងគ្នា គឺ តំបន់២ និងតំបន់៣ ដូចមានរៀបរាប់ខាងក្រោម៖

**- ដីស្រែប្រាំងក្នុងតំបន់២ ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងលិចនៃឃុំ ដែលមានទំហំផ្ទៃដីសរុបចំនួន ២១៨,៨៥ហិកតា បន្តពីដីស្រែប្រាំងនិងវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ។ បើផ្អែកទៅតាមផ្សាក្រាមពំនុះកាត់

ទទឹងឃុំចុងដូង នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងនៅក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាតំបន់មានស្ថាពភាពរមៀលក្រួច ទាបជាងតំបន់ទី I បន្តិច ជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីផេះព័ណ៌ខ្មៅ ដីកណ្តេង ក្រុមគោកគ្រប់ ក្រុមប្រទះឡាង និងក្រុមដីក្រគរ ជាដីសាធារណៈរបស់រដ្ឋ ដែលមិនទាន់បានចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធនោះទេ ហើយប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមតែកាន់កាប់អាស្រ័យផលប៉ុណ្ណោះដោយមិនមានសិទ្ធិក្នុងការចាត់ចែងនោះឡើយ ។ ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង បឹងរៀល បឹងលួងយ៉ាន់ និងបឹងបបែល ។

**-ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងលិចនៃឃុំមកទាល់តំបន់ការពារព្រៃលិចទឹក មានផ្ទៃដីសរុបចំនួន ៩៤,២១ហិកតា ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចុងដូងនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ជាតំបន់ទំនាបលិចទឹក ៤ខែ ទាបជាងតំបន់ទី II ជម្រាលពីកើតទៅលិច ជាប្រភេទដីល្បប់ និងក្រុមដីក្រគរ ជាដីសាធារណៈរបស់រដ្ឋ ស្ថិតក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប និងការសាងសង់សំណង់ថ្មីៗគ្រប់ប្រភេទបន្ថែមទៀត ។ នៅក្នុងករណីដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ ជាដីអាស្រ័យផលពិតប្រាកដរបស់ប្រជាពលរដ្ឋ ដែលរស់ក្នុងឃុំចុងដូងមែន ត្រូវស្នើសុំធ្វើការដោះស្រាយក្នុងការផ្តល់ដីស្រែក្នុងតំបន់នេះ ពីរាជរដ្ឋាភិបាល ដោយឈរលើឯកសារលិខិត បទដ្ឋានគតិយុត្តិ និងបទបញ្ជានានារបស់រាជរដ្ឋាភិបាល ហើយប្រសិនបើមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យឆ្មៀលដីនេះជូនមែន ក៏ដីទាំងអស់នេះមិនមែនជាកម្មសិទ្ធិរបស់ប្រជាជនដែរ ប្រជាជនគ្រាន់តែអាចមានសិទ្ធិកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ ដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង បឹងរៀល បឹងលួងយ៉ាន់ និងបឹងបបែល ។

រូបភាព 7៖ ដីស្រែប្រាំង

| | |
|---|---|
|  |  |
| ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប |

## ខ.៣.ដីស្រែប្រាំងនិងស្រែវស្សា

បច្ចុប្បន្ននេះ ដីស្រែប្រាំងនិងស្រែវស្សានៅក្នុងឃុំចុងដូងមានទំហំផ្ទៃដីសរុបចំនួន ៣ ៩៨១,៥០ ហិកតា ស្ថិតនៅប៉ែកកណ្តាលនៃឃុំដែលនៅក្នុងបច្ចុប្បន្ននេះបាននិងកំពុងប្រើប្រាស់ជាដីស្រែប្រាំងនិងស្រែវស្សា ហើយស្ថិតនៅតាម ០២ផ្សេងគ្នា គឺ តំបន់២ និងតំបន់៣ ដូចមានរៀបរាប់ខាងក្រោម៖

**-ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់២ ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងលិចនៃឃុំ ដែលមានទំហំផ្ទៃដីសរុបចំនួន៣ ៩៧៩,៥០ហិកតា នៅបន្តពីដីស្រែប្រាំងនិងស្រែវស្សានិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចុងដូង នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងនិងស្រែវស្សានៅក្នុងតំបន់២ជុំវិញបឹងទន្លេសាប។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចុងដូងនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាតំបន់មានស្ថាពភាពរមៀលក្រូច ទាបជាងតំបន់ទី၊ បន្តិច ជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីផេះព័ណ៌ខ្មៅ ដីកណ្ដេង ក្រុមគោកត្រប់ ក្រុមប្រទះឡាង និងក្រុមដីក្រគរ ជាដីសាធារណៈរបស់រដ្ឋ ដែលមិនទាន់បានចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធនោះទេ ហើយប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិក្នុងការចាត់ចែងនោះឡើយ ។ ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង បឹងរៀល បឹងលួងយ៉ាន់ និងបឹងបបែល ។

**-ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងលិចនៃឃុំ បន្តពីដីតំបន់២ជុំវិញបឹងទន្លេសាបមកទាល់ដីព្រៃលិចទឹក មានទំហំផ្ទៃដីសរុបចំនួន ២,០១ហិកតា ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចុងដូងនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានដីស្រែប្រាំងនិងស្រែវស្សានៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ជាតំបន់មានស្ថាពភាពរមៀលក្រូច ទាបជាងតំបន់ទី၊ បន្តិច ជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីផេះព័ណ៌ខ្មៅ ដីកណ្ដេង ក្រុមគោកត្រប់ ក្រុមប្រទះឡាង និងក្រុមដីក្រគរ ជាដីសាធារណៈរបស់រដ្ឋស្ថិតក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប និងការសាងសង់សំណង់ថ្មីៗគ្រប់ប្រភេទបន្ថែមទៀត ។ នៅក្នុងករណីដីស្រែប្រាំងនិងស្រែវស្សានៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ ជាដីអាស្រ័យផលពិតប្រាកដរបស់ប្រជាពលរដ្ឋ ដែលរស់ក្នុងឃុំចុងដូងមែន ត្រូវស្នើសុំធ្វើការដោះស្រាយក្នុងការផ្ដល់ដីស្រែក្នុងតំបន់នេះពីរាជរដ្ឋាភិបាល ដោយឈរលើឯកសារលិខិតបទ ដ្ឋានគតិយុត្តិ និងបទបញ្ជានានារបស់រាជរដ្ឋាភិបាល ហើយប្រសិនបើមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យឆ្វៀលដីនេះជូនមែន ក៏ដីទាំងអស់នេះ មិនមែនជាកម្មសិទ្ធិរបស់ប្រជាជនដែរ ប្រជាជនគ្រាន់តែអាចមានសិទ្ធិកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ។ដីស្រែប្រាំងនិងស្រែវស្សានៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង បឹងរៀល បឹងលួងយ៉ាន់ និងបឹងបបែល ។

រូបភាព ៩៖ ដីស្រែប្រាំង និង ស្រែវស្សា



ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប



ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប

## ខ.៤.ដីចម្ការ

នៅពេលបច្ចុប្បន្ននេះ ដីចម្ការនៅក្នុងចុងដូងមានទំហំផ្ទៃដីសរុបចំនួន ៤១,៥៦ហិកតា ស្ថិតនៅចុងភាគខាងជើងនៃឃុំ ហើយបច្ចុប្បន្នបាននិងកំពុងប្រើប្រាស់ជាដីចម្ការ ដែលស្ថិតនៅ០២តំបន់ផ្សេងៗគ្នា គឺតំបន់១ និងតំបន់២ជុំវិញបឹងទន្លេសាប ដូចមានរៀបរាប់ខាងក្រោម៖

**-ដីចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប មាន១ទីតាំង និងមានទំហំផ្ទៃដីសរុប ៣៤,៨៧ហិកតា ដែលស្ថិតនៅខាងចុងភាគខាងជើងនៃឃុំជាប់នឹងព្រំប្រទល់ឃុំត្នោតជុំ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងចុងដូង នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីចម្ការទាំងអស់ ជាតំបន់ដី ដែលមានស្ថាពភាពរមៀលក្រួច និងដីជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីកណ្តេង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាងនិងក្រុមដីព្រៃខ្មែរ ជាដីកម្មសិទ្ធិឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ តែមិនទាន់បានដំណើរការចុះបញ្ជីជាលក្ខណៈប្រព័ន្ធទេ និងមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងស្រះទឹកតែប៉ុណ្ណោះ ។

**-ដីចម្ការក្នុងតំបន់២ ជុំវិញបឹងទន្លេសាប**

ដីចម្ការក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីសរុបចំនួន ១៩,១៣ហិកតា ស្ថិតនៅចុងភាគខាងត្បូងនៃឃុំជាប់ជាមួយឃុំបារាយណ៍ហើយស្ថិតក្នុងតំបន់ការពារសត្វខ្សឹប បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចុងដូង នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីចម្ការក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាតំបន់ដី ដែលមានស្ថាពភាពរមៀលក្រួច និងដីជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីកណ្តេង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងអ្វីនោះឡើយ ។ ដីចម្ការនៅក្នុងតំបន់២ជុំវិញបឹងទន្លេសាបនេះ មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង បឹង និងស្រះទឹកជាដើម ។

រូបភាព ១៖ ចម្ការស្វាយចន្ទី



ចម្ការស្វាយចន្ទីក្នុងតំបន់១ជុំវិញបឹងទន្លេសាប



ចម្ការស្វាយចន្ទីក្នុងតំបន់២ជុំវិញបឹងទន្លេសាប

## ឃ. ដីព្រៃឈើ/គម្របព្រៃ

### ឃ.១.ព្រៃគុម្ពោត

នៅពេលបច្ចុប្បន្ននេះ ព្រៃគុម្ពោតនៅក្នុងឃុំចុងដូងមានទំហំផ្ទៃដីសរុបចំនួន ១២៧,៧១ ហិកតា ហើយបច្ចុប្បន្នបាននិងកំពុងប្រើប្រាស់ជាព្រៃគុម្ពោត ដែលស្ថិតនៅ០២តំបន់ផ្សេងៗគ្នា គឺតំបន់២ និងគម្របព្រៃឈើឆ្នាំ២០០២ត្រួតតំបន់២ជុំវិញបឹងទន្លេសាប ដូចមានរៀបរាប់ខាងក្រោម៖

**-ព្រៃគុម្ពោតក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ព្រៃគុម្ពោតក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីទួលមានទំហំតូចៗ និងមាន៣ទីតាំង ក្នុងនោះ២ទីតាំងស្ថិតនៅភាគខាងជើងនៃឃុំ និងមួយទីតាំងស្ថិតនៅប៉ែកកណ្តាលភាគខាងត្បូងនៃឃុំ ដែលសម្បូរទៅដោយដើមល្ពាក់ ញិញ ភ្លូ និងដើមដើមឈើធំៗមួយចំនួន ព្រមទាំងមានទំហំផ្ទៃដីសរុបចំនួន ៨៨,៨៤ ហិកតា ។ ដីព្រៃគុម្ពោត ជាតំបន់មានស្ថាពភាពរមៀលក្រួច ទាបជាងតំបន់ទី\ បន្តិច ជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីផេះព៌ណ៌ខ្មៅ ដីកណ្តោង ក្រុមគោកត្រប់ ក្រុមប្រទះឡាង និងក្រុមដីក្រគរ ជាដីសាធារណៈរបស់រដ្ឋ ។ បច្ចុប្បន្នដីព្រៃគុម្ពោត ត្រូវបាននិងកំពុងប្រើប្រាស់សម្រាប់ ទុកជាកន្លែងផ្តល់ស្មៅ និងស្លឹកឈើដល់គោ ក្របី និងជាកន្លែង ផ្តល់ខុសជុតចម្អិនអាហារ ។

**-ព្រៃគុម្ពោតក្នុងគម្របព្រៃឈើឆ្នាំ២០០២ត្រួតគ្នាតំបន់២ជុំវិញបឹងទន្លេសាប**

ព្រៃគុម្ពោតក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ត្រួតគ្នាតំបន់២ជុំវិញបឹងទន្លេសាប ជាព្រៃនៅជុំវិញមាត់បឹងស្ថិតនៅប៉ែកកណ្តាលភាគខាងត្បូងនៃឃុំ ដែលសម្បូរទៅដោយដើមភ្នំភ្លើង ត្រស់ កប្បាសព្រៃ ស្ទាច់ និងដើមរាំងជាដើម ព្រមទាំងមានទំហំផ្ទៃដីសរុបចំនួន ៣៨,៨៧ហិកតា ។ ដីព្រៃគុម្ពោត ជាតំបន់មានស្ថាពភាពរមៀលក្រួច ទាបជាងតំបន់ទី\ បន្តិច ជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីផេះព៌ណ៌ខ្មៅ ដីកណ្តោង ក្រុមគោកត្រប់ ក្រុមប្រទះឡាង និងក្រុមដីក្រគរ ជាដីសាធារណៈរបស់រដ្ឋ។ បច្ចុប្បន្នដីព្រៃគុម្ពោត ត្រូវបាននិងកំពុងប្រើប្រាស់សម្រាប់ ទុកជាកន្លែងផ្តល់ស្មៅ និងស្លឹកឈើដល់គោ ក្របី និងជាកន្លែងផ្តល់ខុសជុតចម្អិនអាហារ ។

រូបភាព 10៖ ព្រៃគុម្ពោត

| | |
|---|---|
|  |  |
| ព្រៃគុម្ពោត | ព្រៃគុម្ពោតក្នុងតំបន់២ជុំវិញបឹងទន្លេសាប |

### ឃ.២.ព្រៃជាមួយចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប

នៅក្នុងឃុំចុងដូង មានដីព្រៃជាមួយចម្ការ ទំហំផ្ទៃដីសរុបចំនួន ២៨,៥៦ហិកតា ស្ថិតនៅភាគខាងជើងឆៀងខាងកើតនៃឃុំជាប់ជាមួយព្រំប្រទល់ឃុំបល្ល័ង្គ ដែលមានសំបូរទៅដោយដើមឈើចម្រុះដុះលាយឡំគ្នាដូចជា ដើមខ្លុងត្បែង ត្រសេក និងចំបក់ជាដើម ។ល។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចុងដូង នៃរបាយការណ៍វិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន ដីព្រៃជាមួយចម្ការ ជាតំបន់ដីដែលមានស្ថាពភាពរមៀលក្រួច និងដីជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីកណ្ដេង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ ជាដីកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) តែមិនទាន់ត្រូវបានចុះបញ្ជីជាលក្ខណៈប្រព័ន្ធទេ ។ និងមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀងប៉ុណ្ណោះ ។

### ឃ.៣.ព្រៃលិចទឹក

ព្រៃលិចទឹកនៅក្នុងឃុំចុងដូង មានចំនួន ០១ កន្លែង ស្ថិតនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប នៅភាគខាងលិចនៃឃុំ ដែលមានទំហំផ្ទៃដីសរុបចំនួន ២ ៦៨៨,១៦ហិកតា ដែលសម្បូរទៅដោយដើមឈើចម្រុះដុះលាយឡំគ្នាដូចជាដើមភ្នំភ្លែង ត្រស់ កប្បាសព្រៃ ស្មាច់ និងដើមរាំងជាដើម ។ ព្រៃលិចទឹកទាំងអស់នេះត្រូវបានហាមដាច់ខាតក្នុងការកាប់រាន ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹក និងការសាងសង់សំណង់គ្រប់ប្រភេទ ។

រូបភាព 11៖ ព្រៃលិចទឹក



## គ.ផ្ទៃទឹក និងខ្សែទឹក

### គ.១.បឹង

នៅឃុំត្នោតជុំមានបឹងចំនួន ១០ កន្លែង ដូចជា បឹងរៀល បឹងលួងយ៉ាន់ បឹងត្រាវ បឹងអាផ្ទោល បឹងអាស្រូល បឹងត្រស់ បឹងត្រើយម៉ាកង បឹងរៀល បឹងផ្ទោល និងបឹងអាកង់ មានទំហំផ្ទៃដីសរុបចំនួន ៤២៩,៨៧ហិកតា ។ បឹងធម្មជាតិទាំងអស់នេះ ជាដីសាធារណៈរបស់រដ្ឋ បច្ចុប្បន្ននេះត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រពដំណាំកសិកម្ម ជាពិសេសស្រែប្រាំង និងប្រើប្រាស់ផ្សេងៗទៀតទៅតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

រូបភាព 12៖ បឹង



### គ.២.ស្ទឹង

នៅក្នុងឃុំឃុំចុងដូងមានស្ទឹងចំនួន ១ខ្សែ គឺស្ទឹងជីនិត ដែលមានទំហំផ្ទៃដីសរុបចំនួន ១៤៧,៧០ហិកតា ដែលជាដីសាធារណៈរបស់រដ្ឋ ហើយជាប្រភពទឹកដ៏សំខាន់សម្រាប់ស្រោចស្រពដំណាំស្រូវ និងដំណាំផ្សេងៗទៀត របស់ប្រជាពលរដ្ឋក្នុងឃុំ ព្រមទាំងជាប្រភពធនធានជលផលផងដែរ ។ ស្ទឹងនេះហូរកាត់ឃុំពីកើតទៅលិចផ្តល់ទឹកបានពេញមួយឆ្នាំ ។

រូបភាព 13៖ ស្ទឹង



### គ.៣.ស្រះ

បច្ចុប្បន្ននេះអាងស្តុកទឹកក្នុងឃុំចុងដូងមាន ១០ កន្លែង ទំហំផ្ទៃដីសរុបចំនួន ១២,៦១ហិកតា ភាគច្រើនស្ថិតនៅលាយឡំជាមួយដីលំនៅឋាន និងមានចំនួនតិចតួចនៅលាយឡំជាមួយនឹងដីស្រែ ដែលបច្ចុប្បន្នបាន និងកំពុងប្រើប្រាស់ជាស្រះ ហើយស្ថិតនៅតាម ០៤តំបន់ផ្សេងគ្នា គឺក្រៅតំបន់ការពារ តំបន់១ តំបន់២ និង តំបន់៣ ដូចមានរៀបរាប់ខាងក្រោម៖

**-ស្រះក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប**

ស្រះក្រៅតំបន់ការពារជុំវិញបឹងទន្លេសាបមានចំនួន ០៣កន្លែង ទំហំផ្ទៃដីសរុបចំនួន ១,៦៥ហិកតា នៅខាងកើតផ្លូវជាតិលេខ៦ ។ ស្រះអស់ទាំងនេះ ជាដីឯកជន ដែលបានកាន់កាប់និងប្រើប្រាស់ដោយប្រជាពលរដ្ឋ ហើយត្រូវបានប្រើប្រាស់សម្រាប់ជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

**-ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានចំនួន ៣ កន្លែង ទំហំផ្ទៃដីចំនួន ២,៣០ហិកតា ស្ថិតនៅភាគខាងលិចផ្លូវជាតិលេខ៦ ដែលស្រះទាំងអស់នេះ ជាដីឯកជនត្រូវបានកាន់កាប់និងប្រើប្រាស់ដោយប្រជាពលរដ្ឋ។ បច្ចុប្បន្នស្រះទាំងនេះ ប្រើប្រាស់សម្រាប់ជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតទៅតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

**-ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

នៅក្នុងឃុំចុងដូងមានស្រះចំនួន ៤ កន្លែង ទំហំផ្ទៃដីសរុប ៨,៦៦ ហិកតា ស្ថិតនៅភាគខាងលិចនៃឃុំ នៅក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមតែអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ នាពេលបច្ចុប្បន្នស្រះទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ជាប្រភពទឹកស្រោចស្រពនិងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

រូបភាព 14៖ ស្រះ



ស្រះក្រៅតំបន់ការពារ



ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាប



ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាប

ពាក់ព័ន្ធបញ្ហាផ្សេងៗ ក្នុងការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង តាមរយៈការសម្ភាសន៍ជាមួយក្រុមប្រឹក្សាឃុំ បានឱ្យដឹងថា មានប្រជាពលរដ្ឋក្នុងឃុំចំនួន ៣២ គ្រួសារ ដែលមិនមានដីសម្រាប់សាងសង់លំនៅឋាន និង២៨២ គ្រួសារទៀតមិនមានដីធ្វើកសិកម្ម ។ នៅក្នុងចំណោមប្រជាពលរដ្ឋទាំងនេះ មានមួយចំនួនរស់នៅលើដីចិញ្ចើមផ្លូវចំណីស្នឹង នៅលើដីកម្មសិទ្ធិរបស់គេផ្សេង ព្រមទាំងមួយចំនួនទៀតរស់នៅជាមួយឪពុកម្តាយ ។ ចំណែកបញ្ហាទំនាស់ក្នុងការប្រើប្រាស់ដីនៅក្នុងឃុំចុងដូងវិញ ពុំមានចេញជារូបភាពធំដុំ ដែលគួរឱ្យកត់សម្គាល់ឡើយ ទោះបីក្នុងឃុំពុំទាន់បានដំណើរការចុះបញ្ជីដីក៏ដោយ ។

### ១.៣.២. ផលិតកម្ម កសិកម្ម

#### ក. ផលិតកម្មដំណាំស្បៀង

ផលិតកម្មដំណាំស្បៀងនៅក្នុងឃុំចុងដូងបានផ្តោតសំខាន់ទៅលើផលិតកម្មដំណាំស្រូវ ហើយដំណាំនេះបានដើរតួយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍ឃុំដោយសារផលិតផលស្រូវ ។ ក្រៅពីទុកផ្គត់ផ្គង់សម្រាប់ការហូបចុក ហើយ ប្រជាពលរដ្ឋបានលក់ស្រូវ ដែលនៅសល់សម្រាប់បំពេញតម្រូវការចាយវាយចាំបាច់ ក្នុងជីវភាពរស់នៅផងដែរ ។ ដំណាំស្រូវបានធ្វើការដាំដុះនៅលើផ្ទៃដីទំហំ ៨ ៨៥៥,៣៤ ហិកតា ដែលជាប្រភេទល្បាយខ្សាច់ ដីកណ្តោង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ នៅប៉ែកខាងកើតដែលបច្ចុប្បន្នធ្វើស្រែបានតែម្តងគត់ គឺស្រូវវស្សា ហើយនិយមប្រើពូជស្រូវសែនក្រអូប ស្រូវ ៥០៤ ស្រូវផ្ការំដួល ស្រូវរាំងជ័យ ស្រូវខា ៨ ស្រូវ៤៩ ស្រូវខា៣ ស្រូវអង្គការក្រហម ស្រូវដំណើបនាងនួក ស្រូវដំណើបស្មាច់ ស្រូវនងម៉ន ស្រូវលាក់ស្លឹក ស្រូវផ្កាម្លិះ និងពូជស្រូវផ្ការមៀត ព្រមទាំងមានប្រភេទដីល្បាប់ ល្បាយខ្សាច់ ដីផេះពណ៌ខ្មៅ ដីកណ្តោង ក្រុមគោកត្រប់ក្រុមប្រទះឡាង និងក្រុមដីក្រគរ ចាប់ពីផ្នែកកណ្តាលទៅភាគខាងលិចឃុំ ដែលធ្វើស្រែបានពីរដងក្នុងមួយឆ្នាំ គឺស្រែប្រាំង និងស្រែវស្សា ហើយនិយមប្រើពូជស្រូវសែនក្រអូប ពូជស្រូវ ៥០៤ និងពូជស្រូវ ៤៩។ នៅឃុំចុងដូង ត្រូវបានប្រើប្រាស់ទឹកពីប្រភពទឹកភ្លៀង បឹងរៀល បឹងលួងយ៉ាន់ បឹងបបែល បឹងត្រាវ បឹងផ្ទោល បឹងត្រើយម៉ាកង និងបឹងរៀល ដោយប្រើប្រាស់ប្រព័ន្ធប្រឡាយមួយចំនួន ដែលបច្ចុប្បន្ននៅមានការខ្វះខាតនៅឡើយ ។ ជាទូទៅនៅក្នុងឃុំចុងដូង ប្រជាពលរដ្ឋទទួលបានទិន្នផលស្រូវវស្សាជាមធ្យម ២,៨តោន/ហ.ត និងស្រូវប្រាំងជាមធ្យម ៣តោន/ហ.ត ហើយក្នុងឆ្នាំ២០១៧នេះ ឃុំទទួលបានទិន្នផលស្រូវសរុបចំនួន ១៣ ៣៦៦ តោន ក្នុងនោះទិន្នផលស្រូវវស្សាមានចំនួន ១៣ ០៧៦ តោន និងស្រូវប្រាំងចំនួន ២៤០ តោន ។ ប្រជាពលរដ្ឋបានទុកស្រូវសម្រាប់បរិភោគ ៣០ភាគរយ ស្មើនឹង ៤០១០ តោន ទុកពូជ១០ភាគរយ ស្មើនឹង ១ ៣៣៧ តោន និងនៅសល់ ៦០ ភាគរយ ស្មើនឹង ៨ ០២០តោន បានធ្វើការលក់ចេញ ក្នុងតម្លៃជាមធ្យម ៨២១ រៀល/គ.ក្រ ដែលទទួលបានចំណូលសរុបប្រមាណ ៦ ៥៨៤ ០៩១ ៦០០ រៀល ។

តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ភាពរាំងស្ងួត<br>- សត្វល្អិតបំផ្លាញ និងជម្ងឺលើដំណាំស្រូវ<br>- ប្រើប្រាស់ពូជស្រូវតាមទម្លាប់<br>- ខ្វះបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម<br>- ខ្វះបច្ចេកទេសដាំ និងថែទាំដំណាំស្រូវ<br>- ប្រព័ន្ធប្រឡាយមានស្រាប់រងការខូចខាត (រាក់)<br>- ខ្វះខាតប្រព័ន្ធប្រឡាយនាំទឹកស្រចស្រព<br>- ខ្វះកម្លាំងពលកម្ម(ចំណាកស្រុកច្រើន) | - ដីស្រែធំទូលាយ រហូតដល់ ៦៤ % នៃផ្ទៃដីសរុប<br>- ស្ថានភាពដីស្រែជាវាលទំនាប អាចមានលទ្ធភាព នាំទឹកបឹងរៀល បឹងលួងយ៉ាន់ បឹងបបែល បឹងត្រាវ បឹងផ្ទោល បឹងត្រើយម៉ាកង និងបឹងរៀល មកផ្គត់ផ្គង់ការស្រោចស្រព ដើម្បីធ្វើស្រែបង្កើនរដូវ២-៣ដងក្នុងមួយឆ្នាំបាន<br>- មានប្រព័ន្ធប្រឡាយស្រាប់<br>- មានកម្លាំងពលកម្មច្រើន<br>- មានគោលការណ៍ជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងតួនាទីលើវិស័យកសិកម្ម<br>- មានគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ របស់រាជរដ្ឋាភិបាល។ |

### ខ. ផលិតកម្មដំណាំរួមផ្សំ

ផលិតកម្មដំណាំរួមផ្សំក្នុងឃុំចុងដូងបច្ចុប្បន្ន ប្រជាពលរដ្ឋបានដាំដំណាំមានដូចជា ស្ពៃ ត្រកួន ត្រសក់ សណ្តែក ននោង ល្ពៅ ដែលភាគច្រើន ប្រជាពលរដ្ឋធ្វើការដាំដុះលក្ខណៈគ្រួសារនៅជុំវិញដីលំនៅឋាន និងក្នុងស្រែវស្សា ដែលស្ថិតជិតលំនៅឋាន ជាដីល្បាយខ្សាច់ ដីកណ្តោង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ។ ដំណាំទាំងនេះទទួលបានការស្រោចស្រពពីប្រភពទឹក ប្រឡាយមេស្ទឹងជីនិត ប្រឡាយកំប៉ើយ ប្រឡាយត្នោតជុំ (CAVAC) ប្រឡាយណោងសានស្វាយរៀង ប្រឡាយតូច ប្រឡាយកងមាស ប្រឡាយត្រពាំងឈើទាល ហើយផលដែលទទួលបានគ្រាន់សម្រាប់ផ្គត់ផ្គង់ការហូបចុក និងលក់ដូរបន្តិចបន្តួច ដើម្បីបានកម្រៃខ្លះក្នុងការជួយបំពេញញការខ្វះខាតនៅក្នុងជីវភាពគ្រួសារតែប៉ុណ្ណោះ។

តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ការយល់ដឹងពីបច្ចេកទេសដាំដំណាំរបស់ប្រជាពលរដ្ឋនៅមានកម្រិត។<br>- សត្វល្អិតបំផ្លាញ<br>- ដំណាំកើតមានជម្ងឺ<br>- ខ្វះខាតទឹកស្រោចស្រពនៅរដូវប្រាំង | - មានដីនៅជុំវិញលំនៅឋាន<br>- មានប្រភពទឹកបឹង ស្រះ និងទឹកក្រោមដី សម្រាប់ការស្រោចស្រព<br>- ប្រជាពលរដ្ឋមានការយល់ដឹងពីសារៈប្រយោជន៍នៃដំណាំរួមផ្សំដែលអាចជួយផ្គត់ផ្គង់ដល់ការហូបចុក កាត់បន្ថយបានលើការចំណាយ ហើយបានលក់ខ្លះដោះស្រាយដល់ជីវភាពរស់នៅប្រចាំថ្ងៃ។ |

### គ. ផលិតកម្មឧស្សាហកម្ម

ផលិតកម្មដំណាំឧស្សាហកម្មបច្ចុប្បន្ននៅក្នុងឃុំចុងដូង ក៏បានដើរតួយ៉ាងសំខាន់ដែរក្នុងការអភិវឌ្ឍន៍ឃុំ បន្ទាប់ពីដំណាំស្រូវ ហើយត្រូវបានផលិតនៅលើផ្ទៃដី៤១,៥៦ ហិកតា ដែលជាដីល្បាយខ្សាច់ ដីកណ្តោង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ នៅលើទីតាំងដីចំនួនមួយកន្លែង ស្ថិតនៅភាគខាងជើងឃុំ ។ ដំណាំឧស្សាហកម្មទាំងនេះ ជាដំណាំស្វាយចន្ទី ដែលមិនមានទទួលបានការស្រោចស្រពបន្ថែមក្រៅពីទឹកភ្លៀងនោះទេ ។

តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| -ជួបគ្រោះរាំងស្ងួត<br>-ខ្វះខាតទឹកស្រោចស្រព<br>-ជួបប្រទះទឹកជំនន់(ទឹកភ្លៀង)<br>-សត្វល្អិតបំផ្លាញនិងជម្ងឺលើដំណាំ<br>-ដីខ្វះជីវជាតិ<br>-បច្ចេកទេសដាំ និងថែទាំដំណាំនៅមានកម្រិត<br>-តម្លៃនៅទីផ្សារមានការប្រែប្រួលមិនទៀងទាត់ | -មានផ្ទៃដី ០,៣៣% នៃផ្ទៃដីឃុំសរុប<br>-អាចពង្រីកផ្ទៃដីដាំដុះលើដំណាំនេះបាន<br>-មានប្រភពទឹកភ្លៀង បឹង សម្រាប់ការស្រោចស្រព<br>-មានបច្ចេកទេសដាំដុះនិងថែទាំដំណាំគ្រប់គ្រាន់ពីអ្នកជំនាញបច្ចេកទេសកសិកម្ម |

### ១.៣.៣. ធនធានធម្មជាតិ

#### ក. ធនធានព្រៃឈើ

បច្ចុប្បន្ននៅក្នុងឃុំចុងដូង មានធនធានព្រៃឈើគ្របដណ្តប់នៅលើផ្ទៃដីប្រមាណ ២ ៨៤៤.៤៣ហិកតា ស្មើនឹង ២២,២៤ភាគរយ នៃផ្ទៃដីឃុំទាំងមូល ដែលនៅក្នុងនោះមានប្រភេទព្រៃគុម្ពោត ព្រៃជាមួយដីចម្ការ និងព្រៃលិចទឹក ដែលមានទំហំផ្ទៃដីសរុបចំនួន ៨៨,៨៤ហិកតា សម្បូរទៅដោយដើមឈើដូចជា ក្រសាំង អំពិលកកោះ តាសេក ញិញ ព្រេច ភ្លូ និងខ្លុងតែ្បង ព្រមទាំងព្រៃលិចទឹកទំហំ ២៦៨៨,១៦ហិកតា នៅភាគខាងលិចឃុំក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ជាព្រៃដែលដុះតាមទំនាបលិចទឹកនិងជុំវិញបឹង សម្រាប់ផ្តល់ជីជាតិដល់ដី(ស្លឹកឈើពុកៗ)និងប្រើប្រាស់ជាឱសថុតសម្រាប់ចម្អិនអាហារ ជាកម្មសិទ្ធិរបស់រដ្ឋ ក្រៅពីនោះវាក៏ជាជម្រកសត្វមច្ឆា សត្វស្លាប និងសត្វផ្សេងៗមួយចំនួនផងដែរ ។

តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - មានការកាប់បំផ្លាញឈើសម្រាប់ធ្វើឧសដុត និង<br>- ប្រើប្រាស់ផ្សេងៗ<br>- មានការកាប់បំផ្លាញឈើដើម្បីយកដីកាន់កាប់<br>- ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផលប្រយោជន៍នៃដើមឈើនៅមានកម្រិត<br>- ការអនុវត្តច្បាប់ព្រៃឈើនូវមិនទាន់បានពេញលេញ<br>- ការផ្សព្វផ្សាយច្បាប់ពុំទាន់បានទូលំទូលាយនៅឡើយ | - មានច្បាប់និងអនុក្រឹត្យស្តីពីព្រៃឈើ<br>- មានសហគមន៍ព្រៃឈើការពារ<br>- មានដីព្រៃឈើធម្មជាតិ<br>- មានរដ្ឋបាលព្រៃឈើជាសមត្ថកិច្ចគ្រប់គ្រងព្រៃឈើ |

#### ខ. ធនធានជលផល

បច្ចុប្បន្នក្នុងឃុំចុងដូង មានបឹងចំនួន១២ ហើយភាគច្រើនស្ថិតនៅប៉ែកខាងលិចឃុំ ក្នុងតំបន់ស្រែប្រាំង និងស្រែវស្សា នៅក្នុងតំបន់២ និងតំបន់៣ជុំវិញបឹងទន្លេបឹងទន្លេសាប ដែលមានផ្ទៃដីសរុបទំហំ៤២៩,៨៧ហិកតា និងមានស្រះទឹកចំនួន ១០កន្លែង ដែលស្ថិតនៅលាយឡំជាមួយនឹងតំបន់លំនៅឋាន និងតំបន់ស្រែវស្សា ដែលភាគច្រើននៅប៉ែកកើតឃុំ ដែលមានផ្ទៃដីសរុបទំហំផ្ទៃដី ១២,៦១ ហិកតា ។ បឹង និងស្រះទាំងអស់នេះ មានធនធានជលផល ជាច្រើនប្រភេទមានដូចជា ត្រីរ៉ស់ ត្រីឆ្តោរ ត្រីអណ្តែង ត្រីក្រាញ់ ត្រីទីឡាបស្យា អន្ទង់ ក្តាម ខ្យង កង្កែប អណ្តើក និងពស់ជាដើម។ល។ ហើយត្រូវបានធ្វើការនេសាទដោយប្រជាជននៅក្នុងឃុំ ដែលជាលក្ខណៈគ្រួសារតាមរយៈការប្រើប្រាស់ឧបករណ៍ដូចជា សំណាញ់ មង ទ្រូ អួន សន្ទូច ជាលក្ខណៈប្រពៃណី ដែលផលនេសាទទាំងនេះបានសម្រាប់តែការហូបចុក និងលក់ដូរតិចតួចប៉ុណ្ណោះ ។

តារាង 27៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - មានការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតមិនសមស្របលើដំណាំកសិកម្ម នាំឱ្យមានការថយចុះបរិមាណធនធានជលផល<br>- ការប្រើឧបករណ៍នេសាទខុសច្បាប់។ | - មានបឹង អាងស្តុកទឹក ស្រះ និងស្រែ ដែលអំណោយផលដល់ធនធានជលផល<br>- មានច្បាប់ជលផល<br>- ប្រើប្រាស់ឧបករណ៍បែបប្រពៃណី ។ |

### ១.៣.៨. ធនធានរ៉ែ

នៅក្នុងឃុំចុងដូងទាំងមូល មិនមានទិន្នន័យពីជំនាញពាក់ព័ន្ធអំណះអំណាងពីវត្តមានធនធានរ៉ែនៅក្នុងឃុំគួរឱ្យកត់សម្គាល់បាននោះទេ គឺជាក់ស្តែងឃើញមានតែវាលស្រែគ្របដណ្តប់ស្ទើរទូទាំងឃុំប៉ុណ្ណោះ ។

## ១.៤.ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១.ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

បច្ចុប្បន្ននៅក្នុងឃុំចុងដូង មានតែផលិតផលស្រូវ ដែលអាចនាំចេញទៅរកទីផ្សារ ហើយផលិតផលស្រូវដែលនៅសល់ពីការហូបចុក អាចនាំទៅរកទីផ្សារមានប្រភេទស្រូវ ៥០៤ ស្រូវផ្ការំដួល និងស្រូវរាំងជ័យនិង គឺត្រូវបាននាំទៅរកទីផ្សារទាំងអស់ ។ បើយោងទៅតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំចុងដូង ឆ្នាំ ២០១៧ បានឱ្យដឹងថាប្រភេទស្រូវ ៥០៤ មានទីផ្សារនៅក្នុងប្រទេស និងមានទីផ្សារនៅប្រទេសវៀតណាម ដែលប្រជាពលរដ្ឋតែងតែលក់ស្រូវសើម តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំ មានតម្លៃត្រឹម ៧០០-៨០០រៀលក្នុងមួយគីឡូក្រាម ចំណែកស្រូវផ្ការំដួល មានទីផ្សារក្នុងប្រទេស និងទីផ្សារនៅប្រទេសប្រទេសវៀតណាម ដូចគ្នាដែលប្រជាពលរដ្ឋតែងតែលក់ស្រូវសើម តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំដែរ មានតម្លៃ ៩០០-១០៥០ រៀលក្នុងមួយគីឡូក្រាម ព្រមទាំងស្រូវរាំងជ័យ មានទីផ្សារក្នុងប្រទេស និងទីផ្សារនៅប្រទេសប្រទេសវៀតណាម ដូចគ្នា ដែលប្រជាពលរដ្ឋតែងតែលក់ស្រូវសើម តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំ មានតម្លៃត្រឹម ៨០០-៩០០ រៀលក្នុងមួយគីឡូក្រាម ។

តារាង 28៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ

| ល.រ | ប្រភេទផលិតផលស្រូវ | ឯកតា | តម្លៃជារៀល | ទីផ្សារ | |
|---|---|---|---|---|---|
| | | | | ក្នុងស្រុក | ក្រៅប្រទេស |
| ១ | ស្រូវ៥០៤ | ១ គ.ក្រ | ៧០០-៨០០ | | វៀតណាម |
| ២ | ស្រូវផ្ការំដួល | ១ គ.ក្រ | ៩០០-១ ០៥០ | | វៀតណាម |
| ៣ | ស្រូវរាំងជ័យ | ១ គ.ក្រ | ៨០០-៩០០ | | វៀតណាម |

### ១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល

តាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំចុងដូងឆ្នាំ ២០១៧ បានឱ្យដឹងថា បច្ចុប្បន្ននៅក្នុង ឃុំចុងដូង ការផលិតដំណាំស្រូវរហូតដល់បានផលលក់ចេញ គឺត្រូវដំណើរការតាមខ្សែសង្វាក់ជាបន្តបន្ទាប់ មានដូចជាការផលិតដំណាំស្រូវ ៥០៤ ចំពោះសម្រាប់ពូជត្រូវបានរក្សាទុកដោយខ្លួនឯង ១០ភាគរយ និងទិញពូជគេ ៩០ ភាគរយដែលមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជី និងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ដែលប្រើដោយគ្រឿងយន្ត ១០០ភាគរយ ហើយផលស្រូវ ដែលទទួលបាន ត្រូវបានហាលសម្ងួតទុកពូជ ១០ភាគរយ ចំណែកផលស្រូវនៅសើមដែលសល់ប្រមាណ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវនៅក្នុងឃុំ បានតម្លៃត្រឹមតែ ៧០០-៨០០ រៀលក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តយកទៅលក់ឱ្យទីផ្សារប្រទេសវៀតណាម និងមួយចំនួនទៀតបន្តលក់ទៅឱ្យរោងម៉ាស៊ីនកិនស្រូវ បានតម្លៃ ៧០០-៨០០ រៀលក្នុងមួយគីឡូក្រាមដូចគ្នា ។ ស្រូវផ្ការំដួល ដោយចាប់ផ្តើមពីការត្រៀមពូជស្រូវ ដែលភាគច្រើនបានរក្សាទុកដោយខ្លួនឯងចំនួន ៧០ភាគរយ និងមានការទិញចូល ៣០ភាគរយ ហើយមានការរៀបចំដីរួមទាំងការថែទាំ មានការដាក់ជី និងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ ច្រូតកាត់ ដោយប្រើប្រាស់គ្រឿងយន្តរហូតទៅ

ដល់ ៨០ភាគរយ និងច្រូតកាត់ដោយដៃតែ ២០ភាគរយ ប៉ុណ្ណោះ ។ ទិន្នផលស្រូវ ដែលទទួលបាន ត្រូវហាលសម្ងួត ៧០ភាគរយ ចំណែកផលស្រូវនៅសើម បានយកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃ ៩០០-១០៥០ រៀល ក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តលក់ឱ្យរោងម៉ាស៊ីនកិនស្រូវ យកទៅកិនកែច្នៃជាអង្ករនាំទៅទីផ្សារក្នុងប្រទេស និង ទីផ្សារក្រៅប្រទេស ចំណែកស្រូវរាំងជ័យវិញ ពូជស្រូវទុកទុកខ្លួនឯងចំនួន ៨០ភាគរយ និងទិញពូជ ២០ភាគរយ ពី គ្នាឯងក្នុងឃុំ ហើយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជី និងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ ដែលប្រើដោយគ្រឿងយន្ត ៩០ភាគរយ និងច្រូតដោយដៃ ១០ភាគរយ ចំណែកផលស្រូវ ដែលទទួលបាន ត្រូវបាន ហាលសម្ងួត ៨០ ភាគរយ ក្នុងនោះទុកពូជ ៥០ភាគរយ និងហូប ៣០ភាគរយ ចំណែកផលស្រូវនៅសើម ដែលសល់ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃត្រឹមតែ ៨០០-៩០០ រៀលក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តយក ទៅលក់ឱ្យទីផ្សារប្រទេសវៀតណាម ។

រូបភាព 15៖ ផលិតផលកសិកម្ម



## ដ្យាក្រាម 4៖ គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងភូមិ និង ការប្រើប្រាស់









### ១.៤.៣.ឧបសគ្គ និងឱកាស

តារាង 29៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ទីផ្សារនិងខ្សែសង្វាក់ផលិតផល

| ឧបសគ្គ | ឱកាស |
|---|---|
| - ឈ្មួញជាអ្នកកំណត់តម្លៃស្រូវ<br>- ឈ្មួញកណ្ដាលយកជី ថ្នាំ និងប្រេងមកបណ្ដាក់ដោយគិតការប្រាក់ខ្ពស់រហូតដល់២%ក្នុងមួយខែ ហើយទូទាត់នៅពេលប្រមូលផល<br>- កសិករប្រើពូជទុកខ្លួនឯងច្រើនជំនាន់<br>- ធាតុចូលកសិកម្មថ្លៃខ្ពស់<br>- តម្លៃស្រូវមិនទៀងទាត់(អាស្រ័យលើឈ្មួញ)<br>- ប្រើប្រាស់ពូជស្រូវវៀតណាម។ | - មានឈ្មួញមកទិញដល់កន្លែង<br>- មានភាពងាយស្រួលក្នុងការដឹកជញ្ជូនផលិតផលស្រូវ<br>- អាចប្រកួតប្រជែងតម្លៃជាមួយប្រទេសជិតខាង<br>- គុណភាពស្រូវស្របតាមស្តង់ដាសម្រាប់ការនាំចេញ<br>- តម្លៃអង្ករកើនឡើង និងទៀងទាត់<br>- ពូជស្រូវមានទិន្នផលខ្ពស់ និងតម្លៃខ្ពស់<br>- កែច្នៃចេញជាផលិតផលសម្រេច។ |

# ជំពូក ២៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត

## ២.១. តម្រូវការសម្រាប់អនាគត

### ២.១.១. ផែនការអភិវឌ្ឍន៍ឃុំ

ក. ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ (២០១៨-២០២២)

ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា តម្រូវការ ដែលជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព របស់ប្រជាពលរដ្ឋនៅក្នុងឃុំយ៉ាងមានប្រសិទ្ធភាព តាមរយៈការរៀបចំឱ្យមានតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំមួយ មានរយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិក្រុមប្រឹក្សាឃុំ។ តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំនេះ បានរំលេចនូវចក្ខុវិស័យអភិវឌ្ឍន៍ ដែលជាទស្សនៈរបស់ក្រុមប្រឹក្សាចង់បាន ដើម្បីកែប្រែជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ក៏បានរំលេចចេញឱ្យឃើញពីគោលបំណងអភិវឌ្ឍន៍ ដែលជាលទ្ធផលរួមរបស់ក្រុមប្រឹក្សា ព្រមទាំងគោលដៅអភិវឌ្ឍន៍ ដែលជាលទ្ធផលនានារបស់ក្រុមប្រឹក្សាចង់បាននៅតាមវិស័យនីមួយៗ។ទន្ទឹមនេះក៏បានរំលេចឱ្យឃើញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលបានកំណត់នូវវិធីសាស្ត្រឬសកម្មភាពត្រូវអនុវត្ត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍នីមួយៗខាងលើ ។

ចំណែកឃុំចុងដូង ក្រុមប្រឹក្សាឃុំក្នុងអាណត្តិ ២០១៨-២០២២ ក៏បានរៀបចំឱ្យមានផែនការអភិវឌ្ឍន៍ឃុំ រយៈពេលប្រាំឆ្នាំរបស់ខ្លួន ដែលនៅក្នុងនោះបានលើកឡើងពីគម្រោងវិនិយោគរយៈពេលប្រាំឆ្នាំទៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍឃុំ ដូចមានខ្លឹមសារ ដែលក្រុមការងារបានដកស្រង់បញ្ចូលក្នុងតារាងខាងក្រោម៖

តារាង 30៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត

| កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និង យុទ្ធសាស្ត្រ | | | | | |
|---|---|---|---|---|---|
| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជា អាទិភាព | លេខរៀងនៅលើផែនទី |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១.ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូនល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ប្រជាពលរដ្ឋក្នុងឃុំមានផ្លូវធ្វើដំណើរស្រួលចាប់ពីឆ្នាំ ២០១៨ | -កែលម្អជួសជុលផ្លូវ និងដាក់លូបង្ហូរទឹក<br>-សាងសង់ផ្លូវថ្មីបន្ថែម | -ជួសជុលផ្លូវក្រាលគ្រួសក្រហម<br>-សាងសង់ផ្លូវបេតុង<br>-ជួសជុលផ្លូវលំដីស<br>-ដាក់លូអមផ្លូវ | |
| ២.មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ប្រជាពលរដ្ឋមានប្រព័ន្ធស្រោចស្រពគ្រាប់គ្រាន់ | -ស្តារនិងជួសជុលប្រព័ន្ធធារាសាស្ត្រចាស់ៗឡើងវិញ<br>-សាងសង់ប្រព័ន្ធធារាសាស្ត្រថ្មីបន្ថែមទៀត | -ស្តារប្រឡាយស្រោចស្រព<br>-ជីកប្រឡាយថ្មី<br>-លើកទំនប់ទឹក<br>-សាងសង់ទ្វារទឹក<br>-ជួសជុលទ្វារទឹក<br>-ពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក<br>-ផ្តល់ម៉ាស៊ីនបូមទឹក<br>-ពង្រឹងគណៈកម្មការគ្រប់គ្រងធារាសាស្ត្រ | |

| | | | | | |
|---|---|---|---|---|---|
| ៣.កម្រិតអប់រំមានគ្រប់កម្រិត និងសិស្សបានចូលរៀនគ្រប់គ្នានៅក្នុងឃុំ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -បង្កើនការចូលរៀនកុមារអាយុ ៣-៤ ឆ្នាំឲ្យបាន ៩០% នៅឆ្នាំ ២០១៨<br>-កុមារអាយុ ៦-១៤ ឆ្នាំបានរៀនបញ្ចប់នូវកម្រិតមូលដ្ឋាន៩ឆ្នាំ<br>-ចំនួនអនក្ខរជននឹងថយនៅត្រឹម២% | -ពង្រឹងនិងពង្រីកផ្នែកមត្តេយ្យសាលាឱ្យបានគ្រប់មូលដ្ឋានភូមិ<br>-ជំរុញការយល់ដឹងដល់ឪពុកម្តាយកុមារពីតម្លៃសិក្សា<br>-ពង្រឹងកិច្ចសហការជាមួយមន្ទីរជំនាញ និងអង្គការនានាដើម្បីកាត់បន្ថយអនក្ខរកម្មរបស់ប្រជាពលរដ្ឋ | -បង្កើតថ្នាក់មត្តេយ្យ<br>-ផ្តល់គ្រូមត្តេយ្យ<br>-ផ្សព្វផ្សាយឱ្យឪពុកម្តាយនាំកូនចូលរៀន<br>-ផ្តល់សម្ភារៈសិក្សាដល់សិស្សក្រីក្រ<br>-ផ្តល់អាហាររូបករណ៍ដល់សិស្សក្រីក្រ<br>-អប់រំកុមារឱ្យយល់ដឹងពីតម្លៃនៃការសិក្សា<br>-បើកថ្នាក់អក្ខរកម្មឱ្យបានគ្រប់ភូមិ | |
| ៤.សុខភាពរបស់ប្រជាជនល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងសុខភាព និងអនាម័យរបស់ប្រជាជនបានល្អ | -បង្កើននិងកែលម្អសេវាសុខភាព និងចំណេះដឹងដល់ភ្នាក់ងារសុខភាពភូមិ | -ចាក់វ៉ាក់សាំងការពារជម្ងឺ៧មុខ<br>-ផ្តល់ថ្នាំជាតិដែក<br>-សំណើរសុំគ្រូពេទ្យ និងថ្នាំ<br>-ជួសជុលជីកអណ្តូងទឹកស្អាត<br>-ធ្វើទស្សនកិច្ចសិក្សាយកបទពិសោធន៍ ពីកន្លែងផ្សេងៗ<br>-បណ្តុះបណ្តាលស្ត្រីមេម៉ាយក្រីក្របង្កើតជាសមាគមន៍ក្រុមចេះជួយខ្លួនឯង<br>-សាងសង់បង្គន់អនាម័យ<br>-អប់រំ និងផ្សព្វផ្សាយអំពីជម្ងឺឆ្លងដូចជា របេង ថ្លើម គ្រុនចាញ់ និងគ្រុនឈាមជាដើម<br>-កម្មវិធីពន្យាកំណើត | |
| ៥.ឃុំមានបរិស្ថាន និង ធនធានធម្មជាតិស្រស់បំព្រង | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងនូវធនធានធម្មជាតិ | -បង្កើនសេវាលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | -បណ្តុះបណ្តាលច្បាប់ការពារព្រៃសហគមន៍<br>-បណ្តុះបណ្តាលច្បាប់វក្លាប្រមាញ់ និងនេសាទត្រីខុសច្បាប់<br>-ដាំកូនឈើតាមទីសាធារណៈ<br>-ស្តារត្រពាំងចាស់ៗ ឡើងវិញ<br>-ចិញ្ចឹមត្រីតាមគ្រួសារតាមគោលការណ៍ធម្មជាតិ | |
| ៦.ធ្វើឱ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្ត និងសុវត្ថិភាព | សាលាឃុំ | -ភូមិឃុំមានសន្តិសុខ និងសណ្តាប់ធ្នាប់ និងមានសុវត្ថិភាពល្អ | -ជម្រុញពង្រីកការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព<br>-ប្រជាពលរដ្ឋចូលរួមនិងបង្កើតក្រុមការពារភូមិ ដើម្បីរក្សាសន្តិសុខសណ្តាប់ធ្នាប់ភូមិ-ឃុំ | -បង្កើតប៉ុស្តិ៍ស្វ័យការពារតាមភូមិ<br>-បង្កើតក្រុមប្រជាជនការពារតាមភូមិឃុំ<br>-ផ្សព្វផ្សាយច្បាប់ភូមិបាលនិងច្បាប់ផ្សេងៗទៀត<br>-ចុះបញ្ជីអត្រានុកូលដ្ឋានបានគ្រ ប់ៗគ្នា<br>-ផ្សព្វផ្សាយអប់រំក្រុមក្មេងទំនើង<br>-អប់រំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន<br>-កាត់បន្ថយល្បែងស៊ីសងគ្រប់ប្រភេទ<br>-បំផុសឱ្យចូលរួមសហការណ៍ជាមួយសមត្ថកិច្ច | |

| | | | | | |
|---|---|---|---|---|---|
| ៧.លុបបំបាត់កាត់បន្ថយទំនាស់ដីធ្លី | សាលាឃុំ | -មានប័ណ្ណកម្មសិទ្ធិគ្រប់គ្រងដីធ្លីនិងយល់ច្បាស់ពីសិទ្ធិក្នុងការគ្រប់គ្រង | -ជំរុញឱ្យប្រជាពរដ្ឋបានយល់ដឹងពីច្បាប់ និងមានកម្មសិទ្ធិដីធ្លីដោយស្របច្បាប់<br>-បង្កើនការគ្រប់គ្រងដីធ្លីឱ្យស្របតាមគោលនយោបាយរបស់រដ្ឋ | -ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋ<br>-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ផ្សេងៗ<br>-ជំរុញឱ្យប្រជាពលរដ្ឋធ្វើរបង និងព្រំដីឲ្យបានច្បាស់លាស់ | |
| ៨.ទិន្នផលកសិកម្មកើនឡើង | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធានាស្បៀងហូបគ្រប់គ្រាន់ | -បង្កើនផលិតកសិកម្ម | -លើកទំនប់<br>-ជីកប្រឡាយ<br>-លូស្ពាក់ទឹក ទ្វារទឹក<br>-ពូជស្រូវល្អ<br>-ធ្វើជីកំប៉ុស្ត<br>-បច្ចេកទេសជីគីមី<br>-ចិញ្ចឹមសត្វ ត្រី<br>-ឈើហូបផ្លែ | |
| ៩.មានទឹកស្អាតសម្រាប់គ្រួសារប្រើប្រាស់ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០០៨-២០១២ | -ការរស់នៅមានអនាម័យតាមរយៈមានទឹកស្អាតប្រើប្រាស់ | -ពង្រីក និងកែលម្អប្រភពផ្គត់ផ្គង់ទឹក | -ជីកអណ្តូងលូ ស្នប់<br>ស្រះសហគមន៍<br>-ជួសជុលអណ្តូង<br>-បច្ចេកទេសចម្រោះទឹក | |
| ១០.សមភាព និងសមធម៌ក្នុងការរស់នៅ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងដល់ប្រជាជនគ្រប់រូបរស់នៅប្រកបដោយសមភាព សមធម៌គោរពគ្នាទៅវិញទៅមក | -បង្កើនការផ្សព្វផ្សាយច្បាប់និងលើកកម្ពស់មុខរបរ | -ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស<br>-ផ្សព្វផ្សាយច្បាប់អំពើហិង្សាក្នុងគ្រួសារ<br>-ផ្សព្វផ្សាយច្បាប់ជួញដូរស្ត្រីនិងកុមារ<br>-ពង្រឹងជនបង្គោលជាស្ត្រីតាមភូមិ<br>-ផ្សព្វផ្សាយច្បាប់កេងប្រវ័ញ្ចដល់កម្លាំងពលកម្មស្ត្រីនិងកុមារ<br>-បណ្តុះបណ្តាលពីតួនាទី យេនឌ័រ | |
| ១២.ទិន្នផលត្រីកើនឡើង | សាលាឃុំ | -បង្កើនធនធានជលផល | -ជំរុញការបង្កើតវារីវប្បកម្ម | -បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>-ជ្រើសរើសទីតាំងល្អ<br>-ផ្តល់ឥណទាននិងពូជ<br>-ផ្សព្វផ្សាយច្បាប់ជលផល<br>-បង្កើនការចិញ្ចឹមត្រីតាមគ្រួសារ<br>-អប់រំ និងផ្សព្វផ្សាយបំរាមនេសាទនៅរដូវត្រីពង | |
| ១៣.គ្រួសារចិញ្ចឹមសត្វកើនឡើង | សាលាឃុំ | -បង្កើនការចិញ្ចឹមសត្វបន្ថែមទៀត | -ជំរុញការផ្តល់បច្ចេកទេសជំនាញកសិកម្ម<br>-ជំរុញការផ្តល់បច្ចេកទេសចិញ្ចឹមថែទាំសុខភាពសត្វនិងជ្រើសរើសពូជ | -ចាក់វ៉ាក់សាំងការពារជម្ងឺគោក្របីឱ្យបានទៀងទាត់<br>-ផ្តល់ឥណទានគោក្របី<br>-ផ្តល់ឥណទានមានការប្រាក់ទាប | |
| ១៤.កាត់បន្ថយមរណមាតា និង | សាលាឃុំ | -បង្កើនការលុបបំបាត់អត្រាស្លាប់ | -ពង្រឹងនិងពង្រីកការផ្តល់សេវា | -ផ្សព្វផ្សាយដល់ស្ត្រីមានផ្ទៃពោះឱ្យទៅសម្រាលកូនដោយពេទ្យឆ្មប | |

| | | | | | |
|---|---|---|---|---|---|
| ទារកក្រោយសម្រាល | | មាតា និងទារកក្រោយសម្រាល | គាំពារសុខភាពមាតា និងទារក | -អប់រំឱ្យស្ត្រីចេះរបៀបការពារជម្ងឺឆ្លងកាមរោគ និងជម្ងឺអេដស៍<br>-មិនរើសអើង និងគាំទ្រដល់អ្នកកើតមេរោគអេដស៍<br>-ជំរុញឱ្យស្ត្រីមានផ្ទៃពោះទៅពិនិត្យពោះនៅមណ្ឌលសុខភាព<br>-ជំរុញឪពុកម្តាយយកកុមារទៅចាក់ថ្នាំការពារជម្ងឺ៧មុខ | |
| ១៥.ឱ្យមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់ផ្ទះ | សាលាឃុំ | -ទូទាំងឃុំមានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ | -ពង្រឹងកិច្ចសហការជាមួយអង្គភាពជំនាញដើម្បីជំរុញការផ្គត់ផ្គង់ថាមពលអគ្គិសនី | -រៀបចំបណ្តាញអគ្គិសនីតាមភូមិ | |

## ខ. គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតដែលបានអនុម័តរួច

នៅក្នុងឃុំចុងដូង បច្ចុប្បន្នមិនមានគម្រោងអភិវឌ្ឍន៍ណាមួយ ដែលត្រូវបានអនុម័តរួចដើម្បីជំណើរការជួយជំរុញក្នុងការអភិវឌ្ឍន៍ឃុំឡើយ ។

ផែនទី ១៖ ផែនទីគម្រោងអាទិភាពឃុំចុងដូង



### ២.១.២. ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២

ការព្យាករណ៍ពីកំណើនប្រជាជន ជាចំនុចសំខាន់ណាស់ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង ដែលអាចឱ្យយើងដឹងមុននូវចំនួនប្រជាជនក្នុងឃុំនេះរយៈពេល ១៥ឆ្នាំ ខាងមុខដ៏វែង អត្រាកំណើនជាមធ្យមរបស់ប្រជាពលរដ្ឋនៅក្នុងឃុំចុងដូង ដែលបានបង្ហាញនៅក្នុងជំពូក១ បានឱ្យដឹង គឺ ១,៦៩ភាគរយ ដូច្នេះប្រជាពលរដ្ឋ នៅក្នុងឃុំនឹងមានការកើនឡើងរហូតដល់ឆ្នាំ ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាពលរដ្ឋសរុបក្នុងឆ្នាំ ២០១៧ គឺ ១៣ ៧៤៨ នាក់

-អត្រាកំណើនមធ្យមប្រចាំឆ្នាំៈ ១,៦៩ %

-ចំនួនប្រជាជនកើនឡើងក្នុងរយៈពេល១ឆ្នាំៈ ១៣ ៧៤៨ នាក់ x ១,៦៩ % = ២៣២ នាក់/ឆ្នាំ

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាពលរដ្ឋកើនឡើងបានៈ២៣២នាក់/ឆ្នាំx១៥ឆ្នាំ = ៣ ៤៨០នាក់**

**-ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ខាងមុខមានៈ ១៣ ៧៤៨នាក់+៣៤៨០នាក់ = ១៧ ២២៨នាក់**

ចំណែកចំនួនគ្រួសារនៅក្នុងឃុំ នឹងមានការកើនឡើងនៅក្នុងឆ្នាំ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ២០១៧ គឺ ១៣ ៧៤៨ នាក់

-ចំនួនគ្រួសារសរុបក្នុងឆ្នាំ២០១៧ គឺ ៣ ០៩០ គ្រួសារ

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារក្នុងឆ្នាំ២០១៧ គឺៈ

**១៣ ៧៤៨ នាក់ /៣ ០៩០ គ្រួសារ = ៤,៤៥នាក់/គ្រួសារ**

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបានៈ

**៣៤៨០ នាក់/ ៤,៤៥នាក់/គ្រួសារ = ៧៨២គ្រួសារ**

-ដូច្នេះចំនួនគ្រួសារសរុបក្នុងរយៈពេល១៥ឆ្នាំខាងមុខទៀតមានៈ

**៣ ០៩០គ្រួសារ + ៧៨២គ្រួសារ = ៣៨៧២គ្រួសារ**

តារាង 31៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ)

| ឆ្នាំ | ចំនួនគ្រួសារ | ចំនួនប្រជាជន(នាក់) | |
|---|---|---|---|
| | | សរុប | ស្រី |
| ២០១៧ | ៣០៩០ | ១៣៧៤៨ | ៦៩៦១ |
| ២០២២ | ៣៣៥២ | ១៤៩០៧ | ៧៥៤៨ |
| ២០២៧ | ៣៦១៣ | ១៦០៦៦ | ៨១៣៥ |
| ២០៣២ | ៣៨៧២ | ១៧២២៨ | ៨៧២២ |

**☞ចំណាំ៖**

- ចំណោលប្រជាសាស្ត្រសម្រាប់១៥ឆ្នាំខាងមុខ៖ អត្រាកំណើនមធ្យមប្រចាំឆ្នាំ x ចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន/១០០
- ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើន៖ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ x ១៥
- ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ទៀតមាន៖ ចំនួនអត្រាកំណើនប្រជាជន១៥ខាងមុខ+ចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន

តារាង 32៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ)

| ស្ថិតិតាមក្រុមអាយុ | ២០១៧ | | ២០២២ | | ២០២៧ | | ២០៣២ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុពី០-២ឆ្នាំ | ៧៨៥ | ៣៩២ | ៨៥១ | ៤២៥ | ៩១៨ | ៤៥៨ | ៩៨៤ | ៤៩១ |
| អាយុពី៣-៤ | ៦២១ | ៣១៤ | ៦៧៣ | ៣៤១ | ៧២៦ | ៣៦៧ | ៧៧៨ | ៣៩៤ |
| អាយុ៥ឆ្នាំ | ៤១៦ | ២១១ | ៤៥១ | ២២៩ | ៤៨៦ | ២៤៧ | ៥២១ | ២៦៤ |
| អាយុ៦-១១ឆ្នាំ | ១៦៩៥ | ៨៨១ | ១,៨៣៨ | ៩៥៥ | ១,៩៨១ | ១,០៣០ | ២,១២៤ | ១១០៤ |
| អាយុ១២-១៤ឆ្នាំ | ៨១៩ | ៤២២ | ៨៨៨ | ៤៥៨ | ៩៥៧ | ៤៩៣ | ១,០២៦ | ៥២៩ |
| អាយុ១៥-១៧ឆ្នាំ | ៨៧០ | ៤៥៩ | ៩៤៣ | ៤៩៨ | ១០១៧ | ៥៣៦ | ១០៩០ | ៥៧៥ |
| អាយុ១៨-២៤ឆ្នាំ | ១៤២៦ | ៦៩៨ | ១៥៤៦ | ៧៥៧ | ១៦៦៦ | ៨១៦ | ១៧៨៧ | ៨៧៥ |
| អាយុ២៥-៦០ឆ្នាំ | ៥៣៩៥ | ២៧២៣ | ៥៨៥០ | ២៩៥៣ | ៦៣០៥ | ៣១៨២ | ៦៧៦០ | ៣៤១២ |
| អាយុ៦១ឆ្នាំ | ១៧២១ | ៨៦១ | ១៨៦៦ | ៩៣៤ | ២០១១ | ១០០៦ | ២១៥៦ | ១០៧៩ |
| ប្រជាជនសរុប | ១៣៧៤៨ | ៦៩៦១ | ១៤៩០៧ | ៧៥៤៨ | ១៦០៦៦ | ៨១៣៥ | ១៧២២៨ | ៨៧២២ |
| ចំនួនគ្រួសារ | ៣,០៩០ | | ៣,៣៥២ | | ៣,៦១៣ | | ៣,៨៧២ | |

### ២.១.៣. តម្រូវការដីធ្លីជាមូលដ្ឋាន

#### ក. ដីលំនៅឋាន

ចំពោះដីលំនៅឋានភូមិ គឺសំដៅទៅលើដីសម្រាប់សង់ផ្ទះ និងសម្រាប់សួនដំណាំជុំវិញផ្ទះតាមគ្រួសារ ។ នៅក្នុងឆ្នាំ ២០១៧ ដែលជាឆ្នាំគោល យើងបានដឹងថា ដីលំនៅឋានមានទំហំ ៤១៨,៦៦ ហិកតា និងមានគ្រួសារសរុបចំនួន ៣ ០៩០ គ្រួសារ ដែលនៅក្នុងនោះ ស្ថានភាពរស់នៅរបស់ប្រជាជនមានភាពសមស្របមិនមានបញ្ហាការខ្វះដីសម្រាប់លំនៅឋានឡើយ លើកលែងតែ ៣២គ្រួសារ ប៉ុណ្ណោះ ដែលមិនទាន់មានដីសម្រាប់សាងសង់លំនៅឋាន ហើយបច្ចុប្បន្នគ្រួសារទាំងនោះកំពុងរស់នៅលើដីចំណីប្រឡាយ និងផ្លូវ ដែលជាដីសាធារណៈ និងគ្រួសារមួយចំនួនទៀត គឺកំពុងរស់នៅលើដីកម្មសិទ្ធិរបស់អ្នកដទៃ (យោងតាមទិន្នន័យក្នុងជំពូកទី១ ត្រង់ចំណុច ១.៣.១ អំពីការកាន់កាប់ និងគ្រប់គ្រងការប្រើប្រាស់ដី) ដែលត្រូវយកចិត្តទុកដាក់ នៅក្នុងការដោះស្រាយជូនតាមរយៈដីសម្បទានដីសង្គមកិច្ច ដែលមានទីតាំងនៅខាងក្រៅឃុំ ទៅតាមការសម្រេចរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ច។

ក្នុងឆ្នាំ២០១៧ ផ្ទៃដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារមានចំនួន៖

**៤១៨,៦៦ ហិកតា/ ៣ ០៩០ គ្រួសារ = 0,១៤ហិកតា/ គ្រួសារ**

តែបើយោងទៅតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច បានចែងតម្រូវឱ្យមានដីលំនៅឋានយ៉ាងច្រើន0,២៥ហិកតាក្នុងមួយគ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូនទៅ ៣២ គ្រួសារ ដែលពួកគាត់គ្មានដីពិតប្រាកដ សម្រាប់លំនៅឋាន ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមាននៅទីតាំងផ្សេងក្រៅពីឃុំចុងដូងនេះ។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្ម ក្នុងចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងចំនួនៈ ៣ ៤៨០នាក់

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារមានៈ ៤,៤៥នាក់/គ្រួសារ

-តម្រូវការដីលំនៅឋានក្នុង១គ្រួសារមានចំនួន ០,១៤ហិកតា/គ្រួសារ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបានៈ

**៣ ៤៨០ នាក់/ ៤,៤៥នាក់/គ្រួសារ = ៧៨២គ្រួសារ**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីលំនៅឋានត្រូវកើនឡើងៈ**

**៧៨២គ្រួសារ x ០,១៤ហិកតា/គ្រួសារ = ១០៩,៤៨ហិកតា**

**-ដូច្នេះរហូតដល់ឆ្នាំ ២០៣២ ដីលំនៅឋាននៅក្នុងឃុំចុងដូងត្រូវកើនឡើងដល់ៈ**

**៤១៨,៦៦ ហិកតា + ១០៩,៤៨ហិកតា = ៥២៨,១៤ហិកតា**

ចំណែកការដោះស្រាយដីលំនៅឋាន ជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន៣២គ្រួសារតាមរយៈ សម្បទានសង្គមកិច្ចមានចំនួនៈ **៣២ គ្រួសារ x ០,២៥ ហិកតា/គ្រួសារ = ០៨ ហិកតា**

តារាង 33៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២

| **បរិយាយ** | **២០១៧ បច្ចុប្បន្ន** | **អនាគត ២០៣២** | **បម្រែបម្រួលតម្រូវការដី** |
|---|---|---|---|
| គ្រួសារ | ៣ ០៩០ គ្រួសារ | ៣ ៨៧២ គ្រួសារ | ៧៨២ គ្រួសារ |
| តម្រូវការដីលំនៅឋាន | ៤១៨,៦៦ ហិកតា | ៥២៨,១៤ហិកតា | ១០៩,៤៨ ហិកតា |

### ខ. ដីកសិកម្ម

ចំពោះដីកសិកម្ម គឺសំដៅទៅលើដីសម្រាប់ធ្វើស្រែ និងដីចម្ការដំណាំ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីកសិកម្មមានទំហំ ៨ ៨៥៥,៣៤ ហិកតា និងមានគ្រួសារសរុបចំនួន ៣ ០៩០ គ្រួសារ អាចធ្វើស្រែផលិតស្រូវបានសល់ពីការហូបចុកខ្លះ សម្រាប់ការនាំចេញទៅទីផ្សារ ដើម្បីដោះស្រាយជីវភាព គឺជាស្ថានភាពដែលប្រជាពលរដ្ឋអាចរស់នៅក្នុងជីវភាពសមរម្យបាន លើកលែងតែគ្រួសារចំនួន ២៨២ គ្រួសារប៉ុណ្ណោះដែលមិនមានដីសម្រាប់ធ្វើកសិកម្មផ្ទាល់ខ្លួន និងមួយចំនួនស៊ីឈ្នួលគេ ។

ដូច្នេះបច្ចុប្បន្នទំហំដីកសិកម្មសម្រាប់មួយគ្រួសារជាមធ្យមមានចំនួន៖

**៨ ៨៥៥,៣៤ ហិកតា / ៣ ០៩០ គ្រួសារ = ២,៨៧ហិកតា/ គ្រួសារ**

តែបើយោងតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីកសិកម្មយ៉ាងច្រើន ២ហិកតា នៅក្នុង១គ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូនទៅ២៨២គ្រួសារ ដែលគ្មានដីពិតប្រាកដសម្រាប់ធ្វើកសិកម្ម ជាលក្ខណៈគ្រួសារ ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមាននៅទីតាំងផ្សេងពីឃុំចុងដូង។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជន ដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ គ្រួសារកើនឡើងចំនួនៈ ៣៣១គ្រួសារ

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីកសិកម្មត្រូវកើនឡើងៈ**

៧៨២គ្រួសារ x **២,៨៧ហិកតា/គ្រួសារ = ២ ២៤៤,៣៤ ហិកតា**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីកសិកម្មសរុបមានចំនួនៈ**

**៨ ៨៥៥,៣៤ ហិកតា + ២ ២៤៤,៣៤ ហិកតា = ១១ ០៩៩,៦៨ ហិកតា**

ចំណែកការដោះស្រាយដីកសិកម្មជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន ២៨២គ្រួសារ តាមរយៈសម្បទានសង្គមកិច្ចមានទំហំដីចំនួន ៥៦៤ហិកតា។

**២៨២គ្រួសារ x ២ ហិកតា/គ្រួសារ = ៥៦៤ហិកតា**

តារាង 34៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២

| បរិយាយ | ២០១៧ បច្ចុប្បន្ន | អនាគត ២០៣២ | បម្រែបម្រួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ | ៣ ០៩០ គ្រួសារ | ៣៨៧២ គ្រួសារ | ៧៨២ គ្រួសារ |
| តម្រូវការដីស្រែ | ៨ ៨៥៥,៣៤ ហិកតា | ១១ ០៩៩,៦៨ ហិកតា | ២ ២៤៤,៣៤ ហិកតា |

### គ. ដីព្រៃឈើ

ព្រៃឈើផ្តល់នូវផលិតផលនានាដូចជា ឈើហ៊ុប ឈើគ្រឿងសង្ហារឹម ឈើបង្គោលឧសនិងអនុផលនានា មានជ័រ វល្លិ ឱសថ ដែលបានគាំទ្រដល់ការចិញ្ចឹមជីវិត របស់ប្រជាជននៅជនបទតាមរយៈការប្រើប្រាស់ដោយផ្ទាល់ ឬតាមរយៈការលក់ដូរ ។ ទន្ទឹមនេះ ព្រៃឈើ ក៏បានដើរតួយ៉ាងសំខាន់ក្នុងចំណោមតួនាទីដទៃទៀត ដូចជាការទាក់ទាញទឹកភ្លៀង បញ្ចុះសីតុណ្ហភាព អាកាសធាតុបរិសុទ្ធ(ផ្តល់ខ្យល់អាកាសបរិសុទ្ធ) បញ្ចេញឧស្ម័នអុកស៊ីសែន(ជួយស្រូបយកឧស្ម័នកាបូនិច និងបញ្ចេញឧស្ម័នអុកស៊ីសែនដល់មនុស្សសត្វ) ការពារគ្រោះធម្មជាតិ (ជួយទប់ទល់ខ្យល់ព្យុះ ទឹកជំនន់ ការពារការហូរច្រោះដី និងបាក់ដី) ធ្វើឱ្យដីមានជីជាតិ ជាតំបន់ទេសចរ ធម្មជាតិ។ ចំណែកព្រៃលិចទឹកសាប ជាជម្រកត្រីពង ផ្តល់ជីជាតិដី សម្រាប់ធ្វើកសិកម្ម រក្សាជីវសាស្ត្រចម្រុះ ។

ចំពោះឃុំចុងដូង មានដីព្រៃឈើ ២ ៧៧៨,០១ ហិកតា ស្មើនឹង ២២ភាគរយ នៃផ្ទៃដីឃុំទាំងមូល ដែលនៅពេលអនាគតឃុំ មិនអាចមានលទ្ធភាពពង្រីកដីបន្ថែមសម្រាប់ព្រៃឈើនោះទេ តែនៅក្នុងឃុំមានលទ្ធភាពក្នុងការដាំដើមឈើបន្ថែមលើដីសាធារណៈផ្សេងៗ ដូចជាតាមដងផ្លូវ ប្រឡាយ សាលាឃុំ សាលារៀន មណ្ឌលសុខភាព និងនៅតាមវត្តអារាមជាដើម សម្រាប់ជាម្លប់ ពណ៌បៃតង ធ្វើឱ្យដីមានជីជាតិ ផ្តល់អុកស៊ីសែន ស្រូបឧស្ម័នកាបូនិកជួយដល់សុខភាពប្រជាពលរដ្ឋ ។ល។

### ឃ. ធនធានទឹក

ឃុំចុងដូង ជាឃុំមានសក្តានុពលទៅលើផ្នែកកសិកម្ម ដំណាំស្រូវ និងចម្ការដំណាំឧស្សាហកម្ម ដែលនាំឱ្យឃុំចុងដូង មានគោលដៅអភិវឌ្ឍន៍រយៈពេលវែងរបស់ខ្លួនផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវ និងចម្ការដំណាំឧស្សាហកម្មនេះមិនអាចគេចចេញបានឡើយ ។ ដូច្នេះដើម្បីជំរុញវិស័យកសិកម្មដំណាំស្រូវ កត្តាចាំបាច់មួយក្នុងចំណោមកត្តាជាច្រើន គឺមានទឹក ដែលជាកត្តាសំខាន់ ត្រូវយកចិត្តទុកដាក់ ដោយត្រូវធ្វើយ៉ាងណាឱ្យមានទឹកគ្រប់គ្រាន់សម្រាប់ការស្រោចស្រពបានគ្រប់រដូវកាលទៅលើដីស្រែ និងចម្ការដែលឃុំមាន ដើម្បីដោះស្រាយទឹកពេលមានគ្រោះរាំងស្ងួត និងធ្វើស្រែបង្កើនរដូវឱ្យទទួលបានផលិតភាពខ្ពស់ ដើម្បីជួយផ្គត់ផ្គង់ដល់ការហូបចុក និងជំរុញការនាំចេញ សម្រាប់បង្កើនសេដ្ឋកិច្ចគ្រួសារក៏ដូចសេដ្ឋកិច្ចជាតិ ដើម្បីឆ្លើយតបបានទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។

ចំពោះឃុំចុងដូង បច្ចុប្បន្នមានស្ទឹង បឹងនិងស្រះទឹក ដែលជាប្រភពទឹកបន្ថែមដែលមានផ្ទៃដីសរុបទំហំ ៥៩០,១៨ហិកតា ស្មើនឹង ៣,៤៧%នៃផ្ទៃដីឃុំសរុប ដូច្នេះនៅក្នុងពេលអនាគតឃុំចុងដូង ត្រូវការប្រើប្រាស់ដីបន្ថែមនៅក្នុងតំបន់ដីស្រែ សម្រាប់ការរៀបចំប្រព័ន្ធប្រឡាយបង្ហូរទឹក ១៥ខ្សែ ប្រវែង ២៣ ៨៤៣ម៉ែត្រ ដែល

នៅក្នុងនោះមានប្រឡាយមេសាងសង់ថ្មី១ខ្សែ ប្រវែង ២ ៦៩៧ម៉ែត្រ ប្រឡាយរងសាងសង់ថ្មី១ខ្សែ ប្រវែង ១ ៣៤៣ម៉ែត្រ និងប្រឡាយតូចៗសាងសង់ថ្មីៗចំនួន ០៥ខ្សែ ប្រវែង ៨ ២៤៨ម៉ែត្រ និងស្ពានប្រឡាយតូចៗ ចំនួន៨ខ្សែ ប្រវែង ១១ ៥៥៥ម៉ែត្រ បន្ថែមទៅលើប្រព័ន្ធស្រោចស្រព ដែលមានស្រាប់ សម្រាប់នាំទឹកមក ស្រោចស្រពដំណាំស្រូវនៅរដូវប្រាំង និងនៅពេលមានគ្រោះរាំងស្ងួត ហើយក៏អាចជាជម្រកត្រីនាំឱ្យកើនឡើង បរិមាណត្រី បូកផ្សំជាមួយការយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រីតាមបែបចិញ្ចឹម នៅក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹម ត្រីតាមគ្រួសារ លាយ ឡំជាមួយបន្លែចម្រុះ និងកសិដ្ឋានចិញ្ចឹមត្រីនៅក្នុងស្រែ ដែលជាទម្រង់មួយនៃ វារីវប្បកម្ម ដែលជាបច្ចេកទេសមួយជួយដើម្បីបង្កើនបរិមាណត្រីដោយអាចបង្កើនផលិតភាពជលផលនៅតាមវាលស្រែ ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងក្នុងស្រែដែលបំផ្លាញផលស្រូវផង ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់បំផុតសម្រាប់ទ្រទ្រង់សុខភាព និងជីវិតរស់នៅអោយមានភាពល្អប្រសើរ ។

### ង. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត

#### ង.១. វិស័យអប់រំ

កុមារគ្រប់រូប អាចមានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ ។ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យពួកគេអាចអភិវឌ្ឍខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ ។ យ៉ាងណាមិញនៅក្នុងឃុំចុងដូង រយៈពេល១៥ឆ្នាំទៅមុខនឹងមានការកើនឡើងនូវចំនួនកុមារ និងមនុស្សវ័យជំទង់ក្នុងវ័យសិក្សា ដូចមានការគណនានៅក្នុងចំណុច ២.១.២ ស្តីពីចំណោលប្រជាសាស្ត្រខាងលើ ដែលចាំបាច់ត្រូវតែគិតគូរដោះស្រាយបន្ទប់រៀនបន្ថែម នៅគ្រប់កម្រិតនៅតាមទីតាំងសាលារៀនដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន ។

❖ **មត្តេយ្យសិក្សា:**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ កុមារមានអាយុពី៣-៥ឆ្នាំ នឹងកើនឡើងចំនួនៈ ១ ២៩៩ នាក់

-តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ បានឱ្យដឹងពីការកំណត់សម្រាប់មត្តេយ្យសាលាក្នុងមួយថ្នាក់មានចំណុះកុមារសិក្សារៀនសូត្រ **៥០នាក់**

**-ដូច្នេះក្នុងរយៈពេល ១៥ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់មត្តេយ្យត្រូវការបន្ថែមចំនួនៈ**

**១ ២៩៩ នាក់ /៥០ នាក់/បន្ទប់= ២៦បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ**

**២៦បន្ទប់ /៥ បន្ទប់/អគារ= ៥ អគារ**

❖ **បឋមសិក្សា**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ៦-១១ ឆ្នាំនឹងកើនឡើងចំនួនៈ ២១២៤នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់បឋមសិក្សាត្រូវការបន្ថែមចំនួនៈ**

២១២៤នាក់ ៖ **៤៥នាក់/បន្ទប់ = ៤៧បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៦ បន្ទប់បន្ថែមចំនួនៈ**

**៤៧បន្ទប់ ៖ ៦ បន្ទប់/អគារ = ៨ អគារ**

-តែក្នុងករណីត្រូវរៀន**២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាវតែចំនួនៈ**

**៨អគារ/វេន ៖ ២ វេន = ៤អគារ**

❖ **អនុវិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១២-១៤ ឆ្នាំនឹងកើនឡើងចំនួនៈ ១ ០២៦ នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ**

**១ ០២៦ នាក់ ៖ ៤៥នាក់/បន្ទប់ = ២៣ បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ១២ បន្ទប់បន្ថែមចំនួនៈ**

**២៣ បន្ទប់ ៖ ១២បន្ទប់/អគារ = ២អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

**២ អគារ / វេន ៖ ២ វេន = ១អគារ**

❖ **វិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១៥-១៧ឆ្នាំនឹងកើនឡើងចំនួនៈ ១០៩០ នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ**

**១០៩០ នាក់ ៖ ៤៥នាក់/បន្ទប់ = ២៤ បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ១២ បន្ទប់បន្ថែមចំនួនៈ**

**២៤ បន្ទប់ ៖ ១២បន្ទប់/អគារ = ២ អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

**២អគារ / វេន ៖ ២ វេន = ១អគារ**

តារាង 35៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២

| **បរិយាយ** | **បច្ចុប្បន្ន២០១៧** | **អនាគត ២០៣២** | **បម្រែបម្រួល** |
|---|---|---|---|
| **សាលាមត្តេយ្យ** | | | |
| សិស្ស | ៤៥ នាក់ | ១ ២៩៩ នាក់ | ១២៥៤ នាក់ |
| បន្ទប់ | ២ បន្ទប់ | ២៦ បន្ទប់ | ២៤ បន្ទប់ |
| អគារ | ២ អគារ | ៥ អគារ | ៣ អគារ |
| **សាលាបឋមសិក្សា** | | | |
| សិស្ស | ១៦២៦ នាក់ | ២១២៤ នាក់ | ៤៩៨ នាក់ |
| បន្ទប់ | ៥៧ បន្ទប់ | ៤៧ បន្ទប់ | -១០បន្ទប់ |
| អគារ | ០៧ អគារ | ៨ អគារ | ១អគារ |
| **អនុវិទ្យាល័យ** | | | |
| សិស្ស | ៥៤៥ នាក់ | ១ ០២៦ នាក់ | ៤៨១ នាក់ |
| បន្ទប់ | ១១ បន្ទប់ | ២៣ បន្ទប់ | ១២ បន្ទប់ |
| អគារ | ០១ អគារ | ២ អគារ | ០១ អគារ |
| **វិទ្យាល័យ** | | | |
| សិស្ស | 0 | ១០៩០ នាក់ | ១០៩០ នាក់ |

| | | | |
|---|---|---|---|
| បន្ទប់ | ០ | ២៤ បន្ទប់ | ២៤ បន្ទប់ |
| អគារ | ០ | ២ អគារ | ២ អគារ |

### ង.២. វិស័យសុខាភិបាល

នៅក្នុងឃុំចុងដូង មានមណ្ឌលសុខភាព ០១កន្លែង ដែលស្ថិតនៅភូមិទួលដំណាក់ ហើយបើផ្អែកទៅតាមកំណើនប្រជាជន ដែលមានការកើនឡើងនៅពេលខាងមុខ និងស្ថានភាពភូមិសាស្ត្ររបស់ឃុំទាំងមូល យើងឃើញថាមិនមានភូមិ ដែលនៅឆ្ងាយពីមណ្ឌលសុខភាពនោះទេ ។ ថ្ងៃអនាគត១៥ឆ្នាំទៅមុខ នឹងមិនមានផែនការបង្កើនបន្ថែមមណ្ឌលសុខភាពនោះទេគ្រាន់តែជំរុញការផ្តល់សេវាពីមណ្ឌលសុខភាពមួយនេះជូនដល់ប្រជាពលរដ្ឋនៅក្នុងឃុំឱ្យបានប្រសើរឡើងតែប៉ុណ្ណោះ ហើយក៏នឹងអាចផ្តល់លទ្ធភាពទៅឱ្យមានគ្លីនិច ឯកជនបំពេញបន្ថែមទៀតផងដែរ ។

### ង.៣. អគ្គិសនី

អគ្គិសនី គឺពិតជាមានសារៈសំខាន់ណាស់ សម្រាប់ជីវិតរស់នៅរបស់មនុស្សយើង ។ អគ្គិសនីផ្តល់ឱ្យយើងនូវសន្តិសុខ សុវត្ថិភាព សុខភាព និងភាពសម្បូររុងរឿង ដូចជាជួយដោះស្រាយបញ្ហា និងធ្វើឱ្យកាន់តែប្រសើរឡើងនូវសន្តិសុខ សុវត្ថិភាព ការប្រែប្រួលអាកាសធាតុ ផលិតកម្មស្បៀងអាហារ និងការពង្រឹងសេដ្ឋកិច្ចដោយរួមទាំងការអប់រំ និងកម្សាន្តផងដែរ។

ចំពោះស្ថានភាពការប្រើប្រាស់អគ្គិសនី នៅក្នុងឃុំចុងដូង ដូចបានរៀបរាប់ក្នុងជំពូកទី១ ដែលបច្ចុប្បន្ននៅក្នុងឃុំចុងដូង ប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីមាន ២ ៨៩៨ ខ្នងផ្ទះ ស្មើនឹង ៩៩,១ ភាគរយ ។ ដូច្នេះ នាពេលអនាគត ១៥ឆ្នាំទៅមុខ នឹងមានការកើនឡើងចំនួនគ្រួសារថែមទៀត ដែលអាជ្ញាធរពាក់ព័ន្ធនៅគ្រប់ជាន់ថ្នាក់ ជាពិសេសក្រុមប្រឹក្សាឃុំចុងដូង ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការដោះស្រាយពង្រីកបណ្តាញអគ្គិសនី តភ្ជាប់ផ្គត់ផ្គង់ឱ្យដល់គ្រប់គ្រួសារបានប្រើប្រាស់ ។

### ង.៤. ទីលានចាក់សំរាម

សំរាម គឺជាកាកសំណល់ដែលគេបានបោះបង់ចោល វាមានពីរប្រភេទ គឺកាកសំណល់រឹងនិងរាវ។ ដូច្នេះសំរាម គឺជាអ្វីដែលបំបែកចេញពីបរិស្ថានយើង និងអាចបង្កើតកន្លែងគរមួយផ្សេងទៀត ប្រសិនបើយើងមិនប្រុងប្រយ័ត្ន ។ គំនរសំរាម បានមកពីកាកសំណល់ផ្ទះបាយ ដែលដាក់លាយឡំចូលគ្នាជាមួយនឹង អំបែងកែវ អំបែងចាន និងអំបែងដបជាដើម ។ នៅពេលមានភ្លៀងធ្លាក់ចុះមក គឺដូចជា ការចម្រោះជាតិពុល គ្រប់បែបយ៉ាង ឱ្យហូរជ្រាបទៅបំពុលដី បំពុលទឹក និងបំពុលដល់ប្រភពទឹកនៅក្នុងស្រទាប់ដីខាងក្រោម ជាហេតុធ្វើឱ្យទឹកស្អាតក្លាយជាទឹកមិនស្អាត មានលោហៈធ្ងន់ និងជួនកាលមានបាក់តេរីកាចៗ នៅពេលនោះ បណ្តាលឱ្យលេចឡើងនូវជម្ងឺរាគត្បាតផ្សេងៗដោយសារតែការទទួលទានទឹកមិនស្អាត ។

ចំពោះសំរាម នៅក្នុងឃុំចុងដូងបច្ចុប្បន្ន ប្រជាពលរដ្ឋភាគច្រើន បានបោះចោលនៅក្បែរផ្ទះ ខ្លះចោលរាយប៉ាយនៅតាមផ្លូវ ខ្លះដុតចោល ដែលធ្វើឱ្យរងការបំពុលពីផ្សែងដុត និងបាត់បង់សោភ័ណភាពក្នុងភូមិ ឃុំ ។ ដើម្បីអាចគ្រប់គ្រងសំរាមបាន ឃុំត្រូវរកដី ដែលមានទីតាំងសមស្របនៅក្នុងឃុំ ដែលនៅដាច់ដោយឡែកឆ្ងាយពីភូមិធ្វើជាទីលានចាក់សំរាមមួយកន្លែង ឬ រកទីតាំងនៅខាងក្រៅឃុំចាក់សំរាមរួមជាមួយគ្នាឃុំផ្សេង តែក្នុងករណីក្នុងឃុំមិនមានទីលានចាក់សំរាមក៏គួររៀបចំឲ្យមានឡូត៍សម្រាប់ដុតសំរាមមួយផងដែរ ដើម្បីប្រមូលសំរាម ដែលមាននៅក្នុងឃុំទៅរក្សាទុកឱ្យបានម៉ត់ចត់ឬត្រូវប្រមូលសំរាមប្លាស្ទីកយកទៅកែច្នៃផលិតឡើងវិញចំណែកសំរាម

ចេញពីផ្ទះបាយ និងស្លឹកឈើផ្សេងៗក្រៅពីប្លាស្ទិកអាចកែច្នៃធ្វើជី ដូចជាជីកំប៉ុស្តជាដើម ដើម្បីប្រើប្រាស់នៅក្នុងការបង្កើនគុណភាពដីដាំដុះ។ ជារួមសំខាន់ជាងគេបំផុត គឺត្រូវលុបបំបាត់សំរាមប្លាស្ទិកឱ្យអស់ពីភូមិ ឃុំ។

ង.៥. ដីកប់ខ្មោច

ជាទូទៅពិធីបូជាសព មានពីប្រភេទ គឺពិធីដុតសព និងកប់សពរក្សាក្នុងដី ក្នុងពិធីទាំងពីរនេះ គឺពីធីកប់សពត្រូវការប្រើប្រាស់ដី ដែលធ្វើឱ្យមានការបាត់បង់ដី សម្រាប់ប្រើប្រាស់បម្រើឱ្យការអភិវឌ្ឍន៍នៅក្នុងសហគមន៍ ដែលមនុស្សរស់នៅ ។ នៅក្នុងឃុំចុងដូងបច្ចុប្បន្ន ក៏មានប្រើពិធីទាំងពីរនេះដែរ ចំណែកការប្រើប្រាស់ដីនៅក្នុងឃុំ ក៏មានតម្រូវការកាន់តែច្រើនឡើង ស្របទៅនឹងអត្រាមរណរបស់ប្រជាពលរដ្ឋទៅថ្ងៃអនាគត ដែលចាំបាច់អាជ្ញាធរដែនដីពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំចុងដូង ត្រូវខិតខំយកចិត្តទុកដាក់គិតគូរអំពីពិធីបូជាសពនេះ ដែលនឹងកើតឡើងជាបន្តបន្ទាប់ ដោយគួរខិតខំលប់បំបាត់ការបញ្ចុះសពដោយកប់ក្នុងដី ហើយជំនួសមកវិញ ដោយការរៀបចំឱ្យមានកន្លែងបូជាសពនៅតាមវត្តអារាម ឬកន្លែងណាផ្សេងដាច់ឆ្ងាយពីភូមិ ដែលជាជម្រើសល្អបំផុត ។

ង.៦. ស្រះ និងអណ្តូងទឹក

ទឹក គឺជាផ្នែកមួយនៃធាតុ ដ៏សំខាន់បំផុតសម្រាប់រាងកាយមនុស្សយើង ដែលជាពិសេសនោះ គឺសម្រាប់សុខភាពដើម្បីធានាបាននូវការរស់រានមានជីវិតរបស់មនុស្ស ។ ទឹកអាចនឹងមាននៅគ្រប់ទីកន្លែង ប៉ុន្តែមិនអាចយកមកសម្រាប់ការទទួលទានបានទាំងអស់នោះទេ គឺត្រូវការទឹកដែលស្អាត ។ នៅក្នុងឃុំចុងដូងបច្ចុប្បន្ន មានការប្រើប្រាស់ទឹកស្អាត សម្រាប់ទទួលទានតាមរយៈការប្រើទឹកស្រះ និងអណ្តូង ដូចដែលបានរៀបរាប់ក្នុងជំពូកទី១នៃរបាយការណ៍នេះ ប៉ុន្តែបានរកឃើញថា ចំនួនស្រះទឹក និងអណ្តូងទាំងអស់នេះ មិនមានបរិមាណគ្រប់គ្រាន់សម្រាប់បំពេញតម្រូវរបស់មនុស្ស និងសត្វចិញ្ចឹមគ្រប់គ្រាន់នារដូវប្រាំងបានឡើយ ។

ដូច្នេះដើម្បីឆ្លើយតបទៅនឹងការខ្វះខាតនាពេលបច្ចុប្បន្ន ក៏ដូចជាឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋនៅក្នុងរយៈពេល១៥ឆ្នាំខាងមុខបាន អាជ្ញាធរដែនដីពាក់ព័ន្ធទាំងអស់ ជាពិសេសក្រុមប្រឹក្សាឃុំចុងដូង ត្រូវយកចិត្តទុកដាក់លើកទឹកចិត្តឱ្យប្រជាពលរដ្ឋក្នុងឃុំត្រងទឹកភ្លៀងនៅរដូវវស្សារក្សាទុកក្នុងអាងស្តុកតាមផ្ទះរៀងៗខ្លួន សម្រាប់ទុកដោះស្រាយការប្រើប្រាស់នៅរដូវប្រាំងដែលខ្សត់ទឹក ហើយថែមពីលើនេះទៀត ក៏ត្រូវបំផុសឱ្យមានការរៀបចំជីកស្រះសហគមន៍ផងដែរ ព្រមទាំងជំរុញលើកទឹកចិត្តទៅដល់វិស័យឯកជនឱ្យផលិតទឹកស្អាត និងតបណ្តាញឱ្យដល់គ្រប់ខ្នងផ្ទះ ប្រជាពលរដ្ឋបានប្រើប្រាស់គ្រប់ក្រុមគ្រួសារដែលជាជម្រើសដ៏ល្អបំផុត ។

## ២.២. តំបន់រសើប

តំបន់រសើប គឺជាតំបន់ដែលទាមទារនូវការការពារបន្ថែម និងជាពិសេសដោយផ្អែកលើសារៈសំខាន់ ឬជីវចម្រុះនៃបរិស្ថាន បេតិកភ័ណ្ឌវប្បធម៌ តំលៃខាងផ្លូវចិត្តដែលមានលក្ខណៈដូចជា៖ តំបន់ព្រៃពណីសម្រាប់ជនជាតិដើមភាគតិច ឬក៏មូលហេតុសំខាន់ៗផ្សេងទៀត។ តំបន់បង្ហាញបញ្ហាចោទ ចាំបាច់ត្រូវតែកំណត់ ដើម្បីធានាថាឃុំសង្កាត់ត្រូវការដឹងឮនូវតម្រូវការ និងប្រធានបទពិសេសទាំងនេះ ។

នៅក្នុងឃុំចុងដូង តំបន់រសើបមាននៅលើដីស្រែ ចម្ការ របស់ប្រជាពលរដ្ឋ ដែលជាតំបន់សង្ស័យថា មានគ្រាប់មិនទាន់ផ្ទុះចំនួន ០២កន្លែង ដែលស្ថិតនៅភាគខាងកើតជាប់នឹងព្រំប្រទល់ឃុំបល្ល័ង្ក ព្រមទាំងមានតំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប (សត្វខ្សឹប) នៅភាគកណ្តាល ដីតំបន់៣ជុំវិញបឹងទន្លេសាបនៅភាគខាងលិចឃុំ តំបន់សហគមន៍នេសាទ នៅផ្នែកកណ្តាលនៃឃុំ ដីទួលបុរាណស្ថិតនៅវាយប៉ាយផ្នែកកណ្តាល និងខាងកើតឃុំខ្លះ ។ សម្រាប់តំបន់ដីសង្ស័យមានមីនដែលត្រូវទាមទារនូវកិច្ចការពារបន្ថែម និងជាពិសេសនោះ ដោយសារតំបន់នេះត្រូវការហាមឃាត់ប្រជាពលរដ្ឋចូលទៅតំបន់នោះ ដែលនាំឱ្យមានគ្រោះថ្នាក់ពីគ្រាប់មីនមិនទាន់ផ្ទុះ ចំណែកតំបន់ដីព្រៃ

សហគមន៍ ដែលត្រូវទាមទារនូវកិច្ចការពារបន្ថែម និងជាពិសេសនោះ ដោយសារតំបន់នេះត្រូវថែរក្សាទុកស្របតាមច្បាប់ស្តីពីជលផលជាតំបនសហគមន៍នេសាទ និងតំបន់ទេសភាពទំនាបខាងជើងទន្លេសាប ដែលត្រូវបានការពារដោយអនុក្រឹត្យ និងទួលបុរាណដែលត្រូវបានមន្ទីរវប្បធម៌ជាស្ថាប័នមួយទទួលបន្ទុកក្នុងការគ្រប់គ្រង ។

ផែនទី 10៖ ផែនទីតំបន់រសើប ឃុំចុងដូង




## ២.៣. ការប្រឈម

### ២.៣.១.ការប្រឈមដោយធម្មជាតិ

#### ក. កំណើនប្រជាជន

បច្ចុប្បន្ននៅក្នុងឃុំចុងដូង បានរកឃើញថា ប្រជាពលរដ្ឋបានកើនឡើងតាមធម្មជាតិជារៀងរាល់ឆ្នាំ ដែលគិតជាមធ្យមប្រមាណ ១,៦៩ % ហើយទៅថ្ងៃអនាគតត្រឹមឆ្នាំ ២០៣២ បញ្ហាកំណើនប្រជាជន ត្រូវបានគិតគូរដោះស្រាយដោយពុំមានបញ្ហាប្រឈមធ្ងន់ធ្ងរឡើយ តែបន្តពីនេះទៅមុខវែងឆ្ងាយនឹងអាចកើតមានបញ្ហាប្រឈមដែលត្រូវបន្តដោះស្រាយមួយចំនួនដូចខាងក្រោម៖

-មានការខ្វះខាតដីលំនៅឋាន ដែលនាំឱ្យមានការដោះស្រាយផលប៉ះពាល់ទៅដល់ដីស្រែ ។

-មានការខ្វះខាតដីស្រែ ដែលនាំឱ្យពិបាកក្នុងការដោះស្រាយ ដោយសារតែនៅក្នុងឃុំ ពុំមានដីសល់ទំនេរសម្រាប់បំពេញការខ្វះខាតនេះ ។

-មានការខ្វះខាតដល់ការផ្តល់សេវាអប់រំ ដែលត្រូវដោះស្រាយដូចជាការសាងសង់សាលារៀន គ្រូបង្រៀន និងសម្ភារៈសិក្សាបន្ថែម ។

-មានការខ្វះខាតសេវាសុខាភិបាល ដែលត្រូវដោះស្រាយដូចជា គ្រូពេទ្យ ឧបករណ៍ និងសម្ភារៈបរិក្ខាពេទ្យ និងថ្នាំដង្កូវបន្ថែម ។

-មានការខ្វះខាតទឹកស្អាត អគ្គិសនី ដែលត្រូវដោះស្រាយ សម្រាប់ការផ្គត់ផ្គង់បន្ថែម ។

### ខ. គ្រោះធម្មជាតិ ការរេចរឹលនៃធម្មជាតិ

បច្ចុប្បន្ននៅក្នុងឃុំចុងដូង គេបានកត់សម្គាល់ឃើញថា មានជួបប្រទះនូវគ្រោះធម្មជាតិ កើតឡើងស្ទើរតែរៀងរាល់ឆ្នាំ ដូចជាគ្រោះរាំងស្ងួត ទឹកជំនន់ ជាដើម ។ ទន្ទឹមនេះ ដីធ្លីដែលជាធនធានធម្មជាតិកម្រនៅក្នុងឃុំចុងដូង ក៏មានភាពរេចរឹលទៅៗផងដែរ ដូចជាធ្វើឱ្យដីស្រែរឹង និងខ្សោះជីជាតិ ដោយសារតែការប្រើប្រាស់ជីគីមី និងថ្នាំគីមីសម្លាប់សត្វល្អិតនៅលើដំណាំស្រូវ និងដំណាំដទៃទៀត មិនស្របតាមបទដ្ឋានបច្ចេកទេស ព្រមទាំងមានការថយចុះ និងបាត់បង់ធនធានជលផល ជាពិសេសនោះមច្ឆាជាតិ ដោយសារការនេសាទខុសច្បាប់ មានដូចជាការប្រើប្រាស់ឧបករណ៍ឆក់ នេសាទនៅរដូវបិទនេសាទជាដើម ។ ទៅថ្ងៃអនាគត ប្រជាពលរដ្ឋនៅក្នុងឃុំនៅតែបន្តជួបប្រទះនូវបញ្ហាប្រឈមទាំងអស់នេះជាដដែល បើសិនជាមិនមានយន្តការឬដំណោះស្រាយដើម្បីទប់ទល់ទៅនឹងគ្រោះរាំងស្ងួត ព្រមទាំងមិនមានការកែប្រែឥរិយាបថ នៅក្នុងការប្រើប្រាស់ដីធ្លីសម្រាប់កសិកម្មឱ្យបានសមស្របទេនោះ ។

## ២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍន៍ដែលពុំមាននិរន្តរភាព

ជាការពិតណាស់រាល់គម្រោងអភិវឌ្ឍនានា ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានធម្មជាតិ ជាពិសេសការប្រើប្រាស់ដីក្នុងទីតាំងភូមិសាស្ត្រណាមួយ តែងនាំមកការរីកចម្រើនជានិច្ច តែផ្ទុយទៅវិញ បើគម្រោងអភិវឌ្ឍន៍ទាំងនោះពុំទាន់បានគិតគូរគ្រប់ជ្រុងជ្រោយទៅដល់ទីតាំងភូមិសាស្ត្រនីមួយៗ និងសក្តានុពលនៃធនធាន ដែលមានវានឹងនាំមកនូវផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច សង្គម និងបរិស្ថាននាពេលអនាគត ដោយមិនអាចធានាចិរភាពនៃគម្រោងទាំងនោះ ទៅដល់កូនចៅជំនាន់ក្រោយនៅក្នុងតំបន់នោះបានឡើយ ដូចជាស្ថានភាពនៅក្នុងឃុំចុងដូង ដែលជាឃុំគោលដៅសិក្សារៀបចំផែនការប្រើប្រាស់ដី ដូចអ្វីដែលបានរៀបរាប់នៅក្នុងជំពូកទី១ នៃរបាយការណ៍នេះ បានឱ្យដឹងថា នៅក្នុងឃុំចុងដូង មានស្ថានភាពភូមិសាស្ត្រ ជាវាលទំនាបមានធនធានដីអំណោយផលដល់ដំណាំស្រូវ និងដំណាំចម្ការ ដែលជាសក្តានុពលដល់ការអភិវឌ្ឍដល់ឃុំនេះ ដោយមិនមានការអះអាងណាផ្សេងក្រៅពីនេះនៅឡើយ ។ ដូចនេះឃុំចុងដូង គួរជៀសវាងជាដាច់ខាតនៅគម្រោងអភិវឌ្ឍទាំងឡាយណា ដែលនាំឱ្យមានផលប៉ះពាល់ដល់ការបាត់បង់ដីស្រែចម្ការ ដែលខ្លួនមាន ធ្វើឱ្យឃុំមានការថយចុះឱកាសអភិវឌ្ឍ ដូចជាគម្រោងចាក់លុបដីស្រែ ដីចម្ការបង្កកទុកលក់ ឬពុះដីឡូតិ៍លក់ ដើម្បីគេងផលចំណេញពីឈ្មួញ និងគម្រោងជីកយកអាចម៍ដីយកលក់ជាដើម ។ លើកលែងតែគម្រោងណាពាក់ព័ន្ធ ដែលធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធកសិកម្ម ដូចជាកសិដ្ឋានផលិតពូជស្រូវ ពូជដំណាំ ស្រែគម្រូផលិតជីធម្មជាតិ ទុកដាក់គ្រឿងយន្តកសិកម្ម ទន្ទឹមនិងនេះក៏នៅមានគម្រោងអភិវឌ្ឍប៉ះពាល់ដល់ការរស់នៅ និងបរិស្ថាន ដែលគួរចៀសវាងផងដែរ ដូចជាគម្រោងបង្កើតសិប្បកម្ម ឧស្សាហកម្ម ដែលធ្វើឱ្យមានការបង្ហូរទឹកស្អុយកខ្វក់ជាដើម។ល។ ទន្ទឹមនឹងការប្រឈមដោយការអភិវឌ្ឍខាងលើ ដែលត្រូវចៀសវាង ក៏នៅមានការប្រឈមទៅនិងអំពើអនាធិបតេយ្យ ដែលកើតឡើង ពីការដោះស្រាយការខ្វះខាតរបស់ប្រជាពលរដ្ឋនៅក្នុងឃុំផងដែរ ដូចជាការសាងសង់ផ្ទះស្នាក់នៅលើដីនៅតាមមាត់ប្រឡាយ តាមចិញ្ចើមផ្លូវសាធារណៈ ការទន្ទ្រានដីព្រៃ ធ្វើស្រែបំពានទៅលើប្រឡាយ និងបឹងជាដើម ។

## ២.៤. ឱកាស

### ២.៤.១.ដោយអំណោយផលពីធម្មជាតិ

នៅលើលោកយើងនេះ ធម្មជាតិ គឺពិតជាបានផ្ដល់នូវធនធានដ៏មានសារសំខាន់ សម្រាប់ធ្វើអ្វីៗគ្រប់យ៉ាង ដែលមនុស្សចង់ធ្វើ ដូចជាមនុស្សបានប្រើប្រាស់ធនធានដី និងទឹកសម្រាប់ការដាំដុះ ឈើធ្វើឧសដុត សម្រាប់ផ្ដល់កម្ដៅ ឬសាងសង់ទីជម្រក ខ្យល់អាកាស ត្បូងថ្ម ប្រេង ឧស្ម័នធម្មជាតិ និងរ៉ែជាវត្ថុធាតុដើមជាច្រើនទៀត ដូចជាដែកទង់ដែងជាដើម សម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ផ្សេងៗ។ ចំណែកនៅក្នុងឃុំចុងដូង យើងផ្ដោតសំខាន់លើធនធានដី ដែលមានសក្ដានុពលលើសលប់ទៅលើការអភិវឌ្ឍន៍ឃុំ ដូចបានរកឃើញ និងរៀបរាប់នៅក្នុងជំពូកទី១ នៃរបាយការណ៍នេះ។ នៅក្នុងឃុំចុងដូងមានស្ថានភាពអំណោយផលពីធម្មជាតិដូចខាងក្រោម៖

- ស្ថានភាពដី ជាវាលទំនាប ដែលអំណោយផលដល់ការដាំដុះដំណាំស្រូវ ព្រមទាំងទំនាបទាបនិងទំនាបខ្ពស់ អំណោយផលដល់ការដាំដំណាំចម្ការជាពិសេសដំណាំឧស្សាហកម្ម។
- នៅជិតប្រភព បឹង អូរ អាចមានលទ្ធភាពនាំទឹកមកស្រោចស្រពដំណាំស្រូវ និងដំណាំចម្ការ នៅពេលជួបប្រទះគ្រោះរាំងស្ងួត និងមានលទ្ធភាពនាំទឹកមកស្រោចស្រពបង្កើនរដូវធ្វើស្រែបានច្រើនដង។
- នៅរដូវវស្សាមានភ្លៀងធ្លាក់ច្រើនអាចស្រោចស្រពដំណាំស្រូវ និងដំណាំចម្ការបាន។
- អាកាសធាតុ ក្ដៅ ហើយសើម អំណោយផលដល់ការលូតលាស់របស់រុក្ខជាតិ និងដំណាំគ្រប់ប្រភេទ។

### ២.៤.២.ដោយបច្ចេកវិទ្យាថ្មីៗ

ជីវិតរស់នៅ ដែលយើងកំពុងទទួលបានភាពប្រសើរឡើងនាពេលបច្ចុប្បន្ននេះ គឺដោយសារតែមានការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា ។ បច្ចេកវិទ្យាថ្មីៗ ធ្វើឱ្យមានការផ្លាស់ប្តូរកាន់តែប្រសើរឡើង សម្រាប់ជីវិតរស់នៅរបស់ពលរដ្ឋ ដែលធ្វើឱ្យអ្វីៗនៅក្នុងពេលបច្ចុប្បន្នកាន់តែប្រសើរឡើង និងងាយស្រួលជាងមុន ។ បច្ចេកវិទ្យាថ្មីអាចកាត់បន្ថយបាននូវពេលវេលា គុណភាព និងការចំណាយទៅលើកម្លាំងពលកម្មក្នុងផលិតកម្មនានា ។

បច្ចុប្បន្ន ស្ថានភាពនៅក្នុងឃុំចុងដូង គឺមានសក្ដានុពលខ្លាំងដោយពឹងផ្អែកទៅលើផលិតកម្មដំណាំស្រូវ និងដំណាំចម្ការឧស្សាហកម្ម ហើយនាពេលអនាគត ក៏នៅតែពឹងផ្អែកលើផលិតកម្មដំណាំទាំងនេះដដែលដែរនោះ ប្រជាពលរដ្ឋនឹងចាំបាច់ត្រូវការបច្ចេកវិទ្យាទំនើបទាន់សម័យ សម្រាប់វិស័យកសិកម្មដំណាំស្រូវ និងចម្ការ ដើម្បីជួយជំរុញឱ្យមានការកើនឡើងទិន្នផលខ្ពស់ ដើម្បីអាចដោះស្រាយបាននូវសន្តិសុខស្បៀង និងមានប្រាក់ចំណូលកាន់តែខ្ពស់ ដែលនាំឱ្យជីវភាពរស់របស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ក្នុងពេលដែលមានកំណើនប្រជាពលរដ្ឋកាន់តែខ្ពស់នាពេលខាងមុខ ។ តាមរយៈបច្ចេកវិទ្យាថ្មីៗ នឹងនាំឱ្យប្រជាពលរដ្ឋ មានឱកាសអាចប្រើប្រាស់គ្រឿងយន្តកសិកម្មទំនើបទាន់សម័យ សម្រាប់ការផលិតដំណាំស្រូវ ដែលរួមមានដូចជា៖ ម៉ាស៊ីនភ្ជួររាស់ដី ម៉ាស៊ីនពង្រាបដីស្រែដោយប្រើប្រព័ន្ធឡាស៊ែរ ម៉ាស៊ីនដកស្ទូង ជ្រូនបាញ់ថ្នាំសម្លាប់សត្វល្អិត និងដាក់ជី ម៉ាស៊ីនច្រូតកាត់ និងបោកបែន ព្រមទាំងគ្រឿងយន្តដឹកជញ្ជូនជាដើម។ល។

### ២.៤.៣.ដោយគម្រោងវិនិយោគ

សម្រាប់នាពេលអនាគត ឃុំចុងដូង ដែលមានសក្ដានុពលខ្ពស់ទៅលើដំណាំស្រូវនោះ នឹងនាំឱ្យមានការផ្ដួចផ្ដើមបង្កើតគម្រោងវិនិយោគនានា ដែលភាគច្រើនផ្ដោតទៅលើដំណាំស្រូវ និងដំណាំចម្ការ ដូចជាគម្រោងបង្កើតកសិដ្ឋានកសិកម្ម ដើម្បីជំរុញផលិតកម្មដំណាំស្រូវ និងដំណាំចម្ការ ព្រមទាំងគម្រោងវិនិយោគទៅលើការកែច្នៃផលិតផលកសិកម្ម ដើម្បីនាំចេញ ដែលនឹងផ្ដល់ការងារបន្ថែមទៀតទៅដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនប្រាក់

ចំណូលឲ្យបានកាន់តែខ្ពស់ ដែលអាចធ្វើឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើង ព្រមទាំងកាត់បន្ថយបាននូវភាពក្រីក្រ ស្របទៅតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។

## ២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ

ផ្អែកទៅតាមការរកឃើញ នៅក្នុងជំពូកទី១នៃរបាយការណ៍នេះ អាចឱ្យយើងធ្វើការវិភាគ និងចងក្រងបាននូវបញ្ហា ដែលកើតមាននៅក្នុងឃុំចុងដូង ។ មូលហេតុដែលនាំឱ្យកើតមានបញ្ហា និងដំណោះស្រាយលើបញ្ហាទាំងអស់នេះ គឺត្រូវបានបង្ហាញនៅក្នុងតារាង និងនៅក្នុងផែនទី ដូចមាននៅខាងក្រោមនេះ៖

តារាង 36៖ បញ្ហាប្រឈម (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហា | ទីតាំងបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១.ទីតាំងលំនៅឋាន នៅលើដីសាធារណៈរបស់រដ្ឋ (លើស្ទឹង ប្រឡាយ...) (១៤គ្រួសារ) | គ្រប់ភូមិ | ក-រស់នៅតាំងពីដូនតាមក | ក-១-ស្រង់ស្ថិតិប្រជាជននៅលើដីសាធារណៈរបស់រដ្ឋ<br>ក-២-ផ្សព្វផ្សាយច្បាប់ភូមិបាល |
| | | ខ-ខ្វះខាតដីលំនៅឋាន | ខ-១- ដោះស្រាយដីតាមរយៈដីសម្បទានសង្គមកិច្ច<br>ខ-២-បញ្ឈប់ការសាងសង់លំនៅឋានថ្មី |
| ២.ខ្វះដីកសិកម្ម (២៥០គ្រួសារ) | គ្រប់ភូមិ | ក-លក់សងបំណុល | ក-ខ-គ-១-ស្នើសុំសម្បទានសង្គមកិច្ច<br>ក-ខ-គ-២-ផ្តល់បច្ចេកទេសកសិកម្មទំនើបៗ |
| | | ខ-កំណើនគ្រួសារក្នុងភូមិ | |
| | | គ-ដីកសិកម្មតិច | |
| ៣.កង្វះខាតទីលានទុកដាក់សំរាម ក្នុងឃុំ | ក្នុងឃុំ | ក-ទុកដាក់សំរាមគ្មានសណ្តាប់ធ្នាប់ មិនមានទីតាំងសមរម្យ | ក-ខ-១-យល់ដឹងពីការបែងចែកសំរាម (ប្រភេទសំរាមនីមួយ)<br>ក-ខ-២-ជំរុញឱ្យក្រុមហ៊ុនវិនិយោគ ក្នុងការប្រមូលសំរាមកែច្នៃ<br>ក-ខ-៣-មន្ទីរ ឬក្រសួង ពាក់ព័ន្ធ និងក្រុមប្រឹក្សាឃុំគួរបង្កើតឱ្យមានទីលានទុកដាក់សំរាមក្នុងឃុំ |
| | | ខ-ចោលសំរាមលើដីសារធារណៈរបស់រដ្ឋ | |
| ៤.គ្រាប់មីននៅសេសសល់  | ភូមិពពេជ ភូមិកំប៉ើយ | ក-ជាកន្លែងសមភូមិប្រយុទ្ធ | ក-១-ដាក់សញ្ញាសម្គាល់ដីដែលមានមីន និងគ្រាប់មិន ទាន់ផ្ទុះ<br>ក-២-ដាក់សំណើទៅអង្គភាពកំចាត់មីនា ឬអង្គការដើម្បី ជួយអន្តរាគមន៍ |
| ៥.បាត់បង់ព្រៃលិចទឹក  | ស្ទឹងជីនិត | ក-កាប់រានយកដីធ្វើស្រែប្រាំង | ក-ខ-១-ដាំដើមឈើឡើងវិញ<br>ក-ខ-២-ផ្សព្វផ្សាយច្បាប់ព្រៃលិចទឹក |
| | | ខ-កាប់ឧសដុត | |
| ៦-ទិន្នផលស្រូវទាប | ដីស្រែ | ក-ដីខ្វះជីជាតិ | ក-១-បណ្តុះបណ្តាលផលិតជីកំប៉ុស្ត<br>ក-២-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី<br>ក-៣-ជំរុញការចិញ្ចឹមសត្វដើម្បីបានលាមក |

| | | | |
|---|---|---|---|
|  | | ខ-ខ្វះបច្ចេកទេសកសិកម្ម | ខ-១-បណ្តុះបណ្តាលពីបច្ចេកទេសផលិតពូជស្រូវ<br>ខ-២-បណ្តុះបណ្តាលពីការដាំដំណាំស្រូវ<br>ខ-៣-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី<br>ខ-៤-បណ្តុះបណ្តាលបច្ចេកទេសផលិតជីកំប៉ុស្ត<br>ខ-៥-ប្រើប្រាស់ពូជស្រូវសុទ្ធល្អតាមស្តង់ដា |
| ៧-ខ្វះទឹកស្រោចស្រព | ក្នុងឃុំ | ក-ប្រព័ន្ធធារាសាស្ត្ររងការខូចខាត | ក-១-ស្តារប្រឡាយឡើងវិញ<br>ក-២-ជួសជុល និងរៀបចំទ្វារទឹក |
| | | ខ-ធ្វើស្រែក្នុងប្រឡាយ | ខ-១-ស្រង់ស្ថិតិអ្នកធ្វើស្រែក្នុងប្រឡាយ<br>ខ-២-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ពាក់ព័ន្ធនានា។<br>ខ-៣-រកវិធីដោះស្រាយនិងធ្វើកិច្ចសន្យាបញ្ឈប់ |
| | | គ-ប្រើប្រាស់ប្រឡាយនៅជាប់ដីរបស់ខ្លួនផ្តាច់មុខ | គ- ១- ស្រង់ស្ថិតិប្រជាជនដែលប្រើប្រាស់ប្រឡាយផ្តាច់មុខ<br>គ-២-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ពាក់ព័ន្ធ<br>គ-៣-រកវិធីដោះស្រាយនិងធ្វើកិច្ចសន្យាបញ្ឈប់<br>គ-៤-បង្កើតសហគមន៍ប្រើប្រាស់ទឹកដើម្បីបានទឹកក្នុងការស្រោចស្រពស្មើភាព |
| ៨-ផ្លូវរងការខូចខាតពិបាកធ្វើដំណើរ<br><br> | ក្នុងឃុំ | ក-ឡានធុនធ្ងន់ដឹកលើសទម្ងន់ឆ្លងកាត់ | ក-១-ពង្រឹងការអនុវត្តន៍ច្បាប់ចរាចរណ៍ទប់ស្កាត់ឡានដឹកលើសទម្ងន់តាមរយៈដាក់សញ្ញាកំណត់ទំងន់ដឹកជញ្ជូនរបស់រថយន្ត<br>ក-២-ដាក់បារាស់កាត់ផ្លូវដែលមានរថយន្តធំឆ្លងកាត់<br>ក-៣-ជួសជុលផ្លូវដែលរងការខូចខាត |
| | | ខ-ផ្លូវរងការហូរជាច់ | ខ-១-ដាក់លូបង្ហូរទឹកតាមមុខផ្ទះនៅជាប់ផ្លូវ |
| | | គ-ខ្វះការថែទាំផ្លូវ | គ-១- ថែទាំផ្លូវ ខួប ជាប្រចាំ<br>គ-២-បង្កើតគណៈកម្មការថែទាំផ្លូវ |
| ៩-<br> | ស្ទឹង<br>បឹង | ក-នេសាទខុសច្បាប់ | ក-១-ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា |

| | | | |
|---|---|---|---|
| ធនធានមច្ឆាថយចុះ និងបាត់បង់ | | | ក-២-ហាមឃាត់ការប្រើប្រាស់ឧបករណ៍ឆក់ខុសច្បាប់<br>ក-៣-ធ្វើវារីវប្បកម្ម |
| ១០-ខ្វះទឹកស្អាតប្រើប្រាស់ | ក្នុងឃុំ | ក-គ្មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត | ក-១-គាំទ្រសេវាកម្មផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាត |
| | | ក-គ្មានស្រះទឹកគ្រប់គ្រាន់ | ក-១-ជីកស្រះទឹកបន្ថែម |
| | | ខ-គ្មានអណ្តូងស្នប់គ្រប់គ្រាន់ | ខ-១-ជីកអណ្តូងស្នប់បន្ថែម |
| | | គ-ប្រជាពលរដ្ឋមួយចំនួនខ្វះការសម្ភារៈបរិក្ខារទឹកស្អាត | គ-១-ផ្តល់ធុងចំរោះទឹកស្អាត<br>គ-២-ដាំទឹកឆ្អិនមុននឹងបរិភោគ |

ប្រភព៖ *សៀវភៅផែនអភិវឌ្ឍន៍០៥ឆ្នាំ និងក្រុមប្រឹក្សាឃុំចុងដូង ឆ្នាំ២០១៨*

ផែនទី 11៖ ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ



# ជំពូក ៣៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគតឆ្នាំ២០១៧-២០៣២

## ៣.១. តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង

### ៣.១.១.តម្រូវការដីទៅតាមប្រភេទ

នៅពេលអនាគតរហូតទៅដល់ឆ្នាំ ២០៣២ នៅក្នុងឃុំចុងដូង នឹងមានការកើនឡើងចំនួនប្រជាពលរដ្ឋ ៣ ៤៨០នាក់ ដែលត្រូវនឹងចំនួន ៧៨២គ្រួសារ ។ ដោយសារសន្ទុះនៃកំណើនប្រជាពលរដ្ឋនេះហើយ ដែលតម្រូវឱ្យមានការគិតគូរយកចិត្តទុកដាក់ដល់ការរកដីបន្ថែម សម្រាប់លំនៅឋាន និងដីស្រែជូនដល់ប្រជាពលរដ្ឋ ដែលមានចំនួនកើនឡើង ដើម្បីធានាឱ្យមាននិរន្តរភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំចុងដូង ទៅថ្ងៃអនាគតបន្តពីពេលបច្ចុប្បន្ន ដូចបានរកឃើញនៅក្នុងជំពូក២ខាងលើ នៃរបាយការណ៍នេះ ។ តែដោយសារទំហំផ្ទៃដី ដែលត្រូវបានប្រើប្រាស់បច្ចុប្បន្ននៅក្នុងឃុំ ពុំមានប្រែប្រួលកើនឡើង ស្របគ្នាទៅនឹងកំណើនប្រជាពលរដ្ឋនាពេលអនាគតនោះ ជាដំណោះស្រាយ គឺសម្រាប់លំនៅឋាន ត្រូវប្រើប្រាស់ដីលំនៅឋានភូមិដែលមានស្រាប់ ពីព្រោះថាស្ថានភាពការតាំងលំនៅឋាន ក្នុងបច្ចុប្បន្ន មិនទាន់មានភាពចង្អៀតនោះទេ ដែលអាចមានលទ្ធភាពទ្រទ្រង់ដល់ការសាងសង់លំនៅឋានបន្ថែមទៀតបានសម្រាប់រយៈពេល ១៥ឆ្នាំទៅមុខ ហើយម្យ៉ាងទៀតការតាំងលំនៅឋាន មានលក្ខណៈប្រមូលផ្តុំវានឹងផ្តល់ភាពងាយស្រួលដល់ការផ្គត់ផ្គង់ទឹកស្អាត ភ្លើង និងសេវាសង្គមផ្សេងៗទៀតដូចជាសេវាអប់រំ សេវាសុខភាពជាដើម។ល។

ដោយឡែកចំពោះដីស្រែវិញ ក៏មិនមានលទ្ធភាពពង្រីកបន្ថែមបានទៀតដែរ ជាដំណោះស្រាយ គឺត្រូវតែគិតគូរពិចារណាដោយយកចិត្តទុកដាក់លើការបង្កើនផលិតភាព គុណភាព និងពិពិធកម្មកសិកម្មដំណាំស្រូវ ដោយត្រូវធ្វើស្រែប្រាំងបង្កើនរដូវឱ្យបាន៣ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃរាជរដ្ឋាភិបាលកម្ពុជា ។

### ៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល

នៅពេលអនាគត ធនធានដីក្នុងឃុំចុងដូង នៅតែរក្សាទំហំក្រឡាផ្ទៃសរុបចំនួន ១២ ៧១២,៣២ហិកតាដដែល ដោយពុំមានការប្រែប្រួលឡើយ ដោយដីធ្លីទាំងនេះ នឹងត្រូវប្រើប្រាស់សម្រាប់ការសាងសង់លំនៅឋាន (រួមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន និងដំណាំជុំវិញលំនៅឋាន) ដីស្រែ (រួមទាំងប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន) ដីចម្ការដំណាំ ដីព្រៃឈើ ដីស្មឹង បឹង អាងស្តុកទឹក និងស្រះ ដូចទៅនឹងការប្រើប្រាស់ដីធ្លីបច្ចុប្បន្នដដែល ដោយពុំមានការប្រែប្រួលឡើយ ពីព្រោះដីធ្លី ដែលបានប្រើប្រាស់ក្នុងពេលបច្ចុប្បន្ននេះ បានសមស្របនិងចំសក្តានុពលនៃដីរួចហើយ ។ ចំណែកទំហំផ្ទៃដីតំបន់ប្រើប្រាស់នីមួយៗ ដូចមានរៀបរាប់ក្នុងសេចក្តីអត្ថាធិប្បាយអំពីការបែងចែកដីតាមតម្រូវការប្រើប្រាស់ខាងក្រោមនេះ។ ជាទូទៅធនធានដីនៅក្នុងឃុំចុងដូង មានសក្តានុពលខ្ពស់សមស្របទៅលើកសិកម្មដំណាំស្រូវ និងចម្ការដំណាំ ដោយសារតែដីក្នុងឃុំមានទីតាំងភូមិសាស្ត្រ អំណោយផលពីធម្មជាតិ ដូចដែលបានរៀបរាប់ក្នុងជំពូកទី២ខាងលើ ។ ដូច្នេះការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន និងការសម្រេចចិត្តប្រើប្រាស់ដីទៅថ្ងៃអនាគត នៅក្នុងឃុំ ដែលបានផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវ និងចម្ការជាចំបង គឺជាការប្រើប្រាស់បានត្រឹមត្រូវចំសក្តានុពល ហើយក៏ជាការគាប់ជួន ដែលភាពអំណោយផលពីធនធានដី នៅក្នុងឃុំសមស្របទៅលើវិស័យកសិកម្មដំណាំស្រូវ និងចម្ការនេះ ហើយក៏ស្របទៅនឹងគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងតួនាទីវិស័យកសិកម្ម ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ ដែលមានចែងក្នុងមុំទី១ ចតុកោណទី៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាល

ទី៤របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ដែលជាការផ្តល់ឱកាសដ៏ល្អដល់អាចអភិវឌ្ឍ នៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យឃុំមានការរីកចម្រើនបាន តាមរយៈការជំរុញធ្វើពិពិធកម្មកសិកម្មដំណាំស្រូវ នៅលើផ្ទៃដីកសិកម្មដ៏ធំល្វឹងល្វើយស្ទើរតែពេញដែនដីឃុំទាំងមូល ។ ដើម្បីបង្កើនទិន្នផលស្រូវ និងដំណាំចម្ការ ដែលជាដំណាំ ដ៏មានសារៈសំខាន់សម្រាប់ជាស្បៀងផ្គត់ផ្គង់ការហូបចុកមិនអាចខ្វះបាន និងការនាំចេញទៅលក់នៅទីផ្សារ ដើម្បីបានចំណូលផ្គត់ផ្គង់តម្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង រួមទាំងចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈសកម្មភាពធ្វើពាណិជ្ជកម្មនាំអង្ករចេញ របស់រាជរដ្ឋាភិបាលកម្ពុជា ។

ចំណែកដី ដែលមានទំហំតិចតួច ដែលបានកំណត់ ជាដីសម្រាប់ការសាងសង់លំនៅឋាន នៅលើដីខ្ពស់ជាប់តាមដងផ្លូវសំខាន់ៗ ដែលមិនលិចទឹកនៅរដូវវស្សា បានផ្តល់ភាពងាយស្រួលនៅក្នុងការធ្វើដំណើរចេញចូល និងងាយស្រួលក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្រាប់បម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋ នៅក្នុងឃុំបានប្រកបដោយផាសុកភាព ព្រមទាំងដី ដែលប្រើប្រាស់សម្រាប់ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គឺជាការប្រើប្រាស់បានត្រឹមត្រូវផងដែរ ។

ស្ថានភាពដី ដែលត្រូវប្រើប្រាស់ទាំងនោះមានដីលំនៅឋាន និងដីកសិកម្មដំណាំស្រូវនិងចម្ការ ជាកម្មសិទ្ធិរបស់ឯកជន ចំណែកដីព្រៃគុម្ពោត និងព្រៃដុះរាយប៉ាយ ជាព្រៃដុះតាមដីស្រែរបស់ប្រជាពលរដ្ឋ ដែលជាកម្មសិទ្ធិឯកជនត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ និងព្រៃលិចទឹក ជាដីសាធារណៈរបស់រដ្ឋ ចំណែកដីបឹង អូរ ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធ គឺជាដីកម្មសិទ្ធិរបស់រដ្ឋ ដែលយើងទាំងអស់គ្នា ត្រូវធ្វើការពារថែទាំឱ្យបានគង់វង្ស សម្រាប់បម្រើឱ្យជាផលប្រយោជន៍សាធារណៈដោយមិនត្រូវឱ្យមានការរំលោភកាន់កាប់ប្រើប្រាស់បម្រើផលប្រយោជន៍បុគ្គលផ្ទាល់ខ្លួនបានឡើយ ។

## ៣.២. ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់

### ៣.២.១. ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ

ជាទូទៅរាល់ការកំណត់តំបន់ប្រើប្រាស់ដី ត្រូវបានផ្តោតសំខាន់លើមុខងារនៃការប្រើប្រាស់ដី សម្រាប់គោលបំណងផ្សេងៗដូចជា ផ្លូវ កសិកម្ម លំនៅឋាន ពាណិជ្ជកម្ម សួនកំសាន្ត ព្រៃឈើ ។ល។ ទន្ទឹមនឹងនោះការប្រើប្រាស់ដីតែងតែមានការផ្លាស់ប្តូរមុខងាររបស់វា តែការផ្លាស់ប្តូរមុខងារប្រើប្រាស់ដីទាំងនេះត្រូវតែគិតគូរពិចារណាឱ្យបានហ្មត់ចត់ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវទៅតាមស្ថានភាពច្បាប់ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ហើយត្រូវតែប្រាកដថា ដីដែលក្រោយពីបានប្តូរមុខងារប្រើប្រាស់ហើយនោះ ត្រូវតែមានតម្លៃសេដ្ឋកិច្ច ឬ ផលប្រយោជន៍ខ្ពស់ជាងមុខងារប្រើប្រាស់ពីមុន តាមរយៈការរក្សាជំហរច្បាស់លាស់ ក្នុងការបង្កើនធនធានប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពជាមួយនឹងផលប៉ះពាល់ដ៏តិចតួចបំផុតចំពោះមនុស្សជំនាន់ក្រោយ ។ ឧទាហរណ៍៖ ដូចជាការផ្លាស់ប្តូរពីដីព្រៃឈើរេចរិលទៅជាដីសម្រាប់កសិកម្ម ដែលវានឹងនាំឱ្យមានការបាត់បង់បរិមាណដីព្រៃឈើ ដែលផ្តល់ប្រយោជន៍ច្រើនយ៉ាងដល់សហគមន៍មូលដ្ឋាន តែជំនួសមកវិញដោយវាលស្រែសម្រាប់ផលិតកម្មស្រូវ ដែលជាចំណីអាហារដ៏សំខាន់ សម្រាប់ជីវិតរស់នៅមិនអាចខ្វះបាន ទាំងនេះជាការបង្ហាញឱ្យឃើញអំពីអន្តរអំពើរវាងមុខងារប្រើប្រាស់ដីមួយ ជាមួយមុខងារប្រើប្រាស់ដីមួយផ្សេងទៀត នៅលើទីតាំងដីដដែល។

យ៉ាងណាមិញ នៅក្នុងរយៈពេល ១៥ឆ្នាំខាងមុខ រហូតទៅដល់ឆ្នាំ ២០៣២ សម្រាប់ការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង គឺត្រូវបានធ្វើការគិតគូរយ៉ាងយកចិត្តទុកដាក់ ដើម្បីដោះស្រាយ និងឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋ ដូចដែលបានរៀបរាប់ខាងលើ ជាពិសេសនោះ គឺការដោះស្រាយការបែងចែកការប្រើប្រាស់ដីធ្លី

ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ តាមគោលការណ៍របស់រាជរដ្ឋាភិបាល និងដោយឈរលើស្មារតីនៅក្នុងការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន សម្រាប់ការប្រើប្រាស់ដីធ្លីនៅក្នុងរដ្ឋបាលឃុំ ។ បញ្ហាដែលត្រូវដោះស្រាយខាងលើនេះ យើងសង្កេតឃើញថា មានការដោះស្រាយដី សម្រាប់តែការពង្រីកប្រព័ន្ធស្រោចស្រពប៉ុណ្ណោះ ហើយការដោះស្រាយនេះត្រូវបានសម្រេចចិត្តកំណត់យកទៅលើដីស្រែ ទៅតាមទីតាំងដែលសមស្របអាចមានលទ្ធភាពនាំទឹកទៅស្រោចស្រព លើផ្ទៃដីស្រែបានគ្រប់គ្រាន់ ដែលនឹងនាំឱ្យមានការប្រែប្រួលពីបរិមាណផ្ទៃដីស្រែមួយភាគតូច ទៅជាដីសម្រាប់ការរៀបចំធ្វើប្រព័ន្ធប្រឡាយស្រោចស្រព គឺមានន័យថា៖ មានការថយចុះផ្ទៃដីស្រែ ដែលជាមូលដ្ឋានដ៏រឹងមាំនៃការអភិវឌ្ឍឃុំចុងដូង ធ្វើឱ្យមានការថយចុះផលិតផលស្រូវ ដែលនឹងនាំឱ្យមានការបាត់បង់ប្រាក់ចំណូល ប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តែបរិមាណផ្ទៃដីសម្រាប់ប្រព័ន្ធស្រោចស្រពមានការកើនឡើង ដែលជាតម្រូវការចាំបាច់ សម្រាប់ការដោះស្រាយនៅក្នុងការស្រោចស្រពដំណាំកសិកម្មមិនអាចខ្វះបាន ដើម្បីធានាចីរភាពនៃផលិតកម្មកសិកម្មសម្រាប់ការអភិវឌ្ឍន៍ឃុំ ។

តារាង 37៖ ការប្រើប្រាស់ដីនាពេលអនាគត ឃុំចុងដូង

| ប្រភេទដីប្រើប្រាស់ដី | ផ្ទៃដីបច្ចុប្បន្ន (ហិកតា) | ផ្ទៃដី១៥ឆ្នាំក្រោយ (ហិកតា) | បម្រែបម្រួល (ហិកតា) |
|---|---|---|---|
| **ក.ដីលំនៅឋាន ភូមិ** | **៤១៨,៦៦** | **៤១៨,៦៦** | **០០** |
| -ដីលំនៅឋាន ភូមិ | ១៥៧,៣២ | ១៥៧,៣២ | ០០ |
| -ដីលំនៅឋាន ភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ២២២,៣០ | ២២២,៣០ | ០០ |
| -ដីលំនៅឋាន ភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៣៩,០៥ | ៣៩,០៥ | ០០ |
| **ខ.ដីស្រែវស្សា** | **៤ ៥៦០,៦៤** | **៤ ៥៦០,៦៤** | **០០** |
| -ដីស្រែវស្សា | ៨៩៤,៥០ | ៨៩៤,៥០ | ០០ |
| -ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ២២៦១,៩៨ | ២២៦១,៩៨ | ០០ |
| -ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ១ ៤០៤,២០ | ១ ៤០៤,២០ | ០០ |
| **គ.ដីស្រែប្រាំង** | **៣១៣.២០** | **៣១៣.២០** | **០០** |
| -ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ២១៨,៨៥ | ២១៨,៨៥ | ០០ |
| -ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ៩៤,២១ | ៩៤,២១ | ០០ |
| **ឃ.ដីស្រែប្រាំងនិងស្រែវស្សា** | **៣ ៩៨១,៥០** | **៣ ៩៨១,៥០** | ០០ |
| -ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៣ ៩៧៩,៥០ | ៣ ៩៧៩,៥០ | ០០ |
| -ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ២,០១ | ២,០១ | ០០ |
| **ង.ដីចម្ការ** | **៤១,៥៦** | **៤១,៥៦** | ០០ |
| -ចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ២២,៤៣ | ២២,៤៣ | ០០ |
| -ចម្ការក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ១៩,១៣ | ១៩,១៣ | ០០ |

| | | | |
|---|---|---|---|
| **ច.ព្រៃគុម្ពោត** | **១២៧,៧១** | **១២៧,៧១** | ០០ |
| -ព្រៃគុម្ពោត ក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៨៨,៨៤ | ៨៨,៨៤ | ០០ |
| -ព្រៃគុម្ពោតក្នុងគម្របព្រៃឈើឆ្នាំ២០០២ ត្រួតតំបន់២ជុំវិញបឹងទន្លេសាប | ៣៨,៨៧ | ៣៨,៨៧ | ០០ |
| **ឆ.ព្រៃជាមួយចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប** | **២៨,៥៦** | **២៨,៥៦** | **០០** |
| **ជ.ព្រៃលិចទឹក** | **២ ៦៨៨,១៦** | **២ ៦៨៨,១៦** | **០០** |
| **ឈ.បឹង** | **៤២៩,៨៧** | **៤២៩,៨៧** | **០០** |
| **ញ.ស្ទឹង** | **១៤៧,៧០** | **១៤៧,៧០** | **០០** |
| **ដ.ស្រះ** | **១២,៦១** | **១២,៦១** | **០០** |
| -ស្រះ | ១,៦៥ | ១,៦៥ | ០០ |
| -ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ២,៣០ | ២,៣០ | ០០ |
| -ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៨,៦៦ | ៨,៦៦ | ០០ |
| **ផ្ទៃដីឃុំសរុប** | **១២ ៧៩១,៧៤** | **១២ ៧៩១,៧៤** | **០០** |

តារាង 38៖ តារាងផែនការផ្នែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំ២០១៧ (ម៉ែត្រ) | ប្រវែងផ្លូវឆ្នាំ២០៣២ (ម៉ែត្រ) | បម្រែបម្រួល (ម៉ែត្រ) |
|---|---|---|---|
| ផ្លូវជាតិលេខ៦ | ៤ ៦៧៧,២៩ | ៤ ៦៧៧,២៩ | ០០ |
| ផ្លូវក្រាលគ្រួសក្រហម | ៤២ ៦០៣,៤៨ | ៤៤ ៥៨៣,៤៨ | ១ ៩៨០ |
| ផ្លូវលំដីស/ផ្លូវរទេះ | ៩៩ ៩៧១,៧៤ | ៩៩ ៩៧១,៧៤ | ០០ |
| ប្រឡាយមេ | ៣ ៧៥៣,៧៩ | ៣ ៧៥៣,៧៩ | ០០ |
| ប្រឡាយរង | ៤ ០២៤,៥៣ | ៤ ០២៤,៥៣ | ០០ |
| ប្រឡាយតូច | ៣៨ ៤៣២,៨៣ | ៣៨ ៤៣២,៨៣ | ០០ |

តារាង 39៖ តារាងផែនការផ្នែកសេវាកម្មនាពេលអនាគត

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំ២០១៧ | ចំនួនសម្រាប់១៥ឆ្នាំក្រោយ | បម្រែបម្រួល |
|---|---|---|---|
| សាលាមតេយ្យ | ២អគារ/២បន្ទប់ | ៥អគារ/២៦បន្ទប់ | ៣អគារ/២៤បន្ទប់ |
| សាលាបឋមសិក្សា | ៧អគារ/៥៧បន្ទប់ | ៨អគារ/៤៧បន្ទប់ | ១អគារ/-១០បន្ទប់ |
| សាលាអនុវិទ្យាល័យ | ១អគារ/១១បន្ទប់ | ២អគារ/២៣បន្ទប់ | ១អគារ/១២បន្ទប់ |
| សាលាវិទ្យាល័យ | ០អគារ/០បន្ទប់ | ២អគារ/២៤បន្ទប់ | ២អគារ/២៤បន្ទប់ |
| មណ្ឌលសុខភាព | ០១កន្លែង | ០១កន្លែង | ០កន្លែង |

### ៣.២.២. ផែនទីប្រើប្រាស់ដីអនាគត

ការកំណត់ការប្រើប្រាស់ដី នាពេលអនាគតនៅក្នុងឃុំចុងដូង គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវបំផុត ដោយធ្វើការពឹងផ្អែកទាំងស្រុងទៅលើការវិភាគដី ដ៏សមស្របមួយ តាមរយៈការវាយតម្លៃបែបសាមញ្ញ ទៅលើធនធានដី រយៈកម្ពស់ ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីក្នុងឃុំ នាពេលបច្ចុប្បន្ន ដោយយកផែនទីប្រើប្រាស់ដីធ្លីបច្ចុប្បន្ន ធ្វើជាមូលដ្ឋាន សម្រាប់នៅក្នុងការគិតគូរពិចារណា ដូចមានរំលេចឱ្យឃើញនៅក្នុងតារាងប្រើប្រាស់ដីពេលអនាគតខាងលើនេះ ព្រមទាំងនៅក្នុងផែនទីប្រើប្រាស់ដី នាពេលអនាគតដូចខាងក្រោមនេះ ដែលសមស្របអាចទទួលយកបាន និងអាចប្រើប្រាស់មានប្រសិទ្ធិភាពតាមរយៈការបង្ហាញយ៉ាងពិស្តារពីជម្រើសដ៏ល្អសម្រាប់ការប្រើប្រាស់ដី នាពេលអនាគតរបស់ឃុំនេះ ។ ទន្ទឹមនឹងនោះផែនទីប្រើប្រាស់ដីនាពេលអនាគតខាងក្រោម ក៏មានការអត្ថាធិប្បាយលម្អិតទៅលើតំបន់ប្រើប្រាស់ដីនីមួយៗ ដែលបានកំណត់នៅលើផែនទីនេះផងដែរ ។

ផែនទី 12៖ ផែនទីប្រើប្រាស់ដីពេលអនាគត ឃុំចុងដូង



### ៣.២.៣. សេចក្តីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត

ផ្អែកទៅតាមផែនទីប្រើប្រាស់ដីនាពេលអនាគតខាងលើ បានបង្ហាញឱ្យឃើញពីប្រភេទនៃការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង ដូចខាងក្រោម ៖

#### ក. ដីលំនៅឋាន ភូមិ៖

ដីលំនៅឋាន ភូមិ គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និង ឈើហូបផ្លែ។ នៅក្នុងឃុំចុងដូង ដីលំនៅឋានភូមិនៅពេលអនាគត មានផ្ទៃដីទំហំសរុប ៤១៨,៦៦ហិកតា ក្នុងនោះដីលំនៅឋានភូមិក្រៅតំបន់ការពារមានផ្ទៃដីទំហំ ១៥៧,៣២ហិកតា ដែលស្ថិតនៅពីរទីតាំង គឺទីតាំងទី១ ស្ថិតនៅភាគខាងកើតនៃឃុំ មាន ០១ភូមិ គឺភូមិកំប៉ើយ និង ០២ទីតាំងទៀត ស្ថិតនៅតាមបណ្តោយជាប់ផ្លូវជាតិលេខ៦ ដែលមានចំនួន ០៤ ភូមិ គឺភូមិទួលដំណាក់ ភូមិពពេជ ភូមិចុងដូង និងភូមិទួលសាលា (មួយផ្នែកស្ថិតនៅខាងកើតជាប់ផ្លូវជាតិលេខ៦) ។ ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ២២២,៣០ ហិកតា ស្ថិតនៅខាងលិចផ្លូវជាតិលេខ៦ មាន០១ភូមិ គឺភូមិខ្សាច់ល្អិត និងនៅខាងលិចផ្លូវជាតិលេខ៦ឆៀងខាងត្បូងនៃឃុំ មាន ០១ភូមិ គឺភូមិគួរ ចំណែកដីលំនៅឋាន ភូមិ ក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ៣៩,០៥ ហិកតា ដែលស្ថិតនៅបន្តពីដីតំបន់១ជុំវិញបឹងទន្លេសាប នៅភាគកណ្តាលនៃឃុំ មានចំនួន ០១ ភូមិ គឺ ភូមិសំរោង ។ ដីលំនៅឋានភូមិស្ថិតនៅក្រៅតំបន់ការពារ គឺជាដីដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ (ជាដីកម្មសិទ្ធិឯកជន) លើកលែងតែដីលំនៅឋានភូមិ ដែលស្ថិតក្នុងដីតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលបច្ចុប្បន្ននេះ ត្រូវបានប្រជាពលរដ្ឋសាងសង់ជាដីលំនៅឋាន ពឹងផ្អែកទៅលើប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និង ស្រោចស្រពដំណាំរួមផ្សំជុំវិញលំនៅឋាន បានមកពីស្ទឹងជីនិត អណ្តូងស្នប់ ត្រពាំង បឹង និងស្រះ ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម ម៉ាស៊ីនបូមទឹក និងស្នប់សប់ដៃ ។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជា ដីសម្រាប់សាងសង់លំនៅឋានដដែល ដោយពុំមានការពង្រីកបន្ថែម សម្រាប់ដោះស្រាយនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ ២០៣២ នោះទេ តែនឹងត្រូវបាត់បង់ចំពោះដីលំនៅឋានក្នុងតំបន់២ជុំវិញបឹងទន្លេសាប ដែលទៅថ្ងៃអនាគតអាជ្ញាធរ ដែលពាក់ព័ន្ធត្រូវស្នើសុំការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាល ដើម្បីជូនប្រជាពលរដ្ឋ បើសិនជាពុំមានការអនុញ្ញាតពីរាជរដ្ឋាភិបាលទេនោះ ដីនេះនឹងត្រូវប្រើប្រាស់ជាដីព្រៃលិចទឹកឡើងវិញ ។ ដោយបច្ចុប្បន្ននេះ ដីលំនៅឋានភូមិនៅទូលាយអាចដោះស្រាយសម្រាប់សាងសង់លំនៅឋានរហូតដល់ឆ្នាំ២០៣២បាន។ ដីលំនៅឋានភូមិ នាពេលបច្ចុប្បន្នគិតក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលនៃការសិក្សារៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូងបានឱ្យដឹងថា ដីលំនៅឋានភូមិ ត្រូវបានប្រើប្រាស់មានទំហំផ្ទៃដីជាមធ្យមប្រមាណជា ០,១៤ហិកតា ក្នុងមួយគ្រួសារ តែនៅពេលអនាគត១៥ឆ្នាំខាងមុខ ទំហំដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារ បើផ្អែកតាមកំណើនប្រជាជននៅក្នុងឆ្នាំ២០៣២ មានទំហំប្រមាណជា ០,១១ហិកតា/គ្រួសារប៉ុណ្ណោះ ។

#### ខ. ដីស្រែវស្សា

នៅក្នុងឃុំចុងដូង ដីដែលបានកំណត់ការប្រើប្រាស់សម្រាប់ស្រែវស្សានាពេលអនាគតមានផ្ទៃដីសរុបទំហំ ៤ ៥៦០,៦៤ហិកតា ក្នុងនោះដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ១៥៧,៣២ ហិកតា ស្ថិតនៅខាងកើតផ្លូវជាតិលេខ៦ និងដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានទំហំ ២ ២៦១,៩៨ ហិកតា ស្ថិតនៅខាងលិចផ្លូវជាតិលេខ៦ ហើយដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានទំហំ ១ ៤០៤,២០ហិកតា ស្ថិតនៅបន្តពីដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាបមកទល់ដីស្រែប្រាំង ដែលបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់

ដោយពុំមានការពង្រីកបន្ថែម សម្រាប់ដំណោះស្រាយទៅនឹងកំណើនប្រជាជនរហូតឆ្នាំ ២០៣២ នោះឡើយ ។ ដីស្រែវស្សាស្ថិតនៅភាគច្រើនស្ថិតនៅភាគខាងលិចជាប់ផ្លូវជាតិលេខ៦ និងមានចំនួនតិចតួចស្ថិតនៅភាគខាងកើតជាប់ផ្លូវជាតិលេខ៦ ជាតំបន់ដីដែលមានស្ថាពភាពរមៀលក្រួច និងដីជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីកណ្តោង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ ។ ដីស្រែវស្សាទាំងនេះ ត្រូវពឹងផ្អែកលើប្រភពទឹកសម្រាប់ស្រោចស្រពពីទឹកភ្លៀង ស្ទឹង បឹង អូរ ស្រះទឹក និងទំនប់ទឹក ដែលបានមកស្រោចស្រពតាមរយៈប្រឡាយមេ និងប្រឡាយរង ដោយប្រើប្រាស់ម៉ាស៊ីនបូមទឹក ។ នាពេលអនាគត ទីតាំងដីស្រែវស្សាដែលមានស្រាប់នាពេលបច្ចុប្បន្ននេះ នឹងត្រូវរក្សាទុកជាដីស្រែដដែល ដោយសារដីនេះមានស្ថានភាពជាដីទំនាបលិចទឹកនៅរដូវវស្សា សមស្របសម្រាប់ដំណាំស្រូវ ទទួលបានផលិតផលផ្គត់ផ្គង់ទៅដល់ការហូបចុកសម្រាប់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំនិងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅ ដើម្បីបង្កើនបាននូវប្រាក់ចំណូលក្នុងគ្រួសារ និងចំណូលថវិកាជាតិ ។ ដោយឡែកដីស្រែវស្សានៅក្នុងតំបន់២ជុំវិញបឹងទន្លេសាប នឹងត្រូវបាត់បង់ទៅវិញនៅពេលថ្ងៃអនាគត អាជ្ញាធរពាក់ព័ន្ធត្រូវស្នើសុំការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាល ដើម្បីជូនទៅប្រជាពលរដ្ឋ បើពុំមានការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាលទេនោះ ដីនេះនឹងត្រូវប្រើប្រាស់ជាដីព្រៃលិចទឹកវិញ ។

### គ. ដីស្រែប្រាំង

នៅក្នុងឃុំចុងដូង ដីដែលបានកំណត់ការប្រើប្រាស់សម្រាប់ស្រែប្រាំងនាពេលអនាគតមានផ្ទៃដីសរុបទំហំ ៣១៣,២០ហិកតា ក្នុងនោះដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ២១៨,៨៥ហិកតា ស្ថិតនៅបន្តពីដីស្រែប្រាំង និងវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប និងដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានផ្ទៃទំហំ ៩៤,២១ ហិកតា ស្ថិតនៅភាគខាងលិចនៃឃុំមកទល់នឹងតំបន់ព្រៃលិចទឹក ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីស្រែប្រាំង ដោយពុំមានពង្រីកបន្ថែមសម្រាប់ដោះស្រាយនឹងកំណើនប្រជាជនរហូតឆ្នាំ២០៣២នោះឡើយ ។ ដីស្រែប្រាំង ភាគច្រើនស្ថិតនៅភាគខាងលិចនៃឃុំ ជាតំបន់រមៀលក្រួច និងដីជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីកណ្តោង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ ។ ដីស្រែប្រាំងនេះ ត្រូវពឹងផ្អែកលើប្រភពទឹកសម្រាប់ស្រោចស្រពពីទឹកភ្លៀង បឹង អូរ ។ នាពេលអនាគត ទីតាំងដីស្រែប្រាំងទាំងនេះ នឹងត្រូវរក្សាទុកជាដីស្រែដដែល ដោយសារតែដីនេះមានស្ថានភាពជាដីទំនាបលិចទឹកនៅរដូវវស្សាសមស្រប សម្រាប់ដំណាំស្រូវប្រាំងទទួលបានផលិតផលផ្គត់ផ្គង់ដល់ការហូបចុក សម្រាប់ជីវិតរស់របស់ប្រជាពលរដ្ឋនៅក្នុងឃុំ និងសល់លក់ទៅទីផ្សារក្នុងនិងក្រៅស្រុក ដើម្បីបង្កើនបាននូវប្រាក់ចំណូលក្នុងគ្រួសារ និងចំណូលថវិកាជាតិ។ ចំពោះដីស្រែប្រាំងក្នុងតំបន់២និងតំបន់៣ នឹងត្រូវបាត់បង់ទៅវិញនៅពេលថ្ងៃអនាគត បើពុំមានការអនុញ្ញាតឱ្យធ្វើអនុប្បយោគជូនទៅប្រជាពលរដ្ឋពីរាជរដ្ឋាភិបាលទេនោះ ដីស្រែទាំងនេះនឹងត្រូវប្រើប្រាស់ជាដីព្រៃលិចទឹកវិញ ។

### ឃ. ដីស្រែប្រាំងនិងវស្សា

នៅក្នុងឃុំចុងដូង ដីដែលបានកំណត់ការប្រើប្រាស់សម្រាប់ស្រែប្រាំងនិងវស្សានាពេលអនាគតមានផ្ទៃដីសរុបទំហំ ៣ ៩៨១,៥០ហិកតា ដែលក្នុងនោះដីស្រែប្រាំងនិងវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ៣ ៩៧៩,៥០ហិកតា នៅបន្តពីដីស្រែប្រាំងនិងស្រែវស្សា និងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប និងដីស្រែប្រាំងនិងវស្សាក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានផ្ទៃទំហំ ២,០១ហិកតា ស្ថិតនៅភាគខាងលិចនៃឃុំបន្តពីដីតំបន់២ជុំវិញបឹងទន្លេសាបមកទាល់ដីព្រៃលិចទឹកដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាក់ស្តែងសម្រាប់ស្រែប្រាំងនិងវស្សា

ដដែល ដោយពុំមានពង្រីកបន្ថែមសម្រាប់ដំណោះស្រាយទៅនឹងកំណើនប្រជាជនរហូតឆ្នាំ២០៣២នោះឡើយ ។ ដីស្រែប្រាំងនិងវស្សា ស្ថិតនៅភាគច្រើនស្ថិតនៅភាគខាងលិចនៃឃុំ ហើយជាតំបន់ដី ដែលមានស្ថាពភាពរមៀលក្រួច និងដីជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីកណ្តេង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ។ ដីស្រែប្រាំងនេះ ត្រូវពឹងផ្អែកលើប្រភពទឹកសម្រាប់ស្រោចស្រពពីទឹកភ្លៀង បឹង អូរ ស្រះទឹក ដែលបានមកស្រោចស្រពតាមរយៈប្រឡាយមេ និងរង ដោយប្រើប្រាស់មធ្យោបាយម៉ាស៊ីនបូមទឹក។ នាពេលអនាគត ទីតាំងដីស្រែប្រាំងនិងវស្សា ដែលមានស្រាប់នាពេលបច្ចុប្បន្ន នឹងត្រូវរក្សាទុកជាដីស្រែដដែល ដោយសារដីនេះមានស្ថានភាពជាដីទំនាបលិចទឹកនៅរដូវវស្សាសមស្រប សម្រាប់ដំណាំស្រូវប្រាំងនិវស្សា ទទួលបានផលិតផលផ្គត់ផ្គង់ដល់ការហូបចុកសម្រាប់ជីវិតរស់របស់ប្រជាពលរដ្ឋក្នុងឃុំ និងនៅសល់លក់ទៅទីផ្សារក្នុង និងក្រៅ ដើម្បីបង្កើនបាននូវប្រាក់ចំណូលក្នុងគ្រួសារ និងចំណូលថវិកាជាតិ ។ ចំពោះដីស្រែប្រាំងនិងវស្សាក្នុងតំបន់២និងតំបន់៣ជុំវិញបឹងទន្លេសាប នឹងត្រូវបាត់បង់ទៅវិញ នៅពេលថ្ងៃអនាគត អាជ្ញាធរដែលពាក់ព័ន្ធត្រូវស្នើសុំការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាលដើម្បីជូនប្រជាពលរដ្ឋធានា សុវត្ថិភាពកាន់កាប់ជាកម្មសិទ្ធិផ្ទាល់ខ្លួនបាន បើពុំមានការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាលទេនោះ ដីនេះនឹងត្រូវប្រើប្រាស់ជាដីព្រៃលិចទឹកវិញ ។

### ង. ដីចម្ការ

នៅក្នុងឃុំចុងដូង ដីដែលបានកំណត់ការប្រើប្រាស់សម្រាប់ដំណាំចម្ការ ដែលផ្តោតសំខាន់ទៅលើដំណាំឧស្សាហកម្មនាពេលអនាគតមានផ្ទៃដីសរុបទំហំ ៤១,៥៦ហិកតា ដែលក្នុងនោះមានដីចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ២២,៤៣ ហិកតា ស្ថិតនៅខាងចុងភាគខាងជើងនៃឃុំជាប់ព្រំប្រទល់ជាមួយឃុំត្នោតជុំ និងដីចម្ការក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានផ្ទៃដីទំហំ ១៩,១៣ហិកតា ស្ថិតនៅភាគខាងត្បូងនៃឃុំជាប់ជាមួយឃុំបារាយណ៍ ហើយស្ថិតក្នុងតំបន់សត្វខ្សឹប ដែលជាប្រភេទដំណាំស្វាយចន្ទី ។ ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាក់ស្តែងជាដីចម្ការដំណាំស្វាយចន្ទី។ ដីចម្ការទាំងនេះមានសណ្ឋានភាពដីជាតំបន់ដី ដែលមានស្ថាពភាពរមៀលក្រួច និងដីជម្រាលពីកើតទៅលិច មានប្រភេទដីល្បាយខ្សាច់ ដីកណ្តេង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ ដោយពឹងផ្អែកលើទឹកភ្លៀង បឹង និងស្រះទឹកជាដើម។នាពេលអនាគតទីតាំងដីដែលត្រូវបានកំណត់ការប្រើប្រាស់ជាដីចម្ការដដែល ដោយសារដីនេះមានស្ថានភាពជាដីទំនាបមធ្យម ដែលសមស្របសម្រាប់ដំណាំចម្ការឧស្សាហកម្មទទួលបានផលិតផលផ្គត់ផ្គង់សម្រាប់ការនាំចេញទៅរកទីផ្សារ ដែលជាការប្រសើរជាងនេះទៀតនោះផលិតផលទាំងនេះ ត្រូវធ្វើការកែច្នៃមុននឹងនាំចេញទៅរកទីផ្សារ ដែលនាំឱ្យឃុំចុងដូងមានមូលដ្ឋានគ្រឹះកាន់តែរឹងមាំក្នុងការអភិវឌ្ឍន៍ឃុំខ្លួនឯងថែមទៀត ជាពិសេសនឹងនាំឱ្យកើនឡើងប្រាចំណូលក្នុងគ្រួសារ ក៏ដូចជា បានចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ ដោយឡែកដីចម្ការក្នុងគម្របព្រៃឆ្នាំ២០០២ នឹងត្រូវបាត់បង់ទៅវិញ នៅពេលថ្ងៃអនាគតអាជ្ញាធរដែនពាក់ព័ន្ធត្រូវស្នើសុំការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាលដើម្បីជូនប្រជាពលរដ្ឋ ធនាសុវត្ថិភាពកាន់កាប់ជាកម្មសិទ្ធិផ្ទាល់ខ្លួនបាន បើសិនពុំមានការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាលទេនោះ ដីនេះនឹងត្រូវប្រើប្រាស់ជាដីព្រៃឈើឡើងវិញ ។

### ច. ព្រៃគុម្ពោត

នៅក្នុងឃុំចុងដូង ដីដែលបានកំណត់ការប្រើប្រាស់ជាដីព្រៃគុម្ពោត មានផ្ទៃដីទំហំ ១២៧,៧១ហិកតា ក្នុងនោះមានព្រៃគុម្ពោតក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ៨៨,៨៤ហិកតា ដែលមានដីទួលតូចៗ ចំនួន ០៣កន្លែងផងដែរ នៅក្នុងនោះមាន ០២ទីតាំង ស្ថិតនៅភាគខាងជើងនៃឃុំ និង ០១ទីតាំង ស្ថិតនៅប៉ែកកណ្តាលនៃឃុំ និងព្រៃគុម្ពោតក្នុងគម្របព្រៃឈើឆ្នាំ២០០២ ត្រួតគ្នានឹងតំបន់២ នៅជុំវិញបឹងទន្លេសាប មានផ្ទដី

ទំហំ ៣៨,៨៧ហិកតា ស្ថិតនៅនៅប៉ែកកណ្តាលភាគខាងត្បូងនៃឃុំ ដែលបច្ចុប្បន្នជាក់ស្តែងជាដីព្រៃគុម្ពោតនិងដីទួល ០៣ កន្លែង ដដែល ។ ដីព្រៃគុម្ពោតទាំងនេះ មានសំបូរទៅដោយដើមឈើចំរុះដុះលាយឡំគ្នា មានដើមភ្នំភ្នែង ត្រស់ កប្បាសព្រៃ ស្នាច់ និងដើមរាំងជាដើម ហើយជាដីសាធារណៈរបស់រដ្ឋ ។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីព្រៃគុម្ពោតដដែល ដើម្បីប្រើប្រាស់បានជាប្រយោជន៍ក្នុងការជួយការពារពីការហូរច្រោះបាក់ដី ផ្តល់ ស្មៅ និងស្លឹកឈើដល់គោ ក្របី និងជាជម្រកសត្វស្លាបគ្រប់ប្រភេទ និងជាកន្លែងផ្តល់ខុសដុតចម្អិនអាហារ ។

### ឆ. ព្រៃជាមួយចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប

នៅក្នុងឃុំចុងដូង ដីដែលបានកំណត់ការប្រើប្រាស់ជាដីព្រៃជាមួយចម្ការក្នុងតំបន់ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ២៨,៥៦ ហិកតា ដែលបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់ជាដីព្រៃជាមួយចម្ការ ។ ដីព្រៃជាមួយចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងជើងឆៀងខាងកើតនៃឃុំ ជាប់ជាមួយព្រំប្រទល់ឃុំបល្ល័ង្គ សម្បូរទៅដោយដើមឈើចម្រុះដុះលាយឡំគ្នាដូចជា ដើមខ្លុង ត្បែង ត្រសេក និងចំបក់ជាដើម ។ល។ ហើយដីនេះជាដីកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ( ដីកម្មសិទ្ធិឯកជន )។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីព្រៃជាមួយចម្ការដដែល ព្រោះដីព្រៃនេះផ្តល់នូវគម្របព្រៃសម្រាប់ជាម្លប់ដល់មនុស្ស សត្វ និងផ្តល់ជីវជាតិនិងផ្តល់នូវឧស្ម័នអុកស៊ីសែនដល់មនុស្ស និងស្រូបយកឧស្ម័នកាបូនិក ជាជម្រកសត្វព្រៃ ផ្តល់ខ្យល់អាកាសបរិសុទ្ធ ជួយទប់ទល់ខ្យល់ព្យុះ និងទឹកជំនន់ ជួយទាក់ទាញទឹកភ្លៀង និងជួយរក្សាលំនឹងអាកាសធាតុ ។ល។

### ជ. ព្រៃលិចទឹក

នៅក្នុងឃុំចុងដូង ដីដែលបានកំណត់ការប្រើប្រាស់ជាដីព្រៃលិចទឹកមានផ្ទៃដីទំហំ២ ៦៨៨,១៦ហិកតា ដែលបច្ចុប្បន្នជាក់ស្តែងជាដីព្រៃលិចទឹកដដែល ។ ដីព្រៃលិចទឹកស្ថិតនៅចុងភាគខាងជើងឆៀងខាងលិចនៃឃុំនៅក្នុងតំបន់ការពារព្រៃលិចទឹកជុំវិញបឹងទន្លេសាប ដែលសម្បូរទៅដោយដើមឈើចម្រុះដុះលាយឡំគ្នាដូចជាដើមភ្នំភ្នែង ត្រស់ កប្បាសព្រៃ ស្នាច់ និងដើមរាំងជាដើម ។ល។ ហើយដីនេះ ជាដីសាធារណៈរបស់រដ្ឋ ដែលទទួលខុសត្រូវលើ ការគ្រប់គ្រង ការការពារ និងការថែរក្សាដោយអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ និងមានរដ្ឋបាលជលផល ជាអ្នកធ្វើការត្រួតពិនិត្យជាប្រចាំលើសកម្មភាពថែរក្សា ការពារ និងចាត់វិធានការតាមច្បាប់ក្នុងករណីពិនិត្យឃើញថា មានសកម្មភាពដែលនាំឱ្យប៉ះពាល់ដល់ព្រៃលិចទឹកនេះ ។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីព្រៃលិចទឹកដដែល ពីព្រោះដីព្រៃលិចទឹកនេះត្រូវបានរាជរដ្ឋាភិបាលកំណត់ជាដែនព្រៃលិចទឹកជុំវិញបឹងទន្លេសាបត្រូវការពារដាច់ខាត ដើម្បីការពារ និងថែរក្សាទុកធ្វើឱ្យមានលំនឹងធម្មជាតិ ជម្រកមច្ឆាជាតិ របបជលសាស្ត្រ ការសាយភាយនៃល្បាប់ និងប្រព័ន្ធជីវចម្រុះនៃបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធដោយហាមដាច់ខាតការកាប់រាន ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹក និងការសាងសង់សំណង់គ្រប់ប្រភេទ ។

### ឈ. បឹង

ដីបឹងបច្ចុប្បន្ន ជាបឹងធម្មជាតិ ហើយមានចំនួន ១០កន្លែង ដែលត្រូវបានប្រើប្រាស់ជាប្រភពទឹកស្រោចស្រព និងសម្បូរទៅដោយធនធានជលផល ។ ដីបឹងទាំងនេះ មានទំហំផ្ទៃដីសរុបចំនួន ៤២៩,៨៧ហិកតា ដែលស្ថិតនៅរាយប៉ាយក្នុងភូមិសាស្ត្រឃុំ គឺជាដីសាធារណៈរបស់រដ្ឋ ។បឹងទាំងនេះ ជាតំបន់ទំនាបលិចទឹកតាមរដូវ និងមានស្ថានភាពជាដីទំនាបងាយលិចទឹកនៅរដូវវស្សា ។ នាពេលអនាគត ដីបឹងនេះនឹងនៅតែជាប្រភពទឹក

ស្រោចស្រព និងប្រើប្រាស់ច្រើនយ៉ាងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែលព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្គត់ផ្គង់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

ញ. ស្ទឹង

នៅក្នុងឃុំចុងដូង ដីដែលបានកំណត់ការប្រើប្រាស់ជាដីស្ទឹង មានផ្ទៃដីសរុបទំហំ ១៤៧,៧០ ហិកតា ដែលបច្ចុប្បន្នជាក់ស្តែងជាស្ទឹងធំនិត និងជាដីសាធារណៈរបស់រដ្ឋ ដែលជាប្រភពទឹកស្រោចស្រពយ៉ាងសំខាន់នៅក្នុងឃុំ មានសម្បូរទៅដោយមច្ឆាជាតិជាច្រើន ។ ស្ទឹងនេះ មានទំនាក់ទំនងគ្នាពីខ្សែទឹកខាងលើរួចហូរចុះទៅភាគខាងលិចឆៀងខាងត្បូងជាផ្នែកខាងក្រោមនិងបន្តហូរទៅទៅបឹងទន្លេសាប។ នាពេលអនាគតស្ទឹងនេះ គឺជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្គត់ផ្គង់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ដែលត្រូវការពារថែរក្សា ដោយហាមដាច់ខាតការចាប់រានកាន់កាប់ដីមាត់ស្ទឹងប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន ។

ដ. ស្រះ

ដីស្រះបច្ចុប្បន្ននៅក្នុងឃុំចុងដូង ដីដែលបានកំណត់ប្រើប្រាស់ជាដីស្រះមានចំនួន១០កន្លែង មានផ្ទៃដីទំហំ ១២,៦១ហិកតា ក្នុងនោះស្រះទឹកក្រៅតំបន់ការពារមានចំនួន ០៣កន្លែង ទំហំ ១,៦៥ហិកតា ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាប មាន ០៣កន្លែង ទំហំ ២,៣០ហិកតា ស្រះទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប មាន ០៤កន្លែង ទំហំ ៨,៦៦ហិកតា ។ ស្រះទាំងនេះ ភាគច្រើនស្ថិតនៅលាយឡំគ្នាជាមួយដីលំនៅឋាននិងដីស្រែ ហើយត្រូវបានប្រើប្រាស់ជាប្រភពទឹកស្រោចស្រព ដែលសម្បូរទៅដោយមច្ឆាជាតិ ។ ដីស្រះទាំងនេះ ជាកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ លើកលែងតែស្រះទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ។ នាពេលអនាគត ស្រះទឹកនេះនឹងនៅតែជាប្រភពទឹកស្រោចស្រព និង ប្រើប្រាស់ច្រើនយ៉ាងក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផល សម្រាប់ជាអាហារផ្គត់ផ្គង់ប្រូតេអ៊ីនយ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

## ៣.៣.ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី

ជាការពិតនៅក្នុងពេលបច្ចុប្បន្ននេះ យើងបានរកឃើញថា នៅក្នុងឃុំចុងដូង មានប្រជាពលរដ្ឋ ក្រីក្រខ្វះខាតដីលំនៅឋានចំនួន ៣២ គ្រួសារ និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារពិតប្រាកដ មានចំនួន ២៨២ គ្រួសារ ដូចបានអធិប្បាយនៅក្នុងជំពូកទី ១ នៃរបាយការណ៍នេះ ដែលប្រជាពលរដ្ឋមួយចំនួនកំពុងរស់នៅលើដីចិញ្ចើមផ្លូវ ដីចំណីប្រឡាយ និងលើដីចំណីអូរ និងមួយចំនួនទៀតរស់នៅក្នុងខ្ទមលើដីរបស់អ្នកដទៃ ដែលពួកគាត់កំពុងស៊ីឈ្នួលធ្វើការឱ្យគេ ដើម្បីចិញ្ចឹមជីវិត ។ ដូច្នេះដើម្បីដោះស្រាយដី សម្រាប់សាងសង់លំនៅឋាន និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដែលអាចផ្តល់ឱកាសឱ្យពួកគាត់ មានជម្រកសម្រាប់រស់នៅសមរម្យ និងបង្កើតឱកាសការងារ ដើម្បីទទួលបានប្រាក់ចំណូលជូនពួកគាត់បានអាជ្ញាធរដែនដីនៅគ្រប់ជាន់ថ្នាក់ត្រូវខិតខំដោះស្រាយតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់ក្រោមជាតិ ដែលត្រូវផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាឃុំចុងដូង។ ដីធ្លីដែលត្រូវដោះស្រាយជូនពួកគាត់ ដូចបានធ្វើការវិភាគដោះស្រាយនៅក្នុងជំពូកទី ២ នៅត្រង់ចំណុច ២.១.៣ ខាងលើ គឺដីសម្រាប់លំនៅឋានមានទំហំ ០៨ហិកតា និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារមានទំហំ ៥៦៤ហិកតា។

## ៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

និរន្តរភាពនៃការប្រើប្រាស់ដី គឺជាការធានាឱ្យបាននូវគោលដៅ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ដីទាំងនោះ ដែលការធានាទាំងអស់នេះ ត្រូវតែកើតមានឡើងជាបន្តបន្ទាប់ជារៀងរហូត ដោយពុំមានឈប់ឈរ។ និរន្តរភាព គឺជាចំណុចស្នូលសម្រាប់ការប្រើប្រាស់ដីនៅគ្រប់តំបន់គោលដៅទាំងអស់តាមរយៈការកំណត់កត្តាចាំបាច់នានា សម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាព និងធានាឱ្យមាននិរន្តរភាព។

### ៣.៤.១. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍន៍ សេដ្ឋកិច្ចសង្គម ព្រមទាំងថែរក្សាការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព ។ ដោយធានាបានការផ្គត់ផ្គង់សេចក្តីត្រូវការ និងការទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន និងបន្តទៅដល់កូនចៅ របស់ពួកគាត់ទៅជំនាន់ក្រោយទៀតបាននោះ ត្រូវតែយកចិត្តទុកដាក់ដល់ការគ្រប់គ្រងទៅលើការប្រើប្រាស់សេវាកម្ម និងលើវិស័យទាំងអស់នៅក្នុងឃុំដែលបានកំណត់រួចតាមរយៈការខិតខំប្រឹងប្រែងអនុវត្តឱ្យសម្រេចបានទៅលើកត្តាចាំបាច់មួយចំនួនដូចខាងក្រោមៈ

ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម

បើពិនិត្យទៅលើលក្ខណៈភូមិសាស្ត្រ និងសក្តានុពលនៃធនធានដែលមាននៅក្នុងឃុំចុងដូង ដែលក្រុមការងារ បានធ្វើការសិក្សាស្រាវជ្រាវរកឃើញនោះ ត្រូវបានកំណត់យ៉ាងច្បាស់ថា ឃុំមានគោលដៅអភិវឌ្ឍទៅថ្ងៃអនាគតពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង ដែលនៅក្នុងនោះបានផ្តោតសំខាន់ទៅលើដំណាំស្រូវ និងចម្ការដំណាំឧស្សាហកម្មតិចតួច។ ដូចនេះ នៅឃុំចុងដូង នឹងមានតួនាទីសំខាន់មួយក្នុងការធ្វើឱ្យសម្រេចបាននូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករ ព្រមទាំងគោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ របស់រាជរដ្ឋាភិបាល ដែលត្រូវចាំបាច់ទាមទារឱ្យមានការគ្រប់គ្រងប្រព័ន្ធកសិកម្ម ក្នុងមូលដ្ឋានឱ្យរឹងមាំ និងមាននិរន្តរភាពទៅថ្ងៃអនាគត ដោយត្រូវយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវ និងដំណាំឧស្សាហកម្មដើម្បីបង្កើនទិន្នផលស្រូវ និងដំណាំឧស្សាហកម្មឱ្យបានខ្ពស់អស់សក្តានុពល ដើម្បីមានលទ្ធភាពនាំស្រូវចេញបានច្រើនសល់ពីការហូបចុក ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋ និងអាចមានលទ្ធភាពនាំផលិតផលដំណាំឧស្សាហកម្មចេញផងដែរ ។

ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍឃុំចុងដូងដូចខាងលើ ត្រូវមានការគ្រប់គ្រងដីស្រែ និងដីចម្ការក្នុងឃុំឱ្យបានច្បាស់លាស់ ដោយរាល់ការសម្រេចចិត្តប្តូរមុខងារប្រើប្រាស់ដី ពីកសិកម្មទៅបម្រើឱ្យការសាងសង់ និងបម្រើឱ្យការប្រើប្រាស់ផ្សេងទៀត ត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រកបទៅដោយតម្លាភាព ដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងត្រូវមានការផ្សព្វផ្សាយជាសាធារណៈ ។ ទន្ទឹមនឹងការគ្រប់គ្រងដីស្រែ ត្រូវគិតគូរពីទឹកស្រោចស្រព ដោយធ្វើយ៉ាងណា អាចធ្វើស្រែបង្កើនរដូវ និងស្រែប្រាំងឱ្យបានបីដងក្នុងមួយឆ្នាំ ដោយតាមរយៈការស្តារប្រព័ន្ធប្រឡាយចាស់ៗ និងកសាងប្រឡាយថ្មីបន្ថែមចំនួន ៧ខ្សែ ប្រវែង ១២ ២៨៧,៥២ម៉ែត្រ ដែលនៅក្នុងនោះមានប្រឡាយមេសាងសង់ថ្មី ០១ខ្សែ ប្រវែង ២ ៦៩៧ម៉ែត្រ ប្រឡាយរងសាងសង់ថ្មី ០១ខ្សែ ប្រវែង ១៣៤៣ម៉ែត្រ និងប្រឡាយតូចៗ ០៥ខ្សែ ប្រវែង ៨ ២៤៨ម៉ែត្រ សម្រាប់ជាមធ្យោបាយនៅក្នុងការនាំទឹកទៅស្រោចស្រពដីស្រែទាំងអស់បានគ្រប់គ្រាន់។ បន្ទាប់ពីកត្តាដី និងទឹកនៅមានកត្តាបច្ចេកទេសក្នុងការដាំដុះបន្ថែមទៀត ដោយត្រូវគិតគូរជំរុញការធ្វើស្រែ តាមបែបប្រពលវប្បកម្មទំនើបដូចដែលមានលើកឡើងតាមការវិភាគក្នុងជំពូកទី២ ត្រង់ចំណុចការផ្តល់ឱកាសដោយបច្ចេកវិទ្យាទំនើប ដែលកត្តានេះនឹងលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងារកសិកម្មបានច្រើនផងដែរ ព្រោះយុវជនតែងគិតថាការធ្វើស្រែនាំ

ឱ្យមានការនឿយហត់ ប្រឡាក់ប្រឡូកដីភក់ មិនស្អាតបាត ដែលជាការយល់ខុស គឺតាមពិតការធ្វើស្រែចម្ការតាមបច្ចេកទេសទំនើប កសិករក៏អាចស្លៀកពាក់បានស្អាតបាត និងពាក់ក្រវ៉ាត់កប្រើប្រាស់កុំព្យូទ័រនៅក្នុងបន្ទប់ម៉ាស៊ីនត្រជាក់បានដូចគ្នា។ នៅក្នុងការគ្រប់គ្រងប្រព័ន្ធកសិកម្មនៅឃុំចុងដូង មិនមែនយកចិត្តទុកដាក់តែនៅលើការជំរុញផលិតកម្មកសិកម្មដូចខាងលើប៉ុណ្ណោះទេ តែត្រូវខិតខំពង្រឹងការប្រមូលគ្នាចងក្រងជាសហគមន៍កសិករដើម្បីជ្រើសរើសតំណាងអាចទៅចូលរួមតស៊ូមតិក្នុងការចចាររកទីផ្សារ ក៏ដូចជាមួយឈ្មួញ ដោយធានាការធ្វើស្រែចម្ការបានទិន្នផលខ្ពស់មានគុណភាពតាមស្តង់ដាតម្រូវការទីផ្សារ និងធានាលំនឹងតម្លៃក្នុងទីផ្សារផងដែរ ។

តាមការគណនា ដែលផ្អែកទៅលើការការគិតគូរនៅក្នុងជំពូក២ ត្រង់ចំណុច ១.២.៣ អាចឱ្យយើងរំពឹងទុកអំពីបរិមាណផលស្រូវនាំចេញនាពេលអនាគតក្នុងអំឡុងពេល១៥ឆ្នាំខាងមុខដូចខាងក្រោមៈ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ប្រជាពលរដ្ឋកើនឡើងដល់ ១៦ ៧២៣នាក់

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ដីស្រែមានទំហំ ៦ ៨១៤ ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ទិន្នផលស្រូវជាមធ្យម ៤ តោនក្នុង១ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំនត់ធ្វើស្រែបាន៣ដងក្នុង១ឆ្នាំ

**-ដូច្នេះក្នុងអំឡុងពេល១៥ឆ្នាំ (២០១៧-២០៣១) ផលិតផលស្រូវទទួលបានក្នុង១ឆ្នាំជាមធ្យមៈ**

**៦ ៨១៤ហិកតា x ៤តោន/ហិតា x ៣ដង/ឆ្នាំ = ៨១ ៧៦៨ តោន/ឆ្នាំ**

ប្រជាពលរដ្ឋ១នាក់ ត្រូវការអង្ករសម្រាប់ហូបក្នុងមួយឆ្នាំមានចំនួន១៤៣គីឡូក្រាម ដែលបើគិតជាស្រូវត្រូវការចំនួន២២៤ គីឡូក្រាម (ផ្អែកតាមរបាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ)។

- ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងមួយឆ្នាំជាមធ្យម៖

១៦ ៧២៣នាក់ x ២២៤ គីឡូក្រាម/នាក់/ឆ្នាំ = ៣ ៧៤៥ ៩៥២ គីឡូក្រាម/ឆ្នាំ

ស្មើនឹងប្រហាក់ប្រហែល **៣ ៧៤៦តោន/ឆ្នាំ**

- ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណពូជស្រូវក្នុងមួយឆ្នាំជាមធ្យម៖

៦ ៨១៤ហិតា x ៣០០គីឡូក្រាម/ហិកតា/ឆ្នាំ x ៣ដង/ឆ្នាំ = ៦ ១៣២ ៦០០ គីឡូក្រាម/ឆ្នាំ

ស្មើនឹងប្រហាក់ប្រហែល **៦ ១៣២តោន/ឆ្នាំ**

- ដូច្នេះក្នុងអំឡុងពេល ១៥ ឆ្នាំ ផលិតផលស្រូវទទួលបានសម្រាប់ការនាំចេញក្នុងមួយឆ្នាំជាមធ្យម៖

៨១៧៦៨ តោន/ឆ្នាំ - (៣ ៧៤៦តោន/ឆ្នាំ + ៦ ១៣២ តោន/ឆ្នាំ) = ៧១ ៨៩០ តោន/ឆ្នាំ

**- តែបើគិតជាអង្ករវិញអាចនាំចេញបានក្នុងមួយឆ្នាំជាមធ្យម៖**

**៧១ ៨៩០ តោន/ឆ្នាំ x ៦០% = ៤៣ ១៣៤ តោន/ឆ្នាំ**

### ខ. ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត

នៅពេលអនាគត ទោះបីក្នុងឃុំចុងដូង បានកំណត់រក្សាទុកតំបន់ប្រើប្រាស់ដី សម្រាប់ព្រៃឈើមួយចំនួនដូចជា ព្រៃគុម្ពោត និងព្រៃលិចទឹក ក៏នៅក្នុងឃុំនៅមានដីតាមដងផ្លូវ ប្រឡាយទឹក ទីធ្លាសាលាឃុំ ទីធ្លាសាលារៀន ទីធ្លាមណ្ឌលសុខភាព ទីធ្លាវត្តអារាម និងនៅតាមលំនៅឋានជាដើម ដែលត្រូវធ្វើការជំរុញការដាំដើមឈើថែមទៀតដែរ ដើម្បីឱ្យមានដើមឈើពណ៌បៃតងនៅពាសពេញទូទាំងឃុំ បម្រើផលប្រយោជន៍ដូចបានលើកឡើងនៅក្នុងជំពូកទី២ នៃរបាយការណ៍នេះ ហើយត្រូវបន្តថែទាំដើមឈើទាំងនោះឱ្យបាននៅគង់វង្ស និង

លូតលាស់បានល្អ។ ដូច្នេះ ដើម្បីគ្រប់គ្រងធានានិរន្តរភាព នៃព្រៃឈើទាំងនេះ អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ ជាពិសេសនោះក្រុមប្រឹក្សាឃុំ ត្រូវមានវិធានការទប់ស្កាត់ការបាត់បង់ព្រៃឈើដូចមានរៀបរាប់ខាងក្រោម៖

- ជំរុញការចុះបញ្ជីដីរដ្ឋ
- ត្រូវបង្កើនការគោរពច្បាប់ដើម្បីការពារព្រៃឈើ
- ត្រូវដាក់ទោសចំពោះជនប្រព្រឹត្តបទល្មើសកាប់បំផ្លាញព្រៃឈើ
- ផ្សព្វផ្សាយពីផលប្រយោជន៍នៃព្រៃឈើ
- បណ្តុះបណ្តាលឱ្យប្រជាពលរដ្ឋមានស្មារតីម្ចាស់ការដាំដើមឈើ និងថែរក្សាព្រៃឈើ។

ដោយឡែកមច្ឆាជាតិ ដែលជាធនធានជលផល នៅក្នុងឃុំចុងដូង បានកំណត់ បឹងរៀល បឹងលួងយ៉ាន់ បឹងត្រាវ បឹងអាស្រួល បឹងត្រស់ បឹងអាកង បឹងផ្ទោល បឹងត្រើយម៉ាកង និងស្រះទឹក ជាប្រភពធនធានទាំងនេះ តែទៅថ្ងៃអនាគតក៏ត្រូវខិតខំយកចិត្តទុកដាក់ នៅក្នុងការចិញ្ចឹមត្រីថែមទៀត ដើម្បីបានផលគ្រប់គ្រាន់ អាចផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋ នៅក្នុងឃុំ ។ ចំពោះស្ថានភាពសមស្របក្នុងឃុំគួរចិញ្ចឹមត្រីតាមបែបចិញ្ចឹមក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារ និងកសិដ្ឋានចិញ្ចឹមត្រីនៅក្នុងស្រែដែលជាទម្រង់មួយនៃការបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលតាមប្រពលវប្បកម្ម (តាមវាលស្រែ) ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងនៅក្នុងស្រែ ដែលបំផ្លាញផលដំណាំផងដែរ ដូច្នេះដើម្បីធានាឱ្យមានការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ប្រកបទៅដោយនិរន្តរភាពតទៅអនាគត អាជ្ញាធរមានសមត្ថកិច្ច ជាពិសេសក្រុមប្រឹក្សាឃុំត្រូវមានវិធានទប់ស្កាត់ការបំផ្លាញធនធានជលផលនេះដូចខាងក្រោម៖

- ត្រូវគ្រប់គ្រង និងអភិរក្សធនធានជលផលឱ្យបានល្អ
- លុបបំបាត់ការធ្វើនេសាទលើសកម្រិត
- ថែរក្សា ការពារព្រៃលិចទឹកជាជម្រកត្រីពង
- ជំរុញការធ្វើវារីវប្បកម្មតាមគ្រប់រូបភាព
- ទប់ស្កាត់ការប្រើឧបករណ៍ឆក់ និងសារធាតុពុលគ្រប់ប្រភេទទៅលើធនធានជលផលគ្រប់ប្រភេទ

ចំណែកធនធានសំខាន់ៗ ក្រៅពីការរៀបរាប់នៅខាងលើនេះ នៅក្នុងឃុំពុំមានឃើញធនធានអ្វីផ្សេងដែលគួរឱ្យកត់សម្គាល់ឡើយ ។

### ៣.៨.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព

ដើម្បីមានមធ្យោបាយគ្រប់គ្រាន់ធ្វើឱ្យសម្រេចបាននូវការគ្រប់គ្រងប្រព័ន្ធកសិកម្ម និងធនធានសំខាន់ៗ សម្រាប់ការគាំទ្រដល់និរន្តរភាពនៃការអភិវឌ្ឍន៍ និងអភិរក្សដីធ្លីនិងធនធានធម្មជាតិនៅក្នុងឃុំចុងដូងចាំបាច់ត្រូវបង្កើតឲ្យមានគម្រោងគាំទ្រជាអាទិភាពមួយចំនួនដូចខាងក្រោម៖

- សាងសង់ និងស្តារប្រព័ន្ធធារាសាស្ត្រ
- ជួសជុល និងថែទាំផ្លូវថ្នល់
- កសាងផ្លូវក្រាលកៅស៊ូ ថ្មី
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម
- បណ្តុះបណ្តាលផលិតជីកំប៉ុស្ត
- បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី

- បណ្តុះបណ្តាលពីការដាំដំណាំស្រូវ
- តបណ្តាញទឹកស្អាតអោយបានដល់គ្រប់ភូមិ
- តបណ្តាញអគ្គិសនីអោយបានដល់គ្រប់ភូមិ
- បង្កើតទីលានចាក់សំរាម
- បង្កើតសហគមន៍កសិករ ដើម្បីជំរុញការអនុវត្តន៍ភូមិ១ ផលិតផល១
- ដាក់លូបង្ហូរទឹកតាមមុខផ្ទះនៅជាប់ផ្លូវ
- ដោះស្រាយដីសម្បទានសង្គមកិច្ច
- ជំរុញធ្វើប័ណ្ណក្រីក្រឱ្យដល់ស្ត្រីគ្រប់រូប
- ផ្តល់អាហាររូបត្ថម្ភដល់ស្ត្រី និងកុមារ
- ផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងការពារជម្ងឺដល់ស្ត្រីមានផ្ទៃពោះ និងកុមារ
- ពង្រឹងសេវាថែទាំសុខភាព និងព្យាបាលជម្ងឺជូនដល់ប្រជាពលរដ្ឋឲ្យបានល្អប្រសើរឡើង
- ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ
- ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់បទដ្ឋានគតិយុត្តនានា ជូនដល់ប្រជាពលរដ្ឋ

## ៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)

ផ្អែកលើលទ្ធផល នៃការសិក្សាស្រាវជ្រាវ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូងក្នុងឆ្នាំ ២០១៧នេះ បានឱ្យដឹងថា ឃុំចុងដូង ជាឃុំមួយក្នុងចំណោមឃុំ១០ របស់ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដែលមានភូមិចំនួន០៨ និងមានផ្ទៃដីទំហំសរុបចំនួន ១២ ៧១២,៣២ ហិកតា។ នៅក្នុងឆ្នាំ២០១៧ ឃុំចុងដូង មានប្រជាជនចំនួន ៣ ០៩០ គ្រួសារ ប្រជាជនសរុប ១៣ ៧៤៨ នាក់ ក្នុងនោះស្ត្រី ៦ ៩៦១ នាក់ ហើយមានដង់ស៊ីតេប្រជាជនជាមធ្យម ១២៧ នាក់/គ.ម$^{២}$។ ឃុំចុងដូង មានសណ្ឋានភាពដី រមៀលក្រួច និងជម្រាលពីកើតទៅលិច ដែលមានប្រភេទដីល្បាយខ្សាច់ ដីកណ្តោង ដីគ្រួសខ្មៅ ដីខ្សាច់ ក្រុមដីកំពង់សៀម ក្រុមប្រទះឡាង និងក្រុមដីព្រៃខ្មែរ ត្រូវបានប្រើប្រាស់សម្រាប់លំនៅឋាន ដំណាំស្រូវវស្សា និងស្រូវប្រាំង ដំណាំតាមរដូវ និងដំណាំឈើហូបផ្លែ ព្រមទាំងដីផេះពណ៌ខ្មៅ ដីល្បប់ ដីកណ្តោង ក្រុមគោកត្រប់ ក្រុមប្រទះឡាង និងក្រុមដីក្រគរ ចាប់ពីពាក់កណ្តាលឃុំទៅភាគខាងលិច ត្រូវបានប្រើប្រាស់សម្រាប់ដំណាំស្រូវប្រាំង ស្រូវប្រដេញទឹក បានផ្តល់នូវមុខរបរយ៉ាងសំខាន់ដល់ប្រជាពលរដ្ឋជាច្រើន ដែលមានរហូតដល់ប្រមាណ ៦០ភាគរយ និងផ្នែកសេវាកម្មមាន ៣១ភាគរយ ដែលនៅក្នុងនោះផ្នែកសិប្បកម្មមានចំនួន ០៩ភាគរយ ។ ទន្ទឹមនឹងនេះឃុំចុងដូង មានប្រព័ន្ធប្រឡាយចំនួន ១០ខ្សែ ប្រវែង ១៧ ២៥៩,៣៣ម៉ែត្រ នៅក្នុងនោះមានប្រឡាយតូចៗចំនួន៧ខ្សែ ប្រវែង១១ ៣៧០,១៨ម៉ែត្រ ប្រឡាយរង៣ខ្សែ ប្រវែង ៥ ៨៨៩,១៥ម៉ែត្រ និងមានទ្វារទឹក៨កន្លែង។ បន្ថែមពីលើនេះ ឃុំចុងដូង មានផ្លូវជាតិលេខ៦ ឆ្លងកាត់ គឺជាការផ្តល់ឱកាសឱ្យឃុំចុងដូង អាចទាញយកប្រយោជន៍ពីការអភិវឌ្ឍន៍ នៅតាមផ្លូវនេះបាន ហើយឃុំនៅមានផ្លូវផ្សេងទៀតគ្រប់គ្រាន់អាចភ្ជាប់ទំនាក់ទនងពីភូមិមួយទៅភូមិមួយក្នុងឃុំ និងអាចភ្ជាប់ទំនាក់ទំនងទៅឃុំ និងស្រុកផ្សេង រួមទាំងទីរួមខេត្តកំពង់ធំបានដោយងាយស្រួល។ ចំពោះកំណើនប្រជាជនវិញ បានរកឃើញថានៅក្នុងរយៈពេល១៥ឆ្នាំ ទៅមុខរហូតដល់ ឆ្នាំ២០៣២ នឹងមានប្រជាជនកើនឡើងរហូតដល់ ១៧ ២២៨ នាក់ ដែលនឹងត្រូវយកចិត្តទុកដាក់ក្នុងការគិតគូររកដំណោះស្រាយពីការប្រើប្រាស់ដីដើម្បីអាចឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាជន ។ ទន្ទឹមនេះក៏បានរកឃើញអំពីបញ្ហាប្រឈមមួយចំនួន ទៅលើសកម្មភាពនៃការអភិវឌ្ឍន៍ក្នុងឃុំចុងដូងបច្ចុប្បន្នផងដែរ ដូចជាការធ្វើស្រែដែលមានសក្តានុពលនៅក្នុងការអភិវឌ្ឍន៍ឃុំ មិនទាន់ទទួលបានផលស្រូវសមស្របអស់លទ្ធភាព នៅឡើយដោយសារដីស្រែទាំងនេះកាន់តែខ្សត់ជីជាតិ ខ្វះទឹកស្រោចស្រពសម្រាប់ផ្គត់ផ្គង់

ដល់ការធ្វើស្រែបង្កើនរដូវ ខ្វះចំណេះដឹងពីបច្ចេកទេសនៃការដាំដុះ ខ្វះចំណេះដឹងពីបច្ចេកទេសនៃការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម ប្រព័ន្ធប្រឡាយដែលមានស្រាប់បានរាក់ ខ្វះកម្លាំងពលកម្ម ដោយសារមានចំណាកស្រុកច្រើន បាត់កម្លាំងពលកម្មជិតពាក់កណ្តាល នៃកម្លាំងពលកម្មដែលមាន និងតម្លៃកសិផលមិនមានស្ថិរភាព ដោយឈ្មួញជាអ្នកកំណត់តម្លៃ ។ ទន្ទឹមនឹងការរកឃើញពីបញ្ហាមួយចំនួនលើសកម្មភាពអភិវឌ្ឍឃុំ ក៏បានរកឃើញថាជាទូទៅការប្រើប្រាស់ដីនៅក្នុងឃុំបច្ចុប្បន្នបានចំទិសដៅ និងមានភាពសមស្រប ដូចជា ការប្រើប្រាស់ដីសម្រាប់លំនៅឋាន ដីកសិកម្ម ប្រព័ន្ធផ្លូវគមនាគមន៍ និងធារាសាស្ត្រជាដើម ដែលទៅថ្ងៃអនាគ ក៏នៅរក្សាមុខងារប្រើប្រាស់ដីទាំងនោះឱ្យនៅដដែល។ បន្ថែមលើនេះក៏បានរកឃើញវិធីដោះស្រាយបញ្ហាផ្សេងៗទៀតផងដែរ សម្រាប់អនាគតដូចជាត្រូវសាងសង់បន្ទប់រៀនបន្ថែម ពង្រឹងការផ្តល់សេវាសុខាភិបាលឱ្យបានប្រសើរឡើង ជំរុញឱ្យប្រជាពលរដ្ឋហូបទឹកស្អាត និងប្រើប្រាស់បង្គន់ អនាម័យ ជួសជុលផ្លូវ សាងសង់ផ្លូវ ស្តារប្រឡាយទឹក សាងសង់ប្រឡាយ ដាំដើមឈើនៅតាមទីសាធារណៈ ជំរុញការចិញ្ចឹមត្រីតាមស្រែ។ល។ ជាពិសេសដោះស្រាយដីសម្រាប់លំនៅឋាននៅក្នុងភូមិដែលមានស្រាប់ដែលពេលបច្ចុប្បន្ននេះនៅទូលាយអាចផ្គត់ផ្គង់ការសាងសង់លំនៅឋានបាន។ ដើម្បីដោះស្រាយនឹងកំណើនប្រជាជន ត្រូវពង្រឹងការធ្វើស្រែឱ្យបាន៣ដងនៅក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពល សម្រាប់ធ្វើការផ្គត់ផ្គង់ក្នុងការហូបចុក និងអាចមានលទ្ធភាពអាចនាំស្រូវចេញបានចំនួន ៧១ ៨៩០តោន/ឆ្នាំដើម្បីជួយផ្គត់ផ្គង់ដល់ជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងឃុំឱ្យបានកាន់តែប្រសើរឡើង ស្របទៅនឹងកំណើនរបស់ប្រជាពលរដ្ឋ ព្រមទាំងជួយជំរុញនូវកំណើនសេដ្ឋកិច្ចនៅក្នុងឃុំ។ ការដែលរកឃើញពីភាពសមស្រប និងជម្រើសសម្រាប់ការប្រើប្រាស់ដី នៅក្នុងឃុំចុងដូងនាពេលអនាគត បានមកពីការវាយតម្លៃដ៏ត្រឹមត្រូវ ដោយផ្អែកទៅលើធនធានដី រយៈកម្ពស់ដី ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះ ដើម្បីធានាថាការប្រើប្រាស់ដីនៅក្នុងឃុំចុងដូងទៅអនាគតប្រកបដោយចីរភាព និងសមធម៌។

ដូច្នេះដើម្បីសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង ស្របទៅតាមស្ថានភាពដីជាក់ស្តែង និងសក្តានុពលនៃធម្មជាតិ សម្រាប់ការគាំទ្រដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយចីរភាព និងសមធម៌ ចូលរួមចំណែកនៅក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនាពេលអនាគត ដូចដែលបានរកឃើញ និងមានចែងលម្អិតក្នុងរបាយការណ៍បច្ចេកទេសនេះ រដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធទាំងអស់ ជាពិសេសនោះក្រុមប្រឹក្សាឃុំ ដែលជាតំណាងឱ្យប្រជាពលរដ្ឋនៅក្នុងឃុំចុងដូង ហើយមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ ត្រូវខិតខំអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង ដែលបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួច ដោយបញ្ជៀបទៅនិងផែនការអភិវឌ្ឍន៍ឃុំ ឱ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ដើម្បីធានាភាពជោគជ័យនៃផែនការនេះ ៕

លេខ៖ 776/2020

បានពិនិត្យ និង សូមគោរពជូន

លោកអភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធានគណៈកម្មាធិការ

រៀបចំដែនដី និងនគរូបនីយកម្មស្រុកបារាយណ៍ មេត្តាពិនិត្យ និង សម្រេច។

ថ្ងៃ សុក្រ ១៣ កើត ខែ កត្តិក ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

ចុងដូង ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០២

មេឃុំចុងដូង

ឃុំ ចុងដូង

កែវ_អូក

លេខ៖ [illegible]/២០

បានពិនិត្យ និង សូមគោរពជូន

ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និង ជាប្រធានគណៈកម្មាធិការ

រៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ មេត្តាពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

បារាយណ៍ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០

អភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធាន

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកបារាយណ៍

អ៊ុង_សារឿន

លេខ៖ ៥៤៥៧/[illegible]

បានឃើញ និងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

ថ្ងៃ ព្រហស្បតិ៍ ៣កើត ខែ ភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

កំពង់ធំ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០២១

**អភិបាលនៃគណៈអភិបាលខេត្ត និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ**

សុខ_លុ

# ឯកសារឧបសម្ព័ន្ធ

# ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំចុងដូង



# ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំចុងដូង



# ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំចុងដូង




ផែនទីគម្រោងវិនិយោគ ឃុំចុងដូង
490000 mE
496000
502000
508000
514000 mE
1385000 mN
1380000
1375000
1370000
1365000 mN
ជ
ល
ក
ត
ខ្នាត់ស្រយ៉ូវ
ឃុំថ្វាង់
ឃុំតាំងក្រសាំង
ឃុំប្រាសាទ
ឃុំបឹងល្វា
ឃុំកកោះ
ត្បែងជុំ
ឃុំកំពង់ថ្ម
ឃុំបល្ល័ង្ក
ឃុំព្នៅ
ឃុំចុងដូង
សំរោង
ខ្សាច់ល្អិត
ចុងដូង
ទួលដំណាក់
ឃុំបឹង
ឃុំបារាយណ៍
ឃុំឈូកខ្សាច់
ឃុំត្នោតរៀល
មាត្រដ្ឋាន ១:១00000
0 0.៥ ១
គីឡូម៉ែត្រ
គាំទ្រដោយ
ADB
GAFSP
អនុវត្តដោយ
សញ្ញាសម្គាល់
ព្រំប្រទល់ និងទីតាំងរដ្ឋបាល
សាលាឃុំ
ភូមិ
ព្រំប្រទល់រដ្ឋបាលឃុំ
ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន
សាលារៀន
វត្ត
មន្ទីរពេទ្យ មណ្ឌលសុខភាព
ផ្លូវជាតិលេខ៦
ផ្លូវគ្រួសក្រហម
ផ្លូវលំដីស ឬផ្លូវរទេះ
ប្រឡាយមេ
ប្រឡាយរង
ប្រឡាយតូច
ប្រភេទប្រើប្រាស់ដីបច្ចុប្បន្ន
ដីលំនៅដ្ឋានភូមិ និងហេដ្ឋារចនាសម្ព័ន្ធ
ដីកសិកម្ម
ដីព្រៃ គម្របព្រៃ
ផ្ទៃទឹក និងខ្សែទឹក
គម្រោងវិនិយោគ
កសាងផ្លូវក្រាលបេតុង
កសាងផ្លូវគ្រួសក្រហម
ស្ពានប្រឡាយស្រោចស្រព
ប្រព័ន្ធកូអរដោនេ
ចំណោលផែនទី : UTM
តំបន់ទី : 48N
ទិន្នន័យយោង : WGS 1984
អេលីបសូអីត : WGS 1984
ប្រភពទិន្នន័យ
-ទីតាំងវិនិយោគ ប្រភពពីផែនការអភិវឌ្ឍឃុំរយៈពេល៥ឆ្នាំនិងអាជ្ញាធរមូលដ្ឋាន
-ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាលប្រភពពីនាយកដ្ឋានភូមិសាស្ត្រនៃ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០១៩)
-ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធថ្នាក់ខេត្ត
បញ្ជាក់
-ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងដោយ
ថ្នាក់ជាតិនិងត្រូវបានកែសម្រួលដោយបានចូលរួមពីសហគមន៍មូលដ្ឋាន
-ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់
ព្រំដែននៅផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
-ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ............... ឆ្នាំ២០....

# ឯកសារឧបសម្ព័ន្ធ




សកម្មភាពក្រុមការងារចូលរួមប្រជុំទទួលការណែនាំពីនីតិវិធីរៀបចំផែនការប្រើប្រាស់ដីថ្នាក់ឃុំ ពីប្រធានគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុន




សកម្មភាពប្រមូលទិន្នន័យនៅតាមមន្ទីរជុំវិញខេត្តរបស់ក្រុមការងារក្រុមហ៊ុន SBK




កិច្ចប្រជុំពិភាក្សាអំពីផែនទីប្រើប្រាស់ដីបច្ចុប្បន្នឃុំចុងដូង





សកម្មភាពក្រុមការងារចុះទីវាលស្រង់ទិន្នន័យបំពេញបន្ថែមលើ
ផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែលមានស្រាប់ឃុំចុងដូង





សកម្មភាពចូលរួមត្រួតពិនិត្យ ណែនាំ ការអនុវត្តគម្រោងរបស់អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO)





កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកបារយណ៍ ដើម្បីពិនិត្យ និងឯកភាពទៅលើ
សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង





កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ ដើម្បីពិនិត្យ និងឯកភាពទៅលើសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកបារាយណ៍
ក្រុមប្រឹក្សាឃុំចុងដូង

ថ្ងៃ......... ខែ......... ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
......... ថ្ងៃទី......... ខែ......... ឆ្នាំ២០២០.....

**សេចក្តីជូនដំណឹង**
**ស្តីពីការបិទផ្សាយជាសាធារណៈផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង**

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។
- កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/ ០១ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd។
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។
- តម្រូវការចាំបាច់នៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។

ដើម្បីធានាបាននូវការចូលរួមពីសាធារណជន និងស្របតាមការរៀបចំផែនការប្រើប្រាស់ដី និងលទ្ធផលការងារ ដែលសម្រេចបានទៅតាមនីតិវិធីតាមពេលកន្លងមក ក្រុមប្រឹក្សាឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ សូមគោរពជម្រាបជូនដល់គ្រប់ស្ថាប័ន អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបថា៖ នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០២០... ដល់ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០២១... ឃុំចុងដូង ធ្វើការរៀបចំបិទផ្សាយជាសាធារណៈនូវឯកសារ និងផែនការប្រើប្រាស់ដីអនាគតដែលសម្រេចបាន នៅទីតាំងសាលាឃុំខាងលើដើម្បីធ្វើការពិនិត្យ កែសម្រួល និងផ្តល់យោបល់ ។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធមេត្តាជួយផ្សព្វផ្សាយ និងចូលរួមពិនិត្យផ្តល់យោបល់អោយបានគ្រប់គ្រាន់ កុំបីអាក់ខានឡើយ ។

សូមបងប្អូនជនរួមជាតិ មេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ប្រធានក្រុមប្រឹក្សាឃុំ
[stamp: ឃុំចុងដូង]
កេង_សួរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកបារាយណ៍
ក្រុមប្រឹក្សាឃុំ ចុងដូង

**របាយការណ៍សង្ខេប**
**លទ្ធផល នៃការបិទផ្សាយជាសាធារណៈ នូវឯកសារផែនទី និង**
**សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ ចុងដូង**

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៣ រវាង រាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។
កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/ ០១ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd។
អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។
ក្រុមប្រឹក្សាឃុំចុងដូង បានបិទផ្សាយជាសាធារណៈនៅទីតាំង សាលាឃុំចុងដូង នូវឯកសារផែនទី និងសៀវភៅព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង (បានប្រជុំអនុម័តថ្នាក់ស្រុកបារាយណ៍រួចរាល់ជាស្ថាពរ) ចាប់ពីថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដល់ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២១ មានរយៈពេល ៤៥ ថ្ងៃជាលទ្ធផលមានដូចខាងក្រោម៖

**១. ផែនទីប្រើប្រាស់ដីនៅក្នុងឃុំ ចុងដូង**

- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីលម្អិតបច្ចុប្បន្ន មានទំហំជាខ្នាត A0
- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីអនាគតសម្រាប់រយៈពេល ១៥ឆ្នាំ ២០១៧ ដល់ ២០៣២ មានទំហំជាខ្នាត A0
- **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**

**២. សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ ចុងដូង**

- ជំពូក ១ ៖ ព័ត៌មានស្តីពី ស្ថានភាពឃុំចុងដូង
  - ចាប់ពី ១.១. ស្ថានភាពទូទៅនៃឃុំ ១.១.១. ទីតាំងរដ្ឋបាលឃុំ រហូតដល់ ១.៤. ទីផ្សារ និង ខ្សែសង្វាក់ផលិតផល ១.៤.៣. ឧបសគ្គ និង ឱកាស។
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**
- ជំពូក ២ ៖ ការវិភាគតម្រូវការ សក្តានុពល និង ឧបសគ្គសម្រាប់អនាគត
  - ចាប់ពី ២.១. តម្រូវការសម្រាប់អនាគត់ ២.១.១. ផែនការអភិវឌ្ឍន៍ឃុំ រហូតដល់ ២.៥. បញ្ហា មូលហេតុ និង ដំណោះស្រាយ។
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**
- ជំពូក ៣ ៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគត ឆ្នាំ២០១៧ ដល់ ២០៣២
  - ចាប់ពី ៣.១. តម្រូវការ ស្ថានភាព និង សក្តានុពលជាក់ស្តែង ៣.១.១. តម្រូវការដីទៅតាមប្រភេទ រហូតដល់ ៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**

- **ការវាយតម្លៃ** : ផ្អែកតាមឯកសារភស្តុតាង និងទិន្នន័យជាក់ស្តែង ដែលប្រមូលបាន លទ្ធផលនៃការបិទផ្សាយសាធារណៈនូវឯកសារ ផែនទី និង សៀវភៅព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ ចុងដូង សម្រាប់ឆ្នាំ ២០១៧ ដល់ ២០៣២ ជាយោបល់គួរដាក់ជូនគណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ ដើម្បីពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

ថ្ងៃ......... ខែ......... ឆ្នាំ......... ស័ក ព.ស. ២៥៦៤
ចុងដូង ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២១
ប្រធានក្រុមប្រឹក្សាឃុំ និងជា
មេឃុំចុងដូង
[stamp: ឃុំចុងដូង]
កេង_សួរ

សកម្មភាពផ្សព្វផ្សាយជាសាធារណៈសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំចុងដូង

# ឯកសារយោង

# ឯកសារយោង

១. ឯកសារព័ត៌មានស្ថានភាពឃុំចុងដូងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៣ របស់មន្ទីរផែនការខេត្ត
២. ឯកសារព័ត៌មានស្ថានភាពឃុំចុងដូងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៤ របស់មន្ទីរផែនការខេត្ត
៣. ឯកសារព័ត៌មានស្ថានភាពឃុំចុងដូងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៥ របស់មន្ទីរផែនការខេត្ត
៤. ឯកសារព័ត៌មានស្ថានភាពឃុំចុងដូងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ របស់មន្ទីរផែនការខេត្ត
៥. ឯកសារព័ត៌មានស្ថានភាពឃុំចុងដូងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៧ របស់មន្ទីរផែនការខេត្ត
៦. ផែនការអភិវឌ្ឍន៍ឃុំរយៈពេលប្រាំឆ្នាំ(២០១៨-២០២២)របស់ឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ
៧. ផែនការអភិវឌ្ឍន៍ស្រុករយៈពេលប្រាំឆ្នាំ(២០១៨-២០២២)របស់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ
៨. កម្មវិធីវិនិយោគឃុំចុងដូង ឆ្នាំ២០១៧ របស់ឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ
៩. របាយការណ៍ស្តីពីការវិភាគប្រព័ន្ធកសិត្រ-បរិស្ថាន ឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ឆ្នាំ២០១៧
១០. អនុក្រឹត្យស្តីពីការកំណត់ដែនព្រៃលិចទឹក ៦៤៧,៤០៦ហិកតា ស្ថិតនៅក្នុងខេត្តទាំង៦ជុំវិញបឹងទន្លេសាប (កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប)
១១. អនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ៨៨.អនក្រ.បក ស្តីពីការបង្កើតតំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប ។